សាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច
Université Royale de Droit et des Sciences Economiques
Royal University of Law and Economics

## សារណាបញ្ចប់ការសិក្សា

# ការផ្ទេរបេតិកភណ្ឌពាណិជ្ជកម្ម

ស្រាវជ្រាវចាប់ពីថ្ងៃទី០៣ ខែមេសា ឆ្នាំ២០២៣ ដល់ថ្ងៃទី៣១ ខែឧសភា ឆ្នាំ២០២៣

ស្រាវជ្រាវដោយ
និស្សិតឈ្មោះ លោក **អោក ម៉េងអ៊ូ**
លោក **ហ៊ា សុផានិត**

ណែនាំដោយ
សាស្ត្រាចារ្យជំនួយ **ព្រុំ រិទ្ធី**

ថ្នាក់បរិញ្ញាបត្រ **នីតិសាស្ត្រ**
ជំនាន់ទី២៣

ឆ្នាំចូលសិក្សា ២០១៩
ឆ្នាំសរសេរសារណា ២០២៣

**សាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច**

Université Royale de Droit et des Sciences Economiques

Royal University of Law and Economics

**សារណាបញ្ចប់ការសិក្សា**

# ការផ្ទេរបេតិកភណ្ឌពាណិជ្ជកម្ម

ស្រាវជ្រាវចាប់ពីថ្ងៃទី០៣ ខែមេសា ឆ្នាំ២០២៣ ដល់ថ្ងៃទី៣១ ខែឧសភា ឆ្នាំ២០២៣

ស្រាវជ្រាវដោយ

និស្សិតឈ្មោះ លោក **អោក ម៉េងអ៊ី**

លោក **ហ៊ា សុផានិត**

ណែនាំដោយ

សាស្ត្រាចារ្យជំនួយ **ព្រុំ រិទ្ធី**

ថ្នាក់បរិញ្ញាបត្រ **នីតិសាស្ត្រ**

ជំនាន់ទី២៣

ឆ្នាំចូលសិក្សា ២០១៩

ឆ្នាំសរសេរសារណា ២០២៣

# **សេចក្តីថ្លែងអំណរគុណ**

ខ្ញុំបាទទាំងពីររូបឈ្មោះ **អេង ម៉េងអ៊ី** និង **ហ៊ា សុផានិត** ជានិស្សិតបរិញ្ញាបត្រផ្នែកនីតិសាស្ត្រ ឆ្នាំទី៤ ជំនាន់២៣ ឆ្នាំសិក្សា២០១៩ ដល់ ២០២៣ នៃសាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច។ សូមថ្លែងអំណរគុណ និងសម្តែងនូវភាពកតញ្ញូយ៉ាងជ្រាលជ្រៅបំផុតចំពោះ៖

**លោកឪពុក អ្នកម្តាយ** ដែលលោកទាំងពីរបានផ្តល់កំណើត និងចិញ្ចឹមបីបាច់ថែរក្សាខ្ញុំបាទទាំងពីររូបឱ្យធំដឹងក្តី ព្រមទាំងឧបត្ថម្ភគាំទ្រគ្រប់បែបយ៉ាងទាំងផ្នែកស្មារតី ផ្នែកសេដ្ឋកិច្ច កម្លាំងកាយ កម្លាំងចិត្ត ផ្តល់ភាពកក់ក្តៅ ជាពិសេសផ្តល់ការអប់រំទូន្មានប្រៀនប្រដៅប្រកបដោយព្រហ្មវិហារធម៌ជួយជម្រុញតម្រង់ផ្លូវឱ្យកូនសមប្រកបឆ្ពោះទៅកាន់មាគ៌ាមួយដែលជោគជ័យ រហូតដល់បានបញ្ចប់ថ្នាក់បរិញ្ញាបត្រកម្រិតឧត្តមសិក្សា។

**ឯកឧត្តមបណ្ឌិតសាកលវិទ្យាធិការ សាកលវិទ្យាធិការរង លោក លោកស្រី សាស្ត្រាចារ្យទាំងអស់** នៅសាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច ដែលបានខិតខំប្រឹងប្រែងអស់ពីកម្លាំងកាយចិត្តក្នុងការបណ្តុះបណ្តាល បង្ហាត់បង្រៀនដល់ខ្ញុំបាទទាំងពីររូបរហូតបានបញ្ចប់ការសិក្សា ថ្នាក់បរិញ្ញាបត្រ។

ជាពិសេស **សាស្ត្រាចារ្យជំនួយ ព្រុំ រិទ្ធី** ជាសាស្ត្រាចារ្យណែនាំ ដែលបានលះបង់អស់ពីកម្លាំង កាយចិត្ត និងពេលវេលាផ្ទាល់ខ្លួនយ៉ាងមានតម្លៃដើម្បីបង្ហាត់បង្ហាញផ្លូវល្អ បានផ្តល់អនុសាសន៍ជាច្រើន ទាក់ទងវិធីសាស្ត្រស្រាវជ្រាវ ការប្រមូលឯកសារ ការសរសេរអត្ថបទ ការវិភាគទិន្នន័យសម្រាប់ជាជំនួយចំពោះ ការចងក្រងកិច្ចការស្រាវជ្រាវ ជាពិសេសបានត្រួតពិនិត្យកែតម្រូវលើអត្ថបទនៃកិច្ចការស្រាវជ្រាវមួយនេះយ៉ាង ហ្មត់ចត់ធ្វើឱ្យកាន់តែល្អប្រសើរបន្ថែមទៀត និងលេចចេញជារូបរាងប្រកបដោយជោគជ័យ។

សូមអរគុណដល់មិត្តភក្តិទាំងអស់គ្នាជានិច្ចកាលតែងតែជួយគាំទ្រ និងជួយលើកទឹកចិត្ត។

ជាកិច្ចចុងក្រោយនេះ ខ្ញុំបាទទាំងពីររូបសូមសម្តែងនូវការដឹងគុណជាអនេកប្បការ និងសូមគោរពជូនពរលោក អ្នកទាំងអស់គ្នាឱ្យជួបប្រទះតែសំណាងល្អ សុខភាពល្អ និងសម្រេចជោគជ័យគ្រប់ភារកិច្ចទាំងអស់។

# អារម្ភកថា

ជាបឋម ខ្ញុំទាំងពីរនាក់ជានិស្សិតដែលកំពុងសិក្សាឆ្នាំទី៤ ជំនាញនីតិសាស្ត្រ ជំនាន់២៣ នៃសាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច សូមក្រាបថ្វាយបង្គំព្រះថេរានុថេរៈគ្រប់ព្រះអង្គ និងសូមធ្វើគារវកិច្ច គោរពជម្រាបសួរសម្តេច ទ្រង់ ឯកឧត្តម លោកជំទាវ លោក លោកស្រី លោកគ្រូ អ្នកគ្រូជាទីគោរពដ៏ខ្ពង់ខ្ពស់ សិស្សនិស្សិត និងមិត្តរួមថ្នាក់ទាំងអស់ជាទីរាប់អាន។ ខ្ញុំបាទទាំងពីររូបពិតជាមានក្តីសោមនស្សរីករាយ និងសប្បាយចិត្តខ្លាំងជាអនេកក្រៃលែង ដែលមានឱកាសចងក្រងនូវអត្ថបទកិច្ចការស្រាវជ្រាវ និងសរសេរសារណាបញ្ចប់ការសិក្សាលើប្រធានបទ «**ការផ្ទេរបេតិកភណ្ឌពាណិជ្ជកម្ម**»។

ចំពោះកិច្ចការស្រាវជ្រាវមួយនេះ គឺចង់សិក្សាផ្តោតទៅលើ «**ការផ្ទេរបេតិកភណ្ឌពាណិជ្ជកម្ម**»។ ការផ្ទេរបេតិកភណ្ឌពាណិជ្ជកម្ម គឺជាប្រធានបទមួយដែលមានយន្តការសំខាន់បន្ថែមក្នុងការពង្រឹងវិស័យពាណិជ្ជកម្មសង្គមខ្មែរនាពេលបច្ចុប្បន្ននេះ ក្នុងនោះទៀតសោធ អាជ្ញាធរពាក់ព័ន្ធមានតួនាទី ដោះស្រាយវិវាទទាក់ទងនឹងការផ្ទេរទ្រព្យសម្បត្តិ ឬកេរ្តិ៍ម៌តរបស់នីតិបុគ្គលឯកជន និងរូបវន្តបុគ្គល តាមគោលការណ៍ច្បាប់ដែលបានចែង។ ដូចនេះក៏មានការធ្វើអនុប្បទានទៅដល់ម្ចាស់ភាគហ៊ុនរំលាយ ឬរំលាយបញ្ចូលភាគហ៊ុនដោយប្រការណាមួយ។ លើសពីនេះ ដើម្បីឱ្យកាន់តែស៊ីជម្រៅលើប្រធានបទនេះ ខ្ញុំបាទទាំងពីររូបបានបកស្រាយដោយដកស្រង់ចេញពី បទប្បញ្ញត្តិច្បាប់ក្នុងព្រះរាជាណាចក្រកម្ពុជា លើកយក ឯកសារចាស់ៗថ្មីៗជាច្រើន ដែលបានវិវត្តន៍មកដល់បច្ចុប្បន្ន គឺក្នុងហេតុផលចង់ឱ្យកិច្ចការស្រាវជ្រាវមួយនេះ កាន់តែច្បាស់លាស់បន្ថែមទៀត។ ជាពិសេស ចំពោះការធ្វើកិច្ចការស្រាវជ្រាវនេះ ពិតជាគេចមិនផុតពីកំហុសខុស ឆ្គងដោយអចេតនានោះទេ ដូចសុភាសិតមួយពោលថា ដំរីជើងបួនគង់មានភ្លាត់ អ្នកប្រាជ្ញចេះស្ទាត់គង់មានភ្លេច ដោយសារតែកត្តានេះហើយទើបធ្វើឱ្យការស្រាវជ្រាវនេះនឹងអាចមានចន្លោះខ្វះខាតណាមួយដែលតម្រូវឱ្យបំពេញបន្ថែម។ ប៉ុន្តែទោះជាយ៉ាងណាក៏ដោយ ខ្ញុំបាទទាំងពីររូបនឹងព្យាយាមឱ្យអស់ពីលទ្ធភាព និងសមត្ថភាពហើយក៏សូមស្វាគមន៍នូវរាល់មតិរិះគន់ និងមតិស្ថាបនាទៅលើចំណុចខ្វះខាតរបស់អត្ថបទនេះដើម្បីឱ្យកាន់តែស៊ីជម្រៅ មានអត្ថន័យខ្លឹមសារពេញលេញបរិបូរណ៍។

ជាទីបញ្ចប់ ខ្ញុំបាទទាំងពីររូបសូមគោរពជូនពរដល់សាស្ត្រាចារ្យ និងមិត្តនិស្សិតរួមថ្នាក់ទាំងអស់ដែលបានចំណាយពេលវេលាដ៏មានតម្លៃក្នុងការអាន និងស្តាប់នូវខ្លឹមសារដែលបានចងក្រងនេះ ឱ្យជួបតែសំណាងល្អ សូមទទួលបាននូវពុទ្ធពរទាំងបួនប្រការ គឺអាយុ វណ្ណៈ សុខៈ ពលៈ និងបដិភានៈគ្រប់ពេលវេលា។

# មាតិកា

ទំព័រ

**សេចក្តីផ្តើម** ........ ១

**ជំពូកទី១**

**មូលហេតុនៃការផ្ទេរបេតិកភណ្ឌពាណិជ្ជកម្ម**

**ផ្នែកទី១៖ ការធ្វើអនុប្បទានមូលនិធិពាណិជ្ជកម្ម** ........ ៤

**១.១. អនុប្បទានតាមរបបសន្តតិកម្ម** ........ ៤

១.១.១. សន្តតិកម្មតាមច្បាប់ ........ ៤

១.១.២. សន្តតិកម្មតាមបណ្តាំ ........ ៥

**១.២. អនុប្បទានតាមរយៈកិច្ចសន្យា** ........ ៧

១.២.១. លក្ខខណ្ឌគ្រឹះនៃការបង្កើតកិច្ចសន្យា ........ ៨

១.២.២. លក្ខខណ្ឌទម្រង់នៃការបង្កើតកិច្ចសន្យា ........ ៩

**ផ្នែកទី២៖ ការធ្វើអនុប្បទានក្រុមហ៊ុនពាណិជ្ជកម្ម** ........ ១០

**២.១. ចូលភាគហ៊ុន** ........ ១០

២.១.១. លក្ខន្តិកៈនៃការចូលភាគហ៊ុន ........ ១០

២.១.២. សិទ្ធិនៃម្ចាស់ភាគហ៊ុន ........ ១១

**២.២. បញ្ជូលក្រុមហ៊ុនពាណិជ្ជកម្ម** ........ ១២

២.២.១. លក្ខខណ្ឌនៃការរំលាយបញ្ចូលក្រុមហ៊ុន ........ ១២

២.២.២. ការផ្តល់វិញ្ញាបនបត្របញ្ជាក់ពីការរំលាយក្រុមហ៊ុន ........ ១៥

២.២.៣. លក្ខខណ្ឌក្នុងការទាមទារឱ្យមានការវាយតម្លៃភាគហ៊ុន ........ ១៥

**២.៣. យុទ្ធសាស្ត្រនៃការចរចា** ........ ១៦

**ជំពូកទី២**

**នីតិវិធីនៃការផ្ទេរបេតិកភណ្ឌពាណិជ្ជកម្ម**

**ផ្នែកទី១៖ ការផ្ទេរបេតិកភណ្ឌពាណិជ្ជកម្មតាមរបបសន្តតិកម្ម** ........ ១៨

**១.១. ការយល់ព្រមទាំងស្រុង** ........ ១៨

**១.២. ការយល់ព្រមដោយមានកម្រិត** ........ ១៨
១.២.១. ការធ្វើបញ្ជីសារពើភ័ណ្ឌ ........ ១៩
១.២.២. ការដាក់ពាក្យស្នើសុំទៅតុលាការ ........ ២០
**ផ្នែកទី២៖ ការផ្ទេរបេតិកភណ្ឌពាណិជ្ជកម្មតាមនីតិក្រុមហ៊ុន** ........ ២១
**២.១. ក្រសួងសាមី ឬក្រសួងពាណិជ្ជកម្ម** ........ ២១
២.១.១ ការចុះបញ្ជីពាណិជ្ជកម្ម ........ ២១
២.១.២. ការផ្ទេរក្រុមហ៊ុន ឬលក់ភាគហ៊ុន ........ ២២
២.១.៣. ឯកសារដែលត្រូវតម្កល់ ........ ២២

## ជំពូកទី៣

## អានុភាពនៃការផ្ទេរបេតិកភណ្ឌពាណិជ្ជកម្ម

**ផ្នែកទី១៖ ការផ្ទេរបេតិកភណ្ឌពាណិជ្ជកម្មទៅលើទ្រព្យសកម្ម** ........ ២៤
**១.១ អនុប្បទានសិទ្ធិលើបំណុល** ........ ២៤
១.១.១. លក្ខខណ្ឌនៃការអនុវត្តសិទ្ធិលើបំណុល ........ ២៥
១.១.២. លក្ខខណ្ឌនៃការជូនដំណឹងអំពីការធ្វើអនុប្បទានសិទ្ធិលើបំណុល ........ ២៥
**១.២. សិទ្ធិតតាំងជាមួយតតិយជន** ........ ២៥
**១.៣. កម្មសិទ្ធិឧស្សាហកម្ម** ........ ២៧
១.៣.១. ប្រកាសនីយបត្រតក្កកម្ម និងវិញ្ញាបនបត្រម៉ូដែលមានប្រយោជន៍ ........ ២៧
១.៣.២. គំនូរឧស្សាហកម្មក្រុមហ៊ុន ........ ២៧
១.៣.៣. ម៉ាក ........ ២៨
១.៣.៤. ការសម្ងាត់ពាណិជ្ជកម្ម ........ ២៨
**ផ្នែកទី២៖ ការផ្ទេរបេតិកភណ្ឌពាណិជ្ជកម្មទៅលើទ្រព្យអកម្ម** ........ ២៩
**២.១. ម្ចាស់បំណុលមានអភ័យឯកសិទ្ធិ** ........ ២៩
២.១.១. លក្ខខណ្ឌហ៊ីប៉ូតែក ........ ២៩
២.១.២. កម្មករនិយោជិត ........ ៣០

២.២. អានុភាពផ្ទេរបេតិកភណ្ឌ ............................................................................ ៣១
**សេចក្តីសន្និដ្ឋាន** ............................................................................ ៣៣
**អនុសាសន៍** ............................................................................ ៣៤
**ឯកសារយោង**
**ឧបសម្ព័ន្ធ**

# សេចក្តីផ្តើម

# សេចក្តីផ្តើម

## ១. លំនាំបញ្ហានៃការស្រាវជ្រាវ

ការវិវត្តន៍នៃការធ្វើពាណិជ្ជកម្មដំបូងរបស់មនុស្ស គឺជាការផ្លាស់ប្តូរវត្ថុគ្នាទៅវិញទៅមកប៉ុណ្ណោះ។ ប៉ុន្តែដោយសារតែកំណើននៃប្រជាជនមានការកើនឡើង ដែលជាហេតុនាំឱ្យកំណើននៃតម្រូវការក្នុងការរស់នៅ ក៏ដូចជាវត្ថុប្រើប្រាស់មានការកើនឡើង ទើបធ្វើឱ្យមានការអភិវឌ្ឍន៍នៃការធ្វើពាណិជ្ជកម្មពីភូមិមួយទៅភូមិមួយ ពីតំបន់មួយទៅតំបន់មួយ និងពីប្រទេសមួយទៅប្រទេសមួយ។ នៅក្នុងសតវត្សទី២១ យើងឃើញថាប្រទេសដែលមានការអភិវឌ្ឍន៍លឿន គឺជាប្រទេសដែលធ្វើឱ្យមានលំហូរសេដ្ឋកិច្ចទីផ្សារពាណិជ្ជកម្មសេរី ដោយបើកឱ្យធ្វើបែបនេះគឺបានផ្តល់លទ្ធភាពជូនដល់កសិករ អាជីវករដែលធ្វើការរកស៊ី ម្ចាស់ក្រុមហ៊ុនសហគ្រាសពាណិជ្ជកម្មតូច ធំ និងជាពិសេសវិនិយោគនៅក្នុងប្រទេសក្តី ឬពីបរទេសក្តីឱ្យមានសេរីភាពពេញលេញក្នុងការធ្វើពាណិជ្ជកម្ម។ ការធ្វើពាណិជ្ជកម្មរបស់ក្រុមហ៊ុនសហគ្រាសពាណិជ្ជកម្មមួយ អាចដំណើរការទៅបានរលូនទាល់តែមានអ្នកគ្រប់គ្រងក្រុមហ៊ុនម្នាក់ (ម្ចាស់ក្រុមហ៊ុន) ឬច្រើននាក់ (ម្ចាស់ភាគហ៊ុន) ដើម្បីធ្វើការសម្រេចទៅលើការងារតូច ធំនៅក្នុងក្រុមហ៊ុន។ ទស្សនៈទានមួយបានលើកឡើងថា "កើត ចាស់ ឈឺ ស្លាប់" ដូចនេះនៅក្នុងដំណើរការក្រុមហ៊ុនមួយមនុស្សម្នាក់មិនអាចគ្រប់គ្រងក្រុមហ៊ុនឱ្យស្ថិតស្ថេរបានជារៀងរហូតនោះទេ ដោយតម្រូវឱ្យមានអ្នកឡើងមកស្នងបន្ត ដែលមានចែងនៅក្នុងក្រមរដ្ឋប្បវេណីស្តីពីការធ្វើសន្តតិកម្ម ដែលជាវិធានមួយនៃការផ្ទេរទ្រព្យសម្បត្តិ ឬបេតិកភណ្ឌពាណិជ្ជកម្មរបស់មតកជន ទៅឱ្យសន្តតិជនទទួលបន្តតាមរយៈការស្នងមត៌កតគ្នា ឬតាមរយៈធ្វើមតកសាសន៍របស់មតកជន។ បន្ថែមពីលើនេះទៀតការផ្ទេរបេតិកភណ្ឌពាណិជ្ជកម្ម ក៏អាចកើតឡើងផងដែល ដោយស្ថិតនៅក្រោមលក្ខខណ្ឌនៃការទិញ លក់ ឬធ្វើអនុប្បទានតាមរយៈកិច្ចសន្យា និងការរំលាយបញ្ចូលក្រុមហ៊ុន។ កំណើននៃការផ្ទេរបេតិកភណ្ឌពាណិជ្ជកម្មបែបនេះ គឺដោយសារតែម្ចាស់ក្រុមហ៊ុន ឬម្ចាស់ភាគហ៊ុនមិនអាចមានសមត្ថភាពដើម្បីឱ្យក្រុមហ៊ុនធ្វើដំណើរការបន្តទៅមុខទៀតបាន (ក្ស័យធន) ដែលតម្រូវឱ្យធ្វើការលក់ក្រុមហ៊ុនរបស់ខ្លួន ឬក្នុងន័យចង់ពង្រីកវិសាលភាពនៃក្រុមហ៊ុនរបស់ខ្លួន ក៏ដូចជាដៃគូសហការឱ្យកាន់តែធំឡើងៗ ដោយធ្វើការផ្ទេរបេតិកភណ្ឌក្រុមហ៊ុនរបស់ខ្លួនដោយការរំលាយបញ្ចូលគ្នាជាក្រុមហ៊ុនតែមួយ។

## ២. ចំណោទបញ្ហានៃការស្រាវជ្រាវ

ការផ្ទេរបេតិកភណ្ឌពាណិជ្ជកម្មក្រុមហ៊ុនមួយ អាចកើតមានឡើងនូវបញ្ហាប្រឈមជាច្រើន នៅក្នុងនោះផងដែរបញ្ហាប្រឈម គឺនីតិវិធីនៃផ្ទេរបេតិកភណ្ឌពាណិជ្ជកម្មពីមតកជន (អនុប្បទាយី) ទៅកាន់សន្តតិជន ឬតតិយជន (អនុប្បទានិក)។ ការផ្ទេរទ្រព្យសម្បត្តិធម្មតាវាមានភាពងាយស្រួលដោយគ្រាន់តែតម្រូវឱ្យមតកជនដែលមានបំណងក្នុងការផ្ទេរនោះគោរពទៅតាមលក្ខខណ្ឌនៃការធ្វើសន្តតិកម្មប៉ុណ្ណោះ។ ប៉ុន្តែក្នុងការផ្ទេរបេតិកភណ្ឌពាណិជ្ជកម្មមួយបានវាមានភាពស្មុកស្មាញដែលតម្រូវឱ្យអនុប្បទាយី និងអនុប្បទានិកបំពេញនូវបែបបទ

នីតិវិធីជាច្រើនដើម្បីដាក់ទៅក្រសួងពាណិជ្ជកម្ម ហើយការផ្ទេរនេះផងដែលត្រូវចំណាយពេលវេលាយូរៗ។ លើសពីនេះទៅទៀតនីតិវិធីនៃការដាក់ឯកសារទៅកាន់ក្រសួង តម្រូវឱ្យភ្ជាប់ជាមួយសំណុំឯកសារជាច្រើន ដែលនាំឱ្យមានការខាតបង់ពេលវេលា និងថវិកាដែលត្រូវចំណាយលើឯកសារត្រូវធ្វើការផ្ទេរនោះ។ ដោយមើលឃើញពីទុកលំបាក និងភាពស្មុកស្មាញនៃនីតិវិធីការផ្ទេរបែបនេះហើយទើបធ្វើឱ្យខ្ញុំបាទទាំងពីរនាក់កើតជាចម្ងល់ ថាតើមានមូលហេតុអ្វីខ្លះដែលធ្វើឱ្យកើតមានការផ្ទេរបេតិកភណ្ឌពាណិជ្ជកម្ម? ហើយតើត្រូវមានដំណើរការក្នុងការផ្ទេរមាននីតិវិធីអ្វីខ្លះ? និងតើនៅពេលដែលផ្ទេររួចរាល់អ្នកណាខ្លះមានអានុភាពទៅលើបេតិកភណ្ឌពាណិជ្ជកម្មនោះ?

## ៣. គោលបំណងនៃការស្រាវជ្រាវ

គោលបំណងចម្បងនៃការស្រាវជ្រាវលើប្រធានបទ "**ការផ្ទេរបេតិកភណ្ឌពាណិជ្ជកម្ម**" គឺចង់ពន្យល់អំពីការផ្ទេរដែលស្ថិតក្នុងបរិបទក្រមរដ្ឋប្បវេណី និងច្បាប់ស្តីពីសហគ្រាសពាណិជ្ជកម្ម។ ក្នុងនោះផងដែលក៏មានការបកស្រាយពីកម្មវត្ថុដែលចាំបាច់សម្រាប់គូភាគី (អនុប្បទាយី និងអនុប្បទានិក) នីតិវិធី និងអានុភាពនៃការផ្ទេរបេតិកភណ្ឌពាណិជ្ជកម្ម។ សព្វថ្ងៃមានបញ្ហាជាច្រើនកើតឡើង ដោយសារតែខ្វះការយល់ដឹងអំពីការផ្ទេរបេតិកភណ្ឌ ហេតុដូចនេះហើយ ទើបខ្ញុំបាទទាំងពីររូបជ្រើសរើសប្រធានបទមួយនេះមកធ្វើការសិក្សាស្រាវជ្រាវ។

## ៤.ដែនកំណត់នៃការស្រាវជ្រាវ

វិសាលភាពចំពោះប្រធានបទស្រាវជ្រាវនេះ ខ្ញុំបាទទាំងពីររូបបានលើកយកមកសិក្សាតែទៅលើមូលហេតុដែលកើតឱ្យមានការផ្ទេរបេតិកភណ្ឌពាណិជ្ជកម្ម នីតិវិធីនៃការផ្ទេរបេតិកភណ្ឌពាណិជ្ជកម្ម និងអានុភាពនៃការផ្ទេរបេតិកភណ្ឌពាណិជ្ជកម្មតែប៉ុណ្ណោះ។

## ៥. សារៈសំខាន់នៃការស្រាវជ្រាវ

ការផ្ទេរបេតិកភណ្ឌពាណិជ្ជកម្ម ម្ចាស់ក្រុមហ៊ុនភាគច្រើនតែងតែមើលរំលងដោយគិតថាការផ្ទេរបេតិកភណ្ឌពាណិជ្ជកម្មវាដូចគ្នាទៅនឹងការធ្វើសន្តតិកម្មដែរ។ ប៉ុន្តែផ្ទុយទៅវិញការផ្ទេរបេតិកភណ្ឌពាណិជ្ជកម្មនេះមានលក្ខណៈសាំញ៉ាំ។ ការយល់ដឹងអំពីការផ្ទេរបេតិកភណ្ឌពាណិជ្ជកម្មអនុប្បទាយី និងអនុប្បទានិកនឹងទទួលបានប្រយោជន៍ដូចជា៖

១. យល់ដឹងកាន់តែច្បាស់អំពីថាតើមូលហេតុអ្វីដែលធ្វើឱ្យមានការកើតឡើងនៃការផ្ទេរមូលនិធិពាណិជ្ជកម្ម

២. យល់ដឹងអំពីនីតិវិធីនីមួយៗនៃការផ្ទេរបេតិកភណ្ឌពាណិជ្ជកម្ម ដែលអាចជួយឱ្យយើងត្រៀមឯកសារជាមុនដើម្បីធ្វើការស្នើសុំ និងជួយដល់នីតិវិធីនៃការផ្ទេរមានភាពលឿនជាងមុន។

៣. អាចធ្វើឱ្យអនុប្បទានិកដែលជាម្ចាស់ក្រុមហ៊ុនថ្មី យល់ដឹងបន្ថែមអំពីសិទ្ធិ និងកាតព្វកិច្ចរបស់ខ្លួនថាតើខ្លួនទទួលបានអ្វីខ្លះ នៅពេលដែលខ្លួនទទួលបានសិទ្ធិក្លាយជាអ្នកគ្រប់គ្រងទៅលើក្រុមហ៊ុន។

## ៦. វិធីសាស្ត្រនៃការស្រាវជ្រាវ

ក្នុងការស្រាវជ្រាវនូវលើប្រធានបទនេះផងដែល ខ្ញុំបាទទាំងពីរនាក់បានធ្វើការប្រមូលទិន្នន័យៈ ដោយធ្វើការប្រមូលទិន្នន័យដែលទទួលបានតាមរយៈគេហទំព័ររបស់ក្រសួងពាណិជ្ជកម្ម ក្រមរដ្ឋប្បវេណី ច្បាប់ស្ដីពីសហគ្រាសពាណិជ្ជកម្ម និងសៀវភៅសំខាន់ៗ ជាច្រើនទៀតដែលបានធ្វើការស្រាវជ្រាវដោយសាស្ត្រាចារ្យដែលមានជំនាញ។

## ៧. រចនាសម្ព័ន្ធនៃការស្រាវជ្រាវ

ប្រធានបទនេះត្រូវបានបែងចែកជា ៣ (បី) ជំពូកធំៗ ដែលនៅក្នុងជំពូកនីមួយៗមានផ្នែក ក្នុងផ្នែកនីមួយៗមានកថាខណ្ឌ និងក្នុងកថាខណ្ឌនីមួយៗមានចំណុច។ ដើម្បីធ្វើការស្រាយបំភ្លឺអំពីចំណោទបញ្ហាគតិយុត្តខាងលើឱ្យកាន់តែច្បាស់លាស់យើងនឹងធ្វើការស្រាវជ្រាវទៅលើ **(ជំពូកទី១)** មូលហេតុនៃការផ្ទេរបេតិកភណ្ឌពាណិជ្ជកម្ម **(ជំពូកទី២)** នីតិវិធីនៃការផ្ទេរបេតិកភណ្ឌពាណិជ្ជកម្ម និង **(ជំពូកទី៣)** អានុភាពនៃការផ្ទេរបេតិកភណ្ឌពាណិជ្ជកម្ម។

# ជំពូកទី១
# មូលហេតុនៃការផ្ទេរ
# បេតិកភណ្ឌពាណិជ្ជកម្ម

# ជំពូកទី១
# មូលហេតុនៃការផ្ទេរបេតិកភណ្ឌពាណិជ្ជកម្ម

បេតិកភណ្ឌពាណិជ្ជកម្ម គឺជាវិធានទំនាក់ទំនងទៅនឹងប្រតិបត្តិការ ការផ្ទេរបេតិកភណ្ឌ ឬសកម្មភាពពាណិជ្ជកម្ម និងពាណិជ្ជកិច្ចដែលចាត់ចែងឡើងដោយពាណិជ្ជករដែលជារូបវន្តបុគ្គល និងក្រុមហ៊ុនពាណិជ្ជកម្មដែលជាពាណិជ្ជករ ជានីតិបុគ្គល។ ជួនកាលវិធានទាំងនេះត្រូវបានអនុវត្តទៅលើ ពាណិជ្ជករ និងពាណិជ្ជករគ្នាឯង និងជួនកាលរវាងសហគ្រិន និងអតិថិជនរបស់ខ្លួន។ ហេតុនេះហើយការផ្ទេរបេតិកភណ្ឌពាណិជ្ជកម្មអាចកើតឡើងពីការធ្វើអនុប្បទានមូលនិធិពាណិជ្ជកម្ម **(ផ្នែកទី១)** និងការធ្វើអនុប្បទានក្រុមហ៊ុនពាណិជ្ជកម្ម **(ផ្នែកទី២)**។

## ផ្នែកទី១៖ ការធ្វើអនុប្បទានមូលនិធិពាណិជ្ជកម្ម

ការធ្វើអនុប្បទានមូលនិធិពាណិជ្ជកម្មគឺជាការផ្ទេរសិទ្ធិ និងទ្រព្យសម្បត្តិមួយផ្នែក ឬទាំងស្រុង របស់បុគ្គលណាម្នាក់ដែលជា អនុប្បទាយី ទៅឱ្យបុគ្គលម្នាក់ទៀតដែលជា អនុប្បទានិក ឬតតិយជន។ ហើយការធ្វើអនុប្បទានមូលនិធិពាណិជ្ជកម្មនេះយើងអាចធ្វើឡើងតាម **១.** អនុប្បទានតាមរបបសន្តិតិកម្ម និង **២.** អនុប្បទានតាមរយៈកិច្ចសន្យា។

### ១.១. អនុប្បទានតាមរបបសន្តតិកម្ម

ការធ្វើអនុប្បទានតាមរបបសន្តតិកម្ម គឺជាការផ្ទេរនូវសិទ្ធិ កាតព្វកិច្ច និងករណីកិច្ចរបស់មតកជនទៅឱ្យសន្តតិជនម្នាក់ ឬច្រើននាក់។[1] សន្តតិកម្ម ត្រូវចាប់ផ្ដើមដោយមរណភាពរបស់មតកជន។ សន្តតិកម្ម ត្រូវធ្វើឡើងដោយផ្អែកតាមបញ្ញត្តិនៃច្បាប់ ឬដោយផ្អែកតាមឆន្ទៈរបស់មតកជន។ សន្តតិកម្មដោយផ្អែកតាមបញ្ញត្តិនៃច្បាប់ហៅថាសន្តតិកម្មតាមច្បាប់សន្តតិកម្មដោយផ្អែកតាមឆន្ទៈរបស់មតកជន ហៅថាសន្តតិកម្មតាមបណ្ដាំ។[2]

#### ១.១.១. សន្តតិកម្មតាមច្បាប់

សន្តតិកម្មតាមច្បាប់ គឺការបែងចែកមត៌កដែលគ្មានការបែងចែកពីសំណាក់មតកជនតាមរយៈលិខិតយថាភូតឡើយ។ ពោលគឺកើតឡើងនៅពេលដែលសន្តតិជនបានទទួលមរណភាព ហើយទ្រព្យសម្បត្តិត្រូវបែងចែកទៅតាមលំដាប់របស់សន្តតិជននីមួយៗ។ សន្តតិជន គឺជាអ្នកដែលត្រូវទទួលនូវសិទ្ធិ និងករណីកិច្ចរបស់មតកជនតាមរយៈសន្តតិកម្ម។[3] ហើយសន្តតិជនដែលអាចទទួលបានមូលនិធិពាណិជ្ជកម្មតាមរបបសន្តតិកម្ម

[1] សន្ធានុក្រមផ្នែករដ្ឋប្បវេណី ឆ្នាំ២០០៧។

[2] មាត្រា ១១៤៥ ក្រមរដ្ឋប្បវេណីព្រះរាជាណាចក្រកម្ពុជា ០៨ ធ្នូ ២០០៧។

[3] សន្ធានុក្រមផ្នែករដ្ឋប្បវេណី ឆ្នាំ២០០៧។

ត្រូវបានបែងចែកជា ៤ (បួន) លំដាប់ដូចជា សន្តតិជនលំដាប់ទី១[4] ជាកូនរបស់ (អនុប្បទាយី) សន្តតិជនលំដាប់ទី២[5] (ឪពុកម្តាយរបស់អនុប្បទាយី) សន្តតិជនលំដាប់ទី៣[6] (បងប្អូនបង្កើតរបស់អនុប្បទាយី) និងសន្តតិជនជានិច្ច[7] (ជាសហព័ន្ធរបស់អនុប្បទាយី)។ ប៉ុន្តែក្នុងករណីដែលសន្តតិជនលំដាប់ទី១ កូនរបស់មតកជន (អនុប្បទានិក) បានទទួលមរណភាពនៅមុនពេលចាប់ផ្តើមសន្តតិកម្ម បានបាត់បង់សិទ្ធិសន្តតិកម្ម ដោយត្រូវនឹងលក្ខខណ្ឌដែលបានកំណត់ក្នុងបញ្ញត្តិនៃមាត្រា ១១៥០ (អភ័ព្វបុគ្គលនៃសន្តតិកម្ម ជាអាទិ៍)[8] ខាងលើនេះ ឬដោយការផ្តាច់មត៌ក កូនរបស់អនុប្បទានិកនោះត្រូវក្លាយទៅជាសន្តតិជនជំនួស[9]។ អច្ច័យលាភី គឺជាបុគ្គលដែលទទួលបានអច្ច័យទាន។[10]

### ១.១.២. សន្តតិកម្មតាមបណ្តាំ

សន្តតិកម្មតាមបណ្តាំ ឬហៅថាសន្តតិកម្មតាមមតកសាសន៍ គឺជាកិច្ចឯកតោភាគីដែលអាចប្រព្រឹត្តិទៅបានច្រើនរបៀបក្នុងទម្រង់ជាលិខិតឯកជន លិខិតយថាភូត ឬជាលិខិតសម្ងាត់។ ហេតុនេះលិខិតមតកសាសន៍មានភាពដូចគ្នាទៅនឹងកិច្ចគតិយុត្តដ៏ទៃទៀតដែរ ដើម្បីបង្កើតអានុភាពតាមផ្លូវច្បាប់បាន ចាំបាច់ត្រូវគោរពតាមលក្ខខណ្ឌ និងនីតិវិធីនៃការបង្កើតមតកសាសន៍។

ដើម្បីអាចធ្វើការផ្ទេរបេតិកភណ្ឌពាណិជ្ជកម្មមួយតាមរបបសន្តតិកម្ម អនុប្បទាយីអាចធ្វើការផ្ទេរបេតិកភណ្ឌរបស់ខ្លួនតាមរយៈការធ្វើបណ្តាំ។ ការធ្វើបណ្តាំផ្ទេរបេតិកភណ្ឌអាចធ្វើឡើងទៅបានច្រើនរបៀប ច្រើនទម្រង់ដែលអនុប្បទាយីអាចធ្វើការសម្រេចចិត្តមុននឹងបង្កើតមតកសាសន៍បាន។ បើយោងតាមក្រមរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជា ការបង្កើតមតកសាសន៍អនុប្បទាយីអាចធ្វើឡើងតាម ៣ (បី) ទម្រង់ដូចជា ១. មតកសាសន៍ដោយលិខិតយថាភូត ២. មតកសាសន៍ដោយលិខិតឯកជន និង ៣. មតកសាសន៍ដោយលិខិតសម្ងាត់។

[4] មាត្រា ១១៥៦ ក្រមរដ្ឋប្បវេណីព្រះរាជាណាចក្រកម្ពុជា ០៨ ធ្នូ ២០០៧។

[5] មាត្រា ១១៥៨ ក្រមរដ្ឋប្បវេណីព្រះរាជាណាចក្រកម្ពុជា ០៨ ធ្នូ ២០០៧។

[6] មាត្រា ១១៦០ ក្រមរដ្ឋប្បវេណីព្រះរាជាណាចក្រកម្ពុជា ០៨ ធ្នូ ២០០៧។

[7] មាត្រា ១១៦១ ក្រមរដ្ឋប្បវេណីព្រះរាជាណាចក្រកម្ពុជា ០៨ ធ្នូ ២០០៧។

[8] មាត្រា ១១៥០ ក្រមរដ្ឋប្បវេណីព្រះរាជាណាចក្រកម្ពុជា ០៨ ធ្នូ ២០០៧។

[9] មាត្រា ១១៥៧ ក្រមរដ្ឋប្បវេណីព្រះរាជាណាចក្រកម្ពុជា ០៨ ធ្នូ ២០០៧។

[10] សទ្ទានុក្រមផ្នែករដ្ឋប្បវេណី ឆ្នាំ២០០៧។

### ១.១.២.១. មតកសាសន៍ដោយលិខិតយថាភូត

ការធ្វើមតកសាសន៍ដោយលិខិតយថាភូត គឺជាប្រភេទលិខិតមតកសាសន៍មួយបែបដែលត្រូវសរសេរឡើងដោយផ្ទាល់ដៃរបស់មតកជន ហើយត្រូវភ្ជាប់មកជាមួយនឹងហត្ថលេខា និងថ្ងៃខែឆ្នាំដែលចុះហត្ថលេខានៅលើលិខិតនោះ។[11] មតកសាសន៍ដោយលិខិតយថាភូតត្រូវធ្វើឡើងតាមទម្រង់ដូចខាងក្រោមនេះ៖

- ត្រូវមានវត្តមានរបស់សាក្សីយ៉ាងតិច ២ (ពីរ) នាក់។
- ម្ចាស់បណ្ដាំត្រូវប្រាប់ដោយផ្ទាល់មាត់ នូវខ្លឹមសារនៃមតកសាសន៍ ចំពោះសារការី។
- សារការីត្រូវសរសេរនូវអត្ថន័យនៃមតកសាសន៍របស់ម្ចាស់បណ្ដាំនោះ ជាលាយល័ក្ខណ៍អក្សរហើយត្រូវសូត្រឱ្យម្ចាស់បណ្ដាំ និងសាក្សីនោះស្ដាប់។
- បន្ទាប់ពីម្ចាស់បណ្ដាំ និងសាក្សីបានទទួលស្គាល់ថាកំណត់ជាលាយល័ក្ខណ៍អក្សរនោះត្រឹមត្រូវហើយ ជននីមួយៗនោះត្រូវធ្វើឱ្យមានភាពច្បាស់លាស់នៅលើឯកសារអំពីឈ្មោះ អាយុ និងលំនៅ-ឋាន ហើយត្រូវចុះហត្ថលេខារៀងៗខ្លួន។ ប៉ុន្តែបើម្ចាស់បណ្ដាំ មិនអាចសរសេរអក្សរ ឬមិនអាចចុះហត្ថលេខាបានទេ សារការីអាចជំនួសការសរសេរ និងហត្ថលេខាដូចកំណត់ខាងលើនេះ ដោយសរសេរឈ្មោះ អាយុ និងលំនៅឋានរបស់ជននោះ ហើយត្រូវសរសេរបន្ថែមនូវហេតុនោះផង។
- សារការីត្រូវសរសេរថ្ងៃខែឆ្នាំ ហើយត្រូវចុះហត្ថលេខា។[12]

### ១.១.២.២. មតកសាសន៍ដោយលិខិតឯកជន

មតកសាសន៍ដោយលិខិតឯកជន ត្រូវធ្វើឡើងដោយម្ចាស់បណ្ដាំសរសេរពាក្យទាំងអស់ និងចុះថ្ងៃខែឆ្នាំដោយខ្លួនឯង ហើយត្រូវចុះហត្ថលេខាលើលិខិតនោះ។ មតកសាសន៍ដោយលិខិតឯកជន ដែលត្រូវបានសរសេរជំនួសដោយអ្នកដទៃ ឬដែលត្រូវបាន សរសេរដោយប្រើម៉ាស៊ីនដូចជាអង្គុលីលេខ ជាអាទិ៍នឹងត្រូវចាត់ទុកជាមោឃៈ។ ការបន្ថែម ការលុប ឬការកែប្រែផ្សេងទៀត នៅក្នុងមតកសាសន៍ដោយលិខិតឯកជន ពុំមានអានុភាពឡើយ បើម្ចាស់បណ្ដាំមិនបានបង្ហាញនូវកន្លែង ហើយសរសេរបន្ថែមនូវហេតុនៃការកែប្រែនោះជាពិសេសបើមិនបានចុះហត្ថលេខាទេ។[13] យោងតាមមាត្រា ១១៧០ កថាខណ្ឌទី២ វាក្យខណ្ឌទី១ មតកសាសន៍ដែលធ្វើមិនត្រូវនឹងទម្រង់ណាមួយក្នុងបញ្ញត្តិនៃក្រមនេះត្រូវចាត់ទុកជាមោឃៈ។[14]

---

[11] មាត្រា ១១៧៣ ក្រមរដ្ឋប្បវេណីព្រះរាជាណាចក្រកម្ពុជា ឆ្នាំ ២០០៧។

[12] មាត្រា ១១៧៣ ក្រមរដ្ឋប្បវេណីព្រះរាជាណាចក្រកម្ពុជា ឆ្នាំ ២០០៧។

[13] មាត្រា ១១៧៤ ក្រមរដ្ឋប្បវេណីព្រះរាជាណាចក្រកម្ពុជា ឆ្នាំ ២០០៧។

[14] មាត្រា ១១៧០ កថាខណ្ឌទី២ វាក្យខណ្ឌទី១ ក្រមរដ្ឋប្បវេណីព្រះរាជាណាចក្រកម្ពុជា ឆ្នាំ ២០០៧។

#### **១.១.២.៣. មតកសាសន៍ដោយលិខិតសម្ងាត់**

មតកសាសន៍ដោយលិខិតសម្ងាត់ មតកសាសន៍ដោយលិខិតសម្ងាត់ត្រូវធ្វើឡើង ដោយយោងតាមទម្រង់ដូចខាងក្រោមនេះ៖

- ម្ចាស់បណ្តាំត្រូវចុះហត្ថលេខាលើលិខិតនោះ។
- ម្ចាស់បណ្តាំត្រូវដាក់លិខិតនោះក្នុងស្រោមបិទជិត ហើយត្រូវចុះហត្ថលេខា ឬសរសេរសញ្ញាសំគាល់ ឬមធ្យោបាយផ្សេងទៀតដែលអាចវិនិច្ឆ័យបានអំពីការបានបើក ឬមិនបានបើកស្រោមលិខិតនោះ នៅមាត់ស្រោមលិខិតនោះ។
- ម្ចាស់បណ្តាំត្រូវដាក់លិខិតដែលបានបិទជិតនោះ នៅចំពោះមុខសារការីម្នាក់ និងសាក្សី ២ (ពីរ) នាក់ និងធ្វើសេចក្តីថ្លែងការណ៍ថាលិខិតនេះជាលិខិតមតកសាសន៍របស់ខ្លួន ហើយបើមានជនក្រៅពីសាមីខ្លួនបានសរសេរត្រូវធ្វើសេចក្តីថ្លែងការណ៍អំពីឈ្មោះ និងលំនៅឋានរបស់ជនដែលបានសរសេរនោះ។
- សារការីត្រូវចុះថ្ងៃខែឆ្នាំដែលសាមីខ្លួនបានដាក់លិខិតនោះ និងសរសេរសេចក្តីថ្លែងការណ៍របស់ម្ចាស់បណ្តាំនៅលើលិខិតដែលបិទជិតនោះ ហើយត្រូវចុះហត្ថលេខាលើលិខិតនោះជាមួយគ្នានឹងសាក្សី និងម្ចាស់បណ្តាំ។[15]

### **១.២. អនុប្បទានតាមរយៈកិច្ចសន្យា**

ក្នុងការបង្កើតកិច្ចសន្យាគេអាចធ្វើឡើងបានតាមពីររបៀបដូចជាការធ្វើកិច្ចសន្យាដោយផ្ទាល់មាត់ និងការធ្វើកិច្ចសន្យាជាលាយល័ក្ខណ៍អក្សរ។ ប៉ុន្តែក្នុងការផ្ទេរបេតិកភណ្ឌពាណិជ្ជកម្មត្រូវធ្វើឡើងជាលាយល័ក្ខណ៍អក្សរដាច់ខាតពីព្រោះការកែប្រែ ឬការផ្ទេរកម្មសិទ្ធិក្រុមហ៊ុនមួយបានតម្រូវឱ្យមានចុះក្នុងបញ្ជីក្រុមហ៊ុន។[16] ការធ្វើកិច្ចសន្យាគឺជាទម្រង់ដែលចាំបាច់ក្នុងការផ្ទេរបេតិកភណ្ឌពាណិជ្ជកម្ម ត្រូវប្រើប្រាស់ក្នុងករណីដែលអនុប្បទាយីកំពុងស្ថិតនៅក្នុងស្ថានភាពរស់នៅធម្មតា ហើយអនុប្បទាយីមានសិទ្ធិក្នុងការបែងចែកបេតិកភណ្ឌរបស់ខ្លួនទៅតាមរយៈ **១.** លក្ខខណ្ឌនៃការបង្កើតកិច្ចសន្យា និង **២.** ទម្រង់នៃការបង្កើតកិច្ចសន្យា។

[15] មាត្រា ១១៧៥ ក្រមរដ្ឋប្បវេណីព្រះរាជាណាចក្រកម្ពុជា ឆ្នាំ ២០០៧។

[16] មាត្រា ១៧ ថ្មី នៃច្បាប់ស្តីពីវិធានពាណិជ្ជកម្ម និងបញ្ជីពាណិជ្ជកម្ម ២៦ មិថុនា ១៩៩៥។

### ១.២.១. លក្ខខណ្ឌគ្រឹះនៃការបង្កើតកិច្ចសន្យា

កិច្ចសន្យា គឺជាការព្រមព្រៀងរវាងបុគ្គលពីរនាក់ ឬច្រើននាក់បានបង្ហាញឆន្ទៈត្រូវគ្នាព្រមបង្កើត កែប្រែ ឬរំលត់នូវសិទ្ធិ និងកាតព្វកិច្ច។[17] កិច្ចសន្យាអាចធ្វើដោយផ្ទាល់មាត់ក៏បាន និងធ្វើជាលាយលក្ខណ៍អក្សរក៏បាន ប៉ុន្តែប្រសិនបើអោយកិច្ចសន្យាមួយមានអានុភាពតាមផ្លូវច្បាប់លុះត្រាតែ អនុប្បទាយី និងអនុប្បទានិកគោរពនូវលក្ខខណ្ឌនៃការបង្កើតកិច្ចសន្យា ដែលតម្រូវឱ្យធ្វើជាលិខិតលាយលក្ខណ៍អក្សរដោយសំណើ និងស្វីការត្រូវគ្នា។[18] ដើម្បីឱ្យកិច្ចសន្យាមានសុពលភាពទៅតាមផ្លូវច្បាប់ យើងត្រូវគោរពនូវលក្ខខណ្ឌសុពលភាពនៃកិច្ចសន្យាបន្ថែមទៀតពោលគឺ **១.** សមត្ថភាពអនុប្បទាយី និងអនុប្បទានិក **២.** ការព្រមព្រៀងអនុប្បទាយី និង **៣.** អនុប្បទានិក និងកម្មវត្ថុនៃមូលនិធិពាណិជ្ជកម្ម។

#### ១.២.១.១. សមត្ថភាពអនុប្បទាយី និងអនុប្បទានិក

សមត្ថភាពអនុប្បទាយី និងអនុប្បទានិក គឺជាលក្ខខណ្ឌសំខាន់ណាស់ក្នុងការបង្កើតកិច្ចសន្យាឱ្យមានអានុភាពបានក្នុងនោះរួមមានសមត្ថភាពទទួលសិទ្ធិ[19] សមត្ថភាពខាងឆន្ទៈ[20] និងសមត្ថភាពក្នុងការធ្វើសកម្មភាព[21]។ ការកំណត់សមត្ថភាពអនុប្បទាយី និងអនុប្បទានិកបែបនេះ គឺដើម្បីការពារនូវផលប្រយោជន៍បុគ្គលដែលមិនទាន់មានសមត្ថភាពគ្រប់គ្រាន់ក្នុងការបង្ហាញឆន្ទៈ និងមិនទាន់មានការយល់ដឹងអំពីអានុភាពតាមផ្លូវច្បាប់របស់ខ្លួននៅក្នុងការចុះកិច្ចសន្យា។

#### ១.២.១.២. ការព្រមព្រៀងអនុប្បទាយី និងអនុប្បទានិក

មុននឹងឈានដល់ការបង្កើតកិច្ចសន្យាមូលនិធិពាណិជ្ជកម្មមួយបាន លុះត្រាតែមានការព្រមព្រៀងគ្នាទៅវិញទៅមករវាងអនុប្បទាយី និងអនុប្បទានិកនៃកិច្ចសន្យា។ ដើម្បីសម្រេចបាននូវការព្រមព្រៀងគ្នាអនុប្បទាយី និងអនុប្បទានិក ត្រូវធ្វើការបង្ហាញឆន្ទៈទៅលើកម្មវត្ថុនៃកិច្ចសន្យាមូលនិធិពាណិជ្ជកម្មដែលបង្កើតឱ្យមានសំណើ និងស្វីការ។[22]

[17] មាត្រា ៣១១ ក្រមរដ្ឋប្បវេណីព្រះរាជាណាចក្រកម្ពុជា ០៨ ធ្នូ ២០០៧។

[18] មាត្រា ៣៣៦ ក្រមរដ្ឋប្បវេណីព្រះរាជាណាចក្រកម្ពុជា ០៨ ធ្នូ ២០០៧។

[19] មាត្រា ៦ ក្រមរដ្ឋប្បវេណីព្រះរាជាណាចក្រកម្ពុជា ០៨ ធ្នូ ២០០៧។

[20] មាត្រា ១៤ ក្រមរដ្ឋប្បវេណីព្រះរាជាណាចក្រកម្ពុជា ០៨ ធ្នូ ២០០៧។

[21] មាត្រា ១៥ ក្រមរដ្ឋប្បវេណីព្រះរាជាណាចក្រកម្ពុជា ០៨ ធ្នូ ២០០៧។

[22] មាត្រា ៣៣៧ ក្រមរដ្ឋប្បវេណីព្រះរាជាណាចក្រកម្ពុជា ០៨ ធ្នូ ២០០៧។

នៅក្នុងកិច្ចសន្យាមូលនិធិពាណិជ្ជកម្ម អនុប្បាទាយី និងអនុប្បទានិក បានចចារគ្នាលើកម្មវត្ថុនៃកិច្ចសន្យានោះ ដែលបានបង្កើតចេញជាកិច្ចសន្យាមួយច្បាស់លាស់ហើយស្របទៅ និងលក្ខខណ្ឌនៃការបង្កើតកិច្ចសន្យា។

### ១.២.១.៣. កម្មវត្ថុនៃមូលនិធិពាណិជ្ជកម្ម

រាល់កិច្ចសន្យាមូលនិធិពាណិជ្ជកម្ម ចាំបាច់ណាស់ត្រូវតែមានកម្មវត្ថុចំពោះការផ្ទេរសិទ្ធិ ឬចាត់ចែងទ្រព្យសម្បត្តិបន្តបន្ទាប់ពីមានការផ្ទេរពីអនុប្បទាយី ឱ្យទៅអនុប្បទានិក។ ដែលកម្មវត្ថុនៃកិច្ចសន្យាពាណិជ្ជកម្មនោះរួមមាន៖ ម៉ាកពាណិជ្ជកម្ម គំនូរឧស្សាហកម្ម ពាណិជ្ជនាម កេរ្តិ៍ឈ្មោះ អតិថិជន រូបមន្តក្រុមហ៊ុន ប្លង់ គម្រោងផលិតកម្ម ការព្យាករណ៍ ស្ថានភាពទីផ្សារ យុទ្ធសាស្ត្រពាណិជ្ជកម្ម បញ្ជីឈ្មោះអតិថិជន ទិន្នន័យទាក់ទង និងការលក់ ឯកសារគណនេយ្យ ការប្រមូលផ្តុំឯកសារវិធីសាស្ត្រ បច្ចេកទេស ដំណើរការផលិត ផលិតកម្ម កម្មវិធីកុំព្យូទ័រ វិធីសាស្ត្រពាណិជ្ជកម្ម ប្រភពផ្គត់ផ្គង់ ចំណូលចំណាយ កម្មវត្ថុច្បាស់លាស់និងតម្លៃ ព្រមទាំងកំណត់ឱ្យបានច្បាស់លាស់នូវអត្តសញ្ញាណ និងអាសយដ្ឋានរបស់កម្មវត្ថុនៃមូលនិធិពាណិជ្ជកម្ម។ រាល់កម្មវត្ថុទាំងអស់នេះហើយ ជាចំណុចចម្បងក្នុងការផ្ទេរមូលនិធិពាណិជ្ជកម្ម ដែលធ្វើឱ្យអនុប្បទានិក មានការទទួលដឹងច្បាស់ថាខ្លួនអាចមានសិទ្ធិនិង អានុភាពបន្ទាប់ពីមានការផ្ទេរ។ កម្មវត្ថុនេះផងដែរជាកត្តាយ៉ាងសំខាន់សម្រាប់យកទៅតតាំងនៅពេលមានការបំពានបាននៅថ្ងៃក្រោយ ផ្ទុយទៅវិញដល់ថ្ងៃចុះកិច្ចសន្យាប្រគល់វត្ថុក្នុងករណីដែលអនុប្បទាយីមិនបានផ្តល់កម្មវត្ថុ ឬគ្មានវត្ថុតាមការព្រមព្រៀងនៃកិច្ចសន្យាដែលបានបង្កើតឡើងទេនោះ អនុប្បទានិកមានសិទ្ធិលុបចោលកិច្ចសន្យា[23] ប្រសិនបើអនុប្បទាយីមិនអនុវត្តកាតព្វកិច្ច។ ចំពោះការលុបចោលនេះផងដែលអនុប្បទានិកត្រូវគោរពតាមអាជ្ញាយុកាលនៃការរំលត់សិទ្ធិលុបចោល ប្រសិនបើអ្នកមានសិទ្ធិលុបចោលមិនអនុវត្តសិទ្ធិនោះក្នុងរយៈពេល ៣ (បី) ឆ្នាំ ចាប់តាំងពីពេលដែលខ្លួនក្លាយទៅជាអ្នកដែលអាចផ្តល់សច្ចានុមតិ នោះសិទ្ធិលុបចោល និងសិទ្ធិទាមទារឱ្យសងសេចក្តីចម្រើនដោយឥតហេតុដែលកើតឡើង ដោយសារការលុបចោលនោះត្រូវរលត់។[24]

### ១.២.២. លក្ខខណ្ឌទម្រង់នៃការបង្កើតកិច្ចសន្យា

នៅក្នុងនីតិវិធីនៃការផ្ទេរបេតិកភណ្ឌពាណិជ្ជកម្ម អនុប្បទាយីអាចធ្វើការផ្ទេរបេតិកភណ្ឌពាណិជ្ជកម្មរបស់ខ្លួនបានតាមរយៈការបង្កើតកិច្ចសន្យា។ ការបង្កើតកិច្ចសន្យានៅក្នុងការផ្ទេរបេតិកភណ្ឌពាណិជ្ជកម្មអនុប្បទាយី

[23] មាត្រា ៣៥៨ ក្រមរដ្ឋប្បវេណីព្រះរាជាណាចក្រកម្ពុជា ០៨ ធ្នូ ២០០៧។

[24] មាត្រា ៣៦៣ ក្រមរដ្ឋប្បវេណីព្រះរាជាណាចក្រកម្ពុជា ០៨ ធ្នូ ២០០៧។

ចាំបាច់ត្រូវធ្វើឡើងដោយលាយល័ក្ខណ៍អក្សរ ដែលត្រូវគោរពតាម ទម្រង់លិខិតឯកជន ឬលិខិតយថាភូតដែល លិខិតទាំងពីរនេះត្រូវមានការចុះនូវកម្មវត្ថុនៃ កម្មសិទ្ធិ ការផ្ទេរ ឬកែប្រែបញ្ជីនៅក្រសួងពាណិជ្ជកម្ម។[25]

## ផ្នែកទី២៖ ការធ្វើអនុប្បទានក្រុមហ៊ុនពាណិជ្ជកម្ម

ការធ្វើអនុប្បទានក្រុមហ៊ុនពាណិជ្ជកម្ម គឺជាការផ្ទេរសិទ្ធិ កាតព្វកិច្ច និងទ្រព្យសម្បត្តិមួយផ្នែក ឬទាំងស្រុង នៃក្រុមហ៊ុនពាណិជ្ជកម្ម របស់បុគ្គលណាម្នាក់ដែលជាអនុប្បទាយីទៅឱ្យបុគ្គលម្នាក់ទៀតដែលជាអនុប្បទានិក។ ហើយការធ្វើអនុប្បទានក្រុមហ៊ុនពាណិជ្ជកម្ម អនុប្បទាយីមានសិទ្ធិផ្ទេរភាគហ៊ុន ឬបញ្ចូលក្រុមហ៊ុនទៅឱ្យអនុប្ប-ទានិក ១. ចូលភាគហ៊ុន និង ២. បញ្ចូលក្រុមហ៊ុន។

### ២.១. ចូលភាគហ៊ុន

មុននឹងឈានទៅដល់ការបង្កើតក្រុមហ៊ុនមួយបានត្រូវមានការចូលរួមពីសំណាក់នីតិបុគ្គល និងរូបវន្តបុគ្គល ដើម្បីធ្វើការដឹកនាំព្រមទាំងមានការចូលរួម ដើម្បីធ្វើឱ្យក្រុមហ៊ុននោះមានភាពត្រឹមត្រូវសមស្របទៅតាមច្បាប់ លក្ខន្តិកៈនៃការចូលភាគហ៊ុន របស់ក្រុមហ៊ុននីមួយៗ និងសិទ្ធិរបស់ម្ចាស់ភាគហ៊ុន។

#### ២.១.១. លក្ខន្តិកៈនៃការចូលភាគហ៊ុន

ភាគហ៊ុននីមួយៗ ត្រូវមានការចុះក្នុងបញ្ជីទៅតាមបែបបទដែលបានកំណត់។ ភាគហ៊ុននីមួយៗ ត្រូវមានតម្លៃចារឹកលើប័ណ្ណ ហើយក្រុមហ៊ុនមិនត្រូវចេញប័ណ្ណភាគហ៊ុនណា មួយដែលមានតម្លៃតិចជាង តម្លៃចារឹកលើប័ណ្ណនោះទេ។[26] ក្នុងន័យនេះភាគហ៊ុនដែលអាចលក់បានត្រូវតែមានការចុះក្នុងបញ្ជី និងតម្លៃចារឹកត្រឹមត្រូវតាមលក្ខន្តិកៈដែលបានកំណត់។ ប្រសិនជាក្រុមហ៊ុនមិនបានចែងនូវចំនួន និងតម្លៃនៃប័ណ្ណភាគហ៊ុនដែលក្រុមហ៊ុនត្រូវបោះលក់ចេញនោះទេ ក្រុមហ៊ុនត្រូវបោះលក់ចេញយ៉ាងតិចបំផុតមួយពាន់ភាគហ៊ុន ដែលមានតម្លៃចារឹកលើប័ណ្ណមិនតិចជាងបួនពាន់រៀលក្នុងមួយហ៊ុនៗ។ ក្នុងករណីលក្ខន្តិកៈរបស់ក្រុមហ៊ុន មិនបានបញ្ជាក់នូវប្រភេទនៃភាគហ៊ុនទេនោះ ក្រុមហ៊ុនត្រូវមានប្រភេទភាគហ៊ុនតែមួយប៉ុណ្ណោះ។[27] ប៉ុន្តែលក្ខន្តិកៈរបស់ក្រុមហ៊ុន អាចបែងចែកឱ្យមានប័ណ្ណភាគហ៊ុនច្រើនជាងមួយប្រភេទក្នុងករណីដែលប្រភេទភាគហ៊ុននីមួយៗ អាចមានលក្ខណៈដាច់ខាត ឬលក្ខណៈធៀប។ ប្រភេទនៃប័ណ្ណភាគហ៊ុនត្រូវបានបែងចែកជាច្រើនប្រភេទទៅតាមតម្រូវការ និងប្រភេទនៃក្រុមហ៊ុននីមួយៗ ប័ណ្ណភាគហ៊ុនត្រូវបានគេបែងចែកជា ៥ ប្រភេទដូចជា៖ Blue Chip, Penny, Defensive, Cyclical និង Growth។

---

[25] មាត្រា ១៤ នៃច្បាប់ស្តីពីវិធានពាណិជ្ជកម្ម និងបញ្ជីពាណិជ្ជកម្ម ០៥ វិច្ឆិកា ឆ្នាំ១៩៩៥។

[26] មាត្រា ១៤៣ នៃច្បាប់ស្តីពីសហគ្រាសពាណិជ្ជកម្ម ១៥ កក្កដា ២០០៥។

[27] មាត្រា ១៤៤ នៃច្បាប់ស្តីពីវិសោធនកម្មច្បាប់ស្តីពីសហគ្រាសពាណិជ្ជកម្មសហគ្រាសពាណិជ្ជកម្ម ០៦ មករា ២០២២។

**២.១.២. សិទ្ធិនៃម្ចាស់ភាគហ៊ុន**

ម្ចាស់ភាគហ៊ុនមានសិទ្ធិជាច្រើន ក្នុងនាមជាអ្នកវិនិយោគនៅក្នុងក្រុមហ៊ុនពាណិជ្ជកម្មមួយ ឬច្រើនក្នុងនោះរួមមាន ១. សិទ្ធិគ្រប់គ្រង ២. សិទ្ធិខាងសេដ្ឋកិច្ច ៣. សិទ្ធិទទួលបានព័ត៌មាន និង ៤. សិទ្ធិធ្វើបណ្ដឹង។

**២.១.២.១. សិទ្ធិគ្រប់គ្រង**

សិទ្ធិគ្រប់គ្រងក្រុមហ៊ុន ត្រូវភ្ជាប់មកជាមួយសិទ្ធិកម្មសិទ្ធិដើម្បីសម្គាល់ដែនកំណត់នៃសិទ្ធិគ្រប់គ្រង និងប្រៀបធៀបនឹងការគ្រប់គ្រងអចលនទ្រព្យ និងកម្មសិទ្ធិលើចលនទ្រព្យ។ ទាក់ទងនឹងបញ្ហាក្រុមហ៊ុនវិញ ម្ចាស់-ភាគហ៊ុនមានសិទ្ធិកម្មសិទ្ធិលើក្រុមហ៊ុន តាមចំណែកភាគហ៊ុនដែលខ្លួនមាន មិនថាម្ចាស់ភាគហ៊ុននោះធំ ឬតូចប៉ុណ្ណាទេ។ ម្ចាស់ភាគហ៊ុនមានសិទ្ធិគ្រប់គ្រងក្រុមហ៊ុនបាន ដោយម្ចាស់ភាគហ៊ុនមានសិទ្ធិក្នុងការដកហូតមុខតំណែងរបស់អភិបាលក្រុមហ៊ុនបាន ដោយសំឡេងភាគច្រើនដាច់ខាតនៃម្ចាស់ភាគហ៊ុនដែលមានសិទ្ធិបោះ-ឆ្នោតទោះជាមាន ឬគ្មានមូលហេតុក៏ដោយ។[28]

**២.១.២.២. សិទ្ធិសេដ្ឋកិច្ច**

ភាគហ៊ុនត្រូវបានគេចាត់ទុកដូចជាទ្រព្យបុគ្គលដូច្នោះដែរ ដែលគេអាចទាញយកប្រយោជន៍ ទទួលភាគ-លាភ និងប្រែក្លាយវាឱ្យទៅជាប្រយោជន៍ជាប្រាក់កាស។ ដូច្នេះសិទ្ធិសេដ្ឋកិច្ច រួមមានសិទ្ធិទទួលបានភាគលាភ និងសិទ្ធិលក់ភាគហ៊ុន។ សិទ្ធិសេដ្ឋកិច្ចមានទំនាក់ទំនងជាមួយសិទ្ធិគ្រប់គ្រងនៅពេលដែលម្ចាស់ភាគហ៊ុនបានតែងតាំងអភិបាល ដើម្បីឱ្យគ្រប់គ្រងធុរៈកិច្ចជំនួសខ្លួន ហើយការគ្រប់គ្រងធុរៈកិច្ចនោះ បានជាប្រយោជន៍សេដ្ឋកិច្ចដល់ម្ចាស់ភាគហ៊ុន។

**២.១.២.៣. សិទ្ធិទទួលបានព័ត៌មាន**

ម្ចាស់ភាគហ៊ុនមានសិទ្ធិទទួលបានរបាយការណ៍ហិរញ្ញវត្ថុនានា របាយការណ៍របស់សវនករ និងព័ត៌មានផ្សេងៗទៀតពាក់ព័ន្ធនឹងស្ថានភាពហិរញ្ញវត្ថុរបស់ក្រុមហ៊ុន និងលទ្ធផលដែលទទួលបានពីប្រតិបត្តិការរបស់ក្រុមហ៊ុនដែលត្រូវផ្តល់ជូនដោយអភិបាលនៅពេលប្រជុំសន្និបាតប្រចាំឆ្នាំនៃម្ចាស់ភាគហ៊ុន។[29]

**២.១.២.៤. សិទ្ធិធ្វើបណ្ដឹង**

ម្ចាស់ភាគហ៊ុនមានសិទ្ធិក្នុងការធ្វើបណ្ដឹង ឬធ្វើអន្តរាគមន៍ក្នុងនាមជាម្ចាស់ភាគហ៊ុនទៅកាន់តុលាការបាន តាមរយៈបណ្ដឹងជំនួសមុខបាន។[30] បណ្ដឹងជំនួសមុខមិនអាចដកមកដោះស្រាយផ្ទៃក្នុងក្រុមហ៊ុនវិញទេ បើ

---

[28] មាត្រា ១២៤ នៃច្បាប់ស្តីពីសហគ្រាសពាណិជ្ជកម្ម ១៥ កក្កដា ២០០៥។

[29] មាត្រា ២២៤ នៃច្បាប់ស្តីពីសហគ្រាសពាណិជ្ជកម្ម ១៥ កក្កដា ២០០៥។

[30] មាត្រា ២៨៧ នៃច្បាប់ស្តីពីសហគ្រាសពាណិជ្ជកម្ម ១៥ កក្កដា ២០០៥។

គ្មានការព្រមព្រៀងពីតុលាការ[31] ប្រាក់សំណងពីការឈ្នះនៃបណ្តឹង ត្រូវបានជាទ្រព្យសម្បត្តិរបស់ក្រុមហ៊ុន និងសិទ្ធិពិសេសក្នុងការទាមទារឱ្យតុលាការសម្រេចផ្តល់សំណងឱ្យខ្លួនសមស្រប[32]។

## ២.២. បញ្ចូលក្រុមហ៊ុនពាណិជ្ជកម្ម

ការបញ្ចូលក្រុមហ៊ុន ឬការរំលាយបញ្ចូលក្រុមហ៊ុន គឺជាការរំលាយបញ្ចូលក្រុមហ៊ុនពីរ ឬច្រើនបញ្ចូលគ្នាជាក្រុមហ៊ុនតែមួយ ឬអាចបង្រួបបង្រួមចូលគ្នាជាក្រុមហ៊ុនថ្មីមួយផ្សេងទៀតបាន។ ក្រុមហ៊ុនដែលរំលាយហៅថាក្រុមហ៊ុនដើម ចំណែកឯក្រុមហ៊ុនដែលទទួលបន្ទុកធ្វើអាជីវកម្មតទៅទៀត ហៅថាក្រុមហ៊ុនថ្មី។[33] ដើម្បីអាចបញ្ចូលក្រុមហ៊ុនចូលគ្នាតែមួយបាន យើងគួរគប្បីត្រូវគោរពនូវលក្ខខណ្ឌនៃការរំលាយបញ្ចូលក្រុមហ៊ុន និងត្រូវមានវិញ្ញាបនបត្របញ្ជាក់អំពីការរំលាយក្រុមហ៊ុនជាមុនសិន។

### ២.២.១. លក្ខខណ្ឌនៃការរំលាយបញ្ចូលក្រុមហ៊ុន

មូលហេតុដែលនាំឱ្យមានការរំលាយបញ្ចូលក្រុមហ៊ុន គឺបណ្តាលមកពីការធ្វើអាជីវកម្មរបស់ក្រុមហ៊ុនត្រូវបានបញ្ចប់ គ្មានលទ្ធភាពក្នុងការធ្វើអាជីវកម្មបន្ត និងគោរពតាមការព្រមព្រៀងជាឯកច្ឆ័នរបស់សហកម្មសិទ្ធិករទូទៅ។[34] ក្រុមហ៊ុនដែលគ្មានចេញប័ណ្ណភាគហ៊ុនណាមួយទេ អាចធ្វើការរំលាយនៅពេលណាក៏បាន តាមរយៈសេចក្តីសម្រេចរបស់អភិបាលទាំងអស់។[35] ចំណែកក្រុមហ៊ុនគ្មានទ្រព្យសម្បត្តិ និងគ្មានបំណុល អាចធ្វើការរំលាយបានតាមរយៈសេចក្តីសម្រេចពិសេសរបស់ម្ចាស់ហ៊ុន ឬប្រសិនបើក្រុមហ៊ុនមានចេញប័ណ្ណភាគហ៊ុនច្រើនជាងមួយប្រភេទនោះ ការរំលាយក្រុមហ៊ុនអាចធ្វើទៅបានតាមរយៈសេចក្តីសម្រេចពិសេសរបស់អ្នកកាន់កាប់ភាគហ៊ុននៃប្រភេទភាគហ៊ុននីមួយៗ ទោះបីម្ចាស់ភាគហ៊ុននោះមានសិទ្ធិ ឬគ្មានសិទ្ធិបោះឆ្នោតក៏ដោយ។[36] ដើម្បីអាចធ្វើការរំលាយបញ្ចូលក្រុមហ៊ុនរួមគ្នាតែមួយបានត្រូវមានកិច្ចព្រមព្រៀងនៃការរំលាយក្រុមហ៊ុនបញ្ចូលគ្នាព្រមទាំងភ្ជាប់មកជាមួយនូវកម្រងឯកសារដែលត្រូវតម្កល់ទុកនៅក្រសួងពាណិជ្ជកម្ម។

[31] មាត្រា ២៨៧ កថាខណ្ឌទី៦ នៃច្បាប់ស្តីពីសហគ្រាសពាណិជ្ជកម្ម ១៥ កក្កដា ២០០៥។

[32] មាត្រា ២៨៨ នៃច្បាប់ស្តីពីសហគ្រាសពាណិជ្ជកម្ម ១៥ កក្កដា ២០០៥។

[33] មាត្រា ២៤១ នៃច្បាប់ស្តីពីសហគ្រាសពាណិជ្ជកម្ម ១៥ កក្កដា ២០០៥។

[34] មាត្រា ៥៣ នៃច្បាប់ស្តីពីសហគ្រាសពាណិជ្ជកម្ម ១៥ កក្កដា ២០០៥។

[35] មាត្រា ២៥១ កថាខណ្ឌទី១ នៃច្បាប់ស្តីពីសហគ្រាសពាណិជ្ជកម្ម ១៥ កក្កដា ២០០៥។

[36] មាត្រា ២៥១ កថាខណ្ឌទី២ នៃច្បាប់ស្តីពីសហគ្រាសពាណិជ្ជកម្ម ១៥ កក្កដា ២០០៥។

### ២.២.១.១. កិច្ចព្រមព្រៀងនៃការរំលាយក្រុមហ៊ុនបញ្ចូលគ្នា

មុននឹងឈានទៅដល់ការរំលាយក្រុមហ៊ុនបញ្ចូលគ្នាបានលុះត្រាតែ ក្រុមប្រឹក្សាភិបាលរបស់ក្រុមហ៊ុននីមួយៗ ដែលស្នើរំលាយក្រុមហ៊ុនបញ្ចូលគ្នា ត្រូវអនុម័តនូវសេចក្ដីសម្រេចយល់ព្រមលើកិច្ចព្រមព្រៀងនៃការរំលាយបញ្ចូលគ្នាជាមុនសិន។ លើកលែងតែក្នុងករណីដែលមានចែងផ្សេងក្នុងលក្ខន្តិកៈការអនុម័តនេះត្រូវផ្អែកលើចំនួនភាគច្រើនដាច់ខាតនៃអភិបាលទាំងអស់។[37]

កិច្ចព្រមព្រៀងនៃការរំលាយក្រុមហ៊ុនបញ្ចូលគ្នាត្រូវចែងពី៖

- ចំណុចសំខាន់ៗនិងលក្ខខណ្ឌនៃការរំលាយក្រុមហ៊ុនបញ្ចូលគ្នា។
- លក្ខន្តិកៈរបស់ក្រុមហ៊ុនថ្មីដែលទទួលបន្ទុកបន្តធ្វើអាជីវកម្ម។
- បែបបទនៃការផ្លាស់ប្ដូរភាគហ៊ុននៃប្រភេទនីមួយៗរបស់ក្រុមហ៊ុនដើមឱ្យទៅជាភាគហ៊ុន ឬមូលបត្រផ្សេងៗរបស់ក្រុមហ៊ុនថ្មី ដែលទទួលបន្ទុកបន្តអាជីវកម្ម។
- របាយការណ៍ស្ដីពីសាច់ប្រាក់ សិទ្ធិ មូលបត្រ ឬកម្មសិទ្ធិផ្សេងៗទៀត ដែលអ្នកកាន់កាប់ភាគហ៊ុនត្រូវទទួលក្នុងការរំលាយក្រុមហ៊ុនបញ្ចូលគ្នា ប្រសិនបើភាគហ៊ុនណាមួយរបស់ក្រុមហ៊ុនដើមមិនត្រូវប្ដូរទៅជាភាគហ៊ុនរបស់ក្រុមហ៊ុនថ្មី ដែលទទួលបន្ទុកបន្តអាជីវកម្មនោះទេ។
- ព័ត៌មានដទៃទៀតដែលម្ចាស់ហ៊ុនក្នុងប្រភេទនីមួយៗចង់ដឹង ដើម្បីជាមូលដ្ឋានធ្វើការសម្រេចចិត្តក្នុងការបោះឆ្នោតលើការរំលាយក្រុមហ៊ុនបញ្ចូលគ្នា។
- ព័ត៌មានលម្អិតនៃកិច្ចសម្របសម្រួលចាំបាច់ ដើម្បីធ្វើឱ្យប្រសើរឡើង និងដើម្បីផ្ដល់ដល់ការគ្រប់គ្រង ព្រមទាំងប្រតិបត្តិការនាពេលបន្ទាប់នៃក្រុមហ៊ុនថ្មី ដែលទទួលបន្ទុកបន្តអាជីវកម្ម។[38]

ក្រោយពីបានទទួលនូវសេចក្ដីសម្រេចពីក្រុមប្រឹក្សាភិបាលដើមនីមួយៗរួចមក ម្ចាស់ក្រុមហ៊ុនថ្មីត្រូវជូនដំណឹងទៅឱ្យម្ចាស់ហ៊ុនទាំងអស់ស្ដីពីកិច្ចប្រជុំម្ចាស់ហ៊ុន ដែលមានសិទ្ធិបោះឆ្នោតនូវព័ត៌មានដូចតទៅ៖

- នៅក្នុងរយៈពេល ៣០ (សាមសិប) ថ្ងៃ ក្រោយកិច្ចព្រមព្រៀងនេះ ក្រុមប្រឹក្សាភិបាលនៃក្រុមហ៊ុនដើមនីមួយៗត្រូវធ្វើមហាសន្និបាតម្ចាស់ហ៊ុន ដើម្បីបោះឆ្នោតសម្រេចលើកិច្ចព្រមព្រៀងស្ដីពីការរំលាយក្រុមហ៊ុនបញ្ចូលគ្នា។
- លិខិតជូនដំណឹងត្រូវភ្ជាប់ជាមួយនឹងច្បាប់ចម្លងនៃកិច្ចព្រមព្រៀង ស្ដីពីការរំលាយក្រុមហ៊ុនបញ្ចូលគ្នា។

---

[37] មាត្រា ២៤២ នៃច្បាប់ស្ដីពីសហគ្រាសពាណិជ្ជកម្ម ១៥ កក្កដា ២០០៥។

[38] មាត្រា ២៤៣ នៃច្បាប់ស្ដីពីសហគ្រាសពាណិជ្ជកម្ម ១៥ កក្កដា ២០០៥។

- ក្រុមហ៊ុនដើមនីមួយៗត្រូវផ្តល់លិខិតជូនដំណឹងស្តីពីកិច្ចប្រជុំម្ចាស់ហ៊ុនយ៉ាងតិច ២០ (ម្ភៃ) ថ្ងៃមុន។[39] ការរំលាយក្រុមហ៊ុនបញ្ចូលគ្នាត្រូវមានការយល់ព្រម ដោយសេចក្តីសម្រេចពិសេសរបស់ម្ចាស់ហ៊ុនពីរភាគបី (២/៣) នៃក្រុមហ៊ុននីមួយៗ។[40] ទោះបីលក្ខន្តិកៈរបស់ក្រុមហ៊ុនមិនអនុញ្ញាតឱ្យប្រភេទភាគហ៊ុនណាមួយមានសិទ្ធិជាទូទៅក្នុងការបោះឆ្នោតក៏ដោយ ក៏ប្រភេទភាគហ៊ុននោះនឹងនៅតែមានសិទ្ធិដោយឡែកក្នុងការបោះឆ្នោតទៅតាមប្រភេទភាគហ៊ុនរបស់ខ្លួន ដើម្បីសម្រេចលើការរំលាយក្រុមហ៊ុនបញ្ចូលគ្នាដែលអាចនឹងកែប្រែដោយផ្ទាល់ និងដោយប្រយោលនូវ សិទ្ធិ ឯកសិទ្ធិ ការរឹតត្បិត និងលក្ខខណ្ឌនៃប្រភេទ ឬសេរីនៃភាគហ៊ុនផ្សេងៗ។ អំណាចបោះឆ្នោតដែលបង្កើតឡើងក្នុងមាត្រានេះមិនអាចបដិសេធ ឬកែប្រែដោយលក្ខន្តិកៈរបស់ក្រុមហ៊ុន ឬតាមរបៀបណាផ្សេងទៀតបានឡើយ។[41]

### ២.២.១.២. កម្រងឯកសារដែលត្រូវតម្កល់ទុក

អភិបាលរបស់ក្រុមហ៊ុនថ្មី ដែលទទួលធ្វើអាជីវកម្មបន្ត ត្រូវតម្កល់ឯកសារទុកនៅក្រសួងពាណិជ្ជកម្មដែលមានជាអាទិ៍៖

- កិច្ចព្រមព្រៀងស្តីពីការរំលាយក្រុមហ៊ុនបញ្ចូលគ្នា ។
- សេចក្តីសម្រេចយល់ព្រមលើកិច្ចព្រមព្រៀង ស្តីពីការរំលាយក្រុមហ៊ុនបញ្ចូលគ្នានៃអង្គប្រជុំរបស់ក្រុមប្រឹក្សាភិបាល និងនៃមហាសន្និបាតម្ចាស់ហ៊ុនរបស់ក្រុមហ៊ុនដើមនីមួយៗ។
- លក្ខន្តិកៈរបស់ ក្រុមហ៊ុនថ្មីដែលទទួលធ្វើអាជីវកម្មបន្ត ។
- សេចក្តីប្រកាសរបស់អភិបាល ឬអ្នកគ្រប់គ្រងនៃក្រុមហ៊ុនដើមនីមួយៗ ដែលធ្វើឡើងតាមការទាមទារពីមន្ត្រីទទួលបន្ទុកគ្រប់គ្រងក្រុមហ៊ុននៃក្រសួងពាណិជ្ជកម្ម។ សេចក្តីប្រកាសនោះត្រូវមានមូលហេតុសមរម្យដូចតទៅ :
    - ➢ ក្រុមហ៊ុនដើម និងក្រុមហ៊ុនថ្មីដែលទទួលធ្វើអាជីវកម្មបន្តនីមួយៗគឺមាន លទ្ធភាពសងបំណុលរបស់ខ្លួន តាមពេលវេលាដែលត្រូវសង។
    - ➢ ធនធានសរុបរបស់ក្រុមហ៊ុនថ្មី ដែលទទួលធ្វើអាជីវកម្មបន្ត មិនត្រូវតិចជាងចំនួនសរុបនៃបំណុលដែលខ្លួនជំពាក់ និងដើមទុនចុះបញ្ជីនៃក្រុមហ៊ុនដើម។

---

[39] មាត្រា ២៤៤ នៃច្បាប់ស្តីពីសហគ្រាសពាណិជ្ជកម្ម ១៥ កក្កដា ២០០៥។

[40] មាត្រា ២៤៥ នៃច្បាប់ស្តីពីសហគ្រាសពាណិជ្ជកម្ម ១៥ កក្កដា ២០០៥។

[41] មាត្រា ២៤៦ នៃច្បាប់ស្តីពីសហគ្រាសពាណិជ្ជកម្ម ១៥ កក្កដា ២០០៥។

- ➢ គ្មានម្ចាស់បំណុលណាមួយទទួលការខូចខាត ដោយសារការរំលាយក្រុមហ៊ុនបញ្ចូលគ្នានេះទេ ។
- ➢ លិខិតជូនដំណឹងជាលាយល័ក្ខណ៍អក្សរ ត្រូវបានប្រគល់ឱ្យម្ចាស់បំណុល ទាំងអស់របស់ក្រុមហ៊ុនដើម ហើយគ្មានម្ចាស់បំណុលណាមួយធ្វើការជំទាស់ដែលមាន មូលហេតុស្របទៅលើការរំលាយបញ្ចូលគ្នានោះទេ ។[42]

### ២.២.២. ការផ្តល់វិញ្ញាបនបត្របញ្ជាក់ពីការរំលាយក្រុមហ៊ុន

នៅពេលដែលក្រសួងពាណិជ្ជកម្មទទួលបាននូវលក្ខន្តិកៈ ស្តីពីការរំលាយក្រុមហ៊ុនបញ្ចូលគ្នារួចមក ក្រសួងពាណិជ្ជកម្មត្រូវចេញវិញ្ញាបនបត្របញ្ជាក់ពីការរំលាយក្រុមហ៊ុនបញ្ចូលគ្នា ចាប់តាំងពីកាលបរិច្ឆេទដែលមានការចុះនៅលើវិញ្ញាបនបត្រនៃក្រុមហ៊ុន ដែលត្រូវបានរំលាយបញ្ចូលគ្នា៖

- ការរំលាយបញ្ចូលគ្នារបស់ក្រុមហ៊ុនដើម និងការបន្តជាក្រុមហ៊ុនតែមួយរបស់គេត្រូវចូលជាធរមាន។
- កម្មសិទ្ធិរបស់ក្រុមហ៊ុនដើមនីមួយៗ ត្រូវបានជាកម្មសិទ្ធិក្រុមហ៊ុនថ្មី ដែលត្រូវបន្តធ្វើអាជីវកម្ម។
- ក្រុមហ៊ុនថ្មីដែលបន្តធ្វើអាជីវកម្ម ត្រូវទទួលខុសត្រូវចំពោះកាតព្វកិច្ច របស់ក្រុមហ៊ុនដើមនីមួយៗ។
- កិច្ចការរដ្ឋប្បវេណី ព្រហ្មទណ្ឌ ឬរដ្ឋបាលណាមួយ ដែលពាក់ព័ន្ធដល់ក្រុមហ៊ុនដើមណាមួយនោះ នៅតែមានជាធរមានក្នុងទំនាក់ទំនងជាមួយក្រុមហ៊ុនថ្មីដែលបន្តធ្វើអាជីវកម្ម។
- លក្ខន្តិកៈស្តីពីការរំលាយក្រុមហ៊ុនបញ្ចូលគ្នាត្រូវចាត់ទុកជាលក្ខន្តិកៈ សម្រាប់ការធ្វើអាជីវកម្មរបស់ក្រុមហ៊ុនថ្មី ហើយវិញ្ញាបនបត្របញ្ជាក់ការរំលាយក្រុមហ៊ុនបញ្ចូលគ្នាត្រូវចាត់ទុកជាវិញ្ញាបនបត្របញ្ជាក់ពីការធ្វើអាជីវកម្មសម្រាប់ក្រុមហ៊ុនថ្មីដែលត្រូវបន្តធ្វើអាជីវកម្ម។[43]

### ២.២.៣. លក្ខខណ្ឌក្នុងការទាមទារឱ្យមានការវាយតម្លៃភាគហ៊ុន

ក្នុងការរំលាយក្រុមហ៊ុនបញ្ចូលគ្នា ប្រសិនជាម្ចាស់ហ៊ុនមួយចំនួននៃក្រុមហ៊ុនដើមមានការមិនពេញចិត្តទៅលើការវាយតម្លៃ ម្ចាស់ហ៊ុននៃក្រុមហ៊ុនដើមមានសិទ្ធិក្នុងការទាមទារឱ្យមានការវាយតម្លៃលើតម្លៃភាគហ៊ុនរបស់ខ្លួននៅក្នុងក្រុមហ៊ុនដើម។ ប៉ុន្តែដើម្បីទទួលបានសិទ្ធិធ្វើការវាយតម្លៃបានម្ចាស់ហ៊ុនទាំងនោះត្រូវបំពេញនូវលក្ខខណ្ឌដូចតទៅ៖

- មុនពេលម្ចាស់ហ៊ុនបានបោះឆ្នោតធ្វើការរំលាយក្រុមហ៊ុនបញ្ចូលគ្នា ម្ចាស់ហ៊ុនត្រូវកាន់កាប់ភាគ-ហ៊ុននៅក្នុងក្រុមហ៊ុនដើមណាមួយ។

---

[42] មាត្រា ២៤៧ នៃច្បាប់ស្តីពីសហគ្រាសពាណិជ្ជកម្ម ១៥ កក្កដា ២០០៥។

[43] មាត្រា ២៤៨ នៃច្បាប់ស្តីពីសហគ្រាសពាណិជ្ជកម្ម ១៥ កក្កដា ២០០៥។

- នៅក្នុងពេលបោះឆ្នោតម្ចាស់ហ៊ុននោះមិនបានបោះឆ្នោតគាំទ្រឱ្យមានការរំលាយក្រុមហ៊ុនបញ្ចូលគ្នាទេ។ ម្ចាស់ហ៊ុននោះត្រូវធ្វើការទាមទារជាលាយល័ក្ខណ៍អក្សរចំពោះក្រុមហ៊ុនថ្មីដែលទទួលធ្វើអាជីវកម្មបន្ត ក្រោយពីលក្ខន្តិកៈស្តីពីការរំលាយក្រុមហ៊ុនបញ្ចូលគ្នាត្រូវបានតម្កល់ទុកនៅក្រសួង-ពាណិជ្ជកម្ម។
- នៅពេលដែលធ្វើការទាមទារឱ្យមានការវាយតម្លៃ ម្ចាស់ហ៊ុននោះត្រូវប្រគល់ប័ណ្ណភាគហ៊ុនរបស់ខ្លួនទៅឱ្យក្រុមហ៊ុនថ្មីដែលទទួលធ្វើអាជីវកម្មបន្ត។[44]

## ២.៣. យុទ្ធសាស្ត្រនៃការចរចា

ការចរចាគឺជាទម្រង់ដ៏សាមញ្ញបំផុតនៃដំណើរការដោះស្រាយវិវាទនៅទូទាំងពិភពលោក ដែលគេឃើញមានទាំងនៅក្នុងយុត្តាធិការនៃច្បាប់ស៊ីវិល (Civil Law) និងច្បាប់អង់គ្លេស (Common Law)។[45] ការចរចាធ្វើឡើងតាមវិធីពីរយ៉ាងដូចជា ដោយផ្ទាល់មាត់ ឬជាលាយល័ក្ខណ៍អក្សរ។ ការចរចាអាចធ្វើតាមរយៈតំណាងរបស់អនុប្បទាយី និងអនុប្បទានិកនោះ។ វិធីសាស្ត្រមូលដ្ឋានក្នុងការចរចាមានការបែងចែកជាពីរបែប ឈ្នះ-ចាញ់ និង ឈ្នះ-ឈ្នះ។

**ករណីសិក្សាទី១៖**

កាលពីឆ្នាំ២០១២ លោក Mark Zuckerberg ដែលជាម្ចាស់ក្រុមហ៊ុន Facebook បានទិញក្រុមហ៊ុន Instagram ក្រោមចំនួនទឹកប្រាក់ ១ (មួយ) ពាន់លានដុល្លារសហរដ្ឋអាមេរិក ដោយសារតែលោកបានមើលឃើញថាក្រុមហ៊ុន Facebook និងក្រុមហ៊ុន Instagram គឺនឹងក្លាយជាក្រុមហ៊ុនតែមួយ និងផ្តល់នូវបទពិសោធន៍ចែករំលែករូបថតដ៏ល្អបំផុតនៅលើបណ្តាញសង្គមនេះជាមួយគ្នា។[46]

---

[44] មាត្រា ២៨៩ នៃច្បាប់ស្តីពីសហគ្រាសពាណិជ្ជកម្ម ១៩ កក្កដា ២០០៥។

[45] សៀវភៅសិក្សាស្តីពី ដំណោះស្រាយវិវាទក្រៅប្រព័ន្ធតុលាការ ខែមករា ឆ្នាំ២០១០។

[46] The New York Times " Facebook Buys Instagram For $1 Billion"
<https://archive.nytimes.com/dealbook.nytimes.com/2012/04/09/facebook-buys-instagram-for-1-billion/>
"This is an important milestone for Facebook because it's the first time we've ever acquired a product and company with so many users. We don't plan on doing many more of these, if any at all. But providing the best photo sharing experience is one reason why so many people love Facebook and we knew it would be worth bringing these two companies together. We're looking forward to working with the Instagram team and to all of the great new experiences we're going to be able to build together." ថ្ងៃទី០៦ ខែសីហា ឆ្នាំ២០២៣។

**ករណីសិក្សាទី២៖**

ការបញ្ចូលក្រុមហ៊ុនរវាង King Technologies Co., Ltd (Opennet) និង ក្រុមហ៊ុន Ezecom Co., Ltd ដោយយោងតាមសេចក្ដីប្រកាសព័ត៌មាន នៅក្នុងសំណុំរឿងរដ្ឋប្បវេណីលេខ ២៧៦ ចុះថ្ងៃទី២២ ខែកុម្ភៈ ឆ្នាំ២០២២ របស់សាលាដំបូងរាជធានីភ្នំពេញដែលមានខ្លឹមសារដូចខាងក្រោម "អភិបាលបណ្ដោះអាសន្ន នៃកូនបំណុលក្រុម-ហ៊ុន King Technologies Co., Ltd (Opennet) សូមប្រកាសព័ត៌មានជូនសាធារណៈជនឱ្យបានជ្រាបថា អតិថិជនទាំងអស់ របស់កូនបំណុលក្រុមហ៊ុន King Technologies Co., Ltd (Opennet) ត្រូវបានផ្ទេរទៅឱ្យក្រុមហ៊ុន Ezecom Co., Ltd ចាប់ពីថ្ងៃប្រកាសព័ត៌មាននេះតទៅ"[47]។ ការរំលាយបញ្ចូលគ្នារបស់ក្រុមហ៊ុន King Technologies Co., Ltd (Opennet) និង ក្រុមហ៊ុន Ezecom Co., Ltd នេះកើតឡើងដោយសារតែក្រុមហ៊ុន King Technologies Co., Ltd (Opennet) គ្មានលទ្ធភាពក្នុងការធ្វើអាជីវកម្មបន្តអាជីវកម្មរបស់ខ្លួនទើបមានការផ្ទេរសិទ្ធិកាន់កាប់ក្រុមហ៊ុនរបស់ខ្លួនឱ្យទៅក្រុមហ៊ុន Ezecom Co., Ltd ជាអ្នកកាន់កាប់បន្ត។[48]

[47] សេចក្ដីប្រកាសព័ត៌មាន នៃអភិបាលបណ្ដោះអាសន្នស្ដីពី សំណុំរឿងរដ្ឋប្បវេណីលេខ ២៧៨ ចុះថ្ងៃទី២២ ខែកុម្ភៈ ឆ្នាំ២០២២។

[48] មាត្រា ៥៣ នៃច្បាប់ស្ដីពីសហគ្រាសពាណិជ្ជកម្ម ១៥ កក្កដា ២០០៥។

# ជំពូកទី២

# នីតិវិធីនៃការផ្ទេរ

# បេតិកភណ្ឌពាណិជ្ជកម្ម

# ជំពូកទី២

# នីតិវិធីនៃការផ្ទេរបេតិកភណ្ឌពាណិជ្ជកម្ម

ដើម្បីធ្វើការផ្ទេរបេតិកភណ្ឌពាណិជ្ជកម្មមួយទៅបាន បុគ្គលគ្រប់រូបតម្រូវឱ្យធ្វើទៅតាមនូវនីតិវិធីដែលច្បាប់បានចែង ការផ្ទេរបេតិកភណ្ឌពាណិជ្ជកម្មតាមរបបសន្តតិកម្ម **(ផ្នែកទី១)** និងការផ្ទេរបេតិកភណ្ឌពាណិជ្ជកម្មតាមនីតិក្រុមហ៊ុន **(ផ្នែកទី២)**។

## ផ្នែកទី១៖ ការផ្ទេរបេតិកភណ្ឌពាណិជ្ជកម្មតាមរបបសន្តតិកម្ម

ការផ្ទេរបេតិកភណ្ឌពាណិជ្ជកម្មតាមរបបសន្តតិកម្ម អាចធ្វើឡើងទៅបានតាមទម្រង់នៃការបែងចែកមត៌កដែលច្បាប់បានចែង ដែលបុគ្គលគ្រប់រូបមានសេរីភាពក្នុងការផ្ទេរ ឬចាត់ចែងទ្រព្យសម្បត្តិរបស់ខ្លួនឱ្យស្របទៅតាមទម្រង់ណាមួយដែលបានកំណត់នៅក្នុងក្រមរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០០៧។ ហើយមតកជនមានសិទ្ធិក្នុងការផ្ទេរឬបែងចែកទ្រព្យសម្បត្តិរបស់ខ្លួនទៅឱ្យសន្តតិជន ដែលសន្តតិជនធ្វើការសម្រេចចិត្តយល់ព្រមទាំងស្រុង ឬមួយផ្នែកណាមួយនៃទ្រព្យសម្បត្តិនោះ។ **១.១.** ការយល់ព្រមទាំងស្រុង និង **១.២.** ការយល់ព្រមដោយមានកម្រិត។

### ១.១. ការយល់ព្រមទាំងស្រុង

ការយល់ព្រមទទួលអនុប្បទានមូលនិធិពាណិជ្ជកម្ម (សន្តតិជន ឬតតិយជន) បានយល់ព្រមត្រូវតែទទួលបន្តនូវសិទ្ធិ និងកាតព្វកិច្ចរបស់មតកជននោះ។ ប្រសិនបើសន្តតិជនបានធ្វើការយល់ព្រមទាំងស្រុងក្នុងការទទួលបន្តនូវមត៌កនោះសន្តតិជនត្រូវតែទទួលបន្តដោយគ្មានកម្រិតនូវសិទ្ធិ និងកាតព្វកិច្ចរបស់មតកជននោះទេ។[49] ដូចនេះសន្តតិជនដែលធ្វើការយល់ព្រមទាំងស្រុងនៃមត៌កដែលមតកជនបានប្រគល់ឱ្យត្រូវទទួលទាំងទ្រព្យសកម្ម និងទ្រព្យអកម្ម។

### ១.២. ការយល់ព្រមដោយមានកម្រិត

ការយល់ព្រមដោយមានកម្រិត សន្តតិជនអាចយល់ព្រមដោយបម្រុងទុកនូវសំណងកាតព្វកិច្ច និងអច្ច័យទានរបស់មតកជនបានត្រឹមកម្រិតនៃទ្រព្យសម្បត្តិដែលខ្លួនបានទទួលតាមរយៈសន្តតិកម្មតែប៉ុណ្ណោះ។[50] មានន័យថានៅពេលដែលសន្តតិជនយល់ព្រមទទួលមត៌កពីមតកជនដោយមានកម្រិត សន្តតិជនត្រូវទទួលយកមកទាំងអស់នូវកាតព្វកិច្ចរបស់មតកជនពោល គឺទ្រព្យអកម្ម (បំណុល) និងទ្រព្យសកម្ម (ភាគលាភ) ក៏ប៉ុន្តែសន្តតិជនអាចកម្រិតការទទួលខុសត្រូវសងបំណុល ត្រឹមតែកម្រិតនៃមត៌កដែលបានទទួលដោយសន្តតិកម្មប៉ុណ្ណោះ។ ប៉ុន្តែ

---

[49] មាត្រា ១២៥៤ ក្រមរដ្ឋប្បវេណីព្រះរាជាណាចក្រកម្ពុជា ០៨ ធ្នូ ២០០៧។

[50] មាត្រា ១២៥៦ ក្រមរដ្ឋប្បវេណីព្រះរាជាណាចក្រកម្ពុជា ០៨ ធ្នូ ២០០៧។

ប្រសិនបើសន្តតិជនស្ម័គ្រចិត្តសងកាតព្វកិច្ចលើសពីកម្រិតដែលខ្លួនទទួលបានពីសន្តតិកម្មក៏ដោយ ក៏មិនមែនជាការសងដោយគ្មានកាតព្វកិច្ចដែរ ដូច្នេះការសងនេះមានសុពលភាព។[51] ក្នុងករណីប្រសិនបើសន្តតិជនមានច្រើននាក់ ការយល់ព្រមដោយកម្រិតនេះ អាចធ្វើបានលុះត្រាតែសហសន្តតិជននោះបានធ្វើដោយរួមគ្នាទាំងអស់។[52] ពេលយល់ព្រមដោយមានកម្រិត ចាំបាច់ត្រូវមាននីតិវិធីជម្រះបញ្ជីដើម្បីឱ្យមានសមភាពក្នុងការសងចំពោះម្ចាស់បំណុលរបស់មតកជន ហើយសហសន្តតិជនទាំងអស់ត្រូវមានការឯកភាពក្នុងការសងនោះ។[53] សហសន្តតិជនដែលមានបំណងចង់យល់ព្រមដោយកម្រិត សន្តតិជនត្រូវធ្វើបញ្ជីសារពើភ័ណ្ឌ ហើយត្រូវដាក់ពាក្យសុំអំពីការយល់ព្រមដោយកម្រិតនោះទៅតុលាការ។[54] ការធ្វើបញ្ជីសារពើភ័ណ្ឌ និងដាក់ពាក្យសុំទៅតុលាការ។

### ១.២.១. ការធ្វើបញ្ជីសារពើភ័ណ្ឌ

ទម្រង់នៃការធ្វើបញ្ជីសារពើភ័ណ្ឌមិនបានចែងនៅក្នុងបញ្ញត្តិច្បាប់នោះទេ ក៏ប៉ុន្តែត្រូវធ្វើដោយសរសេរមត៌កសកម្ម (ភាគលាភ) មត៌កអកម្ម (បំណុល) ដែលសន្តតិជនបានទទួលបន្តដោយចាប់ផ្ដើម សន្តតិកម្មទាំងអស់ក្នុងកម្រិតដែលមានលទ្ធភាពអាចដឹង។[55] ការធ្វើបញ្ជីសារពើភ័ណ្ឌនៅក្នុងនីតិវិធីនៃការផ្ទេរបេតិកភណ្ឌពាណិជ្ជកម្ម គឺត្រូវធ្វើឡើងដោយសារការី។ សារការីគឺជាអ្នកដែលដើរតួយ៉ាងសំខាន់ក្នុងការធ្វើប្រតិបត្តិមតកសាសន៍ឱ្យសមស្របតាមខ្លឹមសារនៃលិខិតបណ្ដាំ និងគោរពតាមឆន្ទៈរបស់ម្ចាស់បណ្ដាំ[56] ក្រោយពីសារការីបានកាន់កាប់មុខងារជាអ្នកប្រតិបត្តិមតកសាសន៍ជាដំបូងសារការីត្រូវធ្វើបញ្ជីសារពើភ័ណ្ឌនៃទ្រព្យសម្បត្តិ ហើយត្រូវប្រគល់បញ្ជីសារពើភណ្ឌនោះទៅឱ្យសន្តតិជន ដោយគ្មានការយឺតយ៉ាវ។ ក្នុងករណីដែលសារការីជាអ្នកប្រតិបត្តិមតកសាសន៍គាត់ត្រូវធ្វើបញ្ជីសារពើភ័ណ្ឌនៃទ្រព្យសម្បត្តិ ដោយសន្តតិជនអាចអវត្តមានបាន។[57] គួរកត់សម្គាល់ផងដែលថា មូលហេតុដែលក្រមរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជាបានបញ្ញត្តិថា អ្នកប្រតិបត្តិមតកសាសន៍ត្រូវធ្វើបញ្ជីសារពើភ័ណ្ឌនៅដែលខ្លួនចាប់ផ្ដើមកាន់កាប់មុខងារដំបូង ដើម្បីកំណត់ឱ្យមានភាពច្បាស់លាស់នូវ

[51] មាត្រា ១២៥៦ កថាខណ្ឌទី១ នៃសេចក្ដីកំណត់ក្រមរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជា ២០១០។

[52] មាត្រា ១២៥៦ ក្រមរដ្ឋប្បវេណីព្រះរាជាណាចក្រកម្ពុជា ០៨ ធ្នូ ២០០៧។

[53] មាត្រា ១២៥៦ កថាខណ្ឌទី២ នៃសេចក្ដីកំណត់ក្រមរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជា ២០១០។

[54] មាត្រា ១២៥៧ ក្រមរដ្ឋប្បវេណីព្រះរាជាណាចក្រកម្ពុជា ០៨ ធ្នូ ២០០៧។

[55] មាត្រា ១២៥៧ នៃសេចក្ដីកំណត់ក្រមរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជា ២០១០។

[56] មាត្រា ១២២០ ក្រមរដ្ឋប្បវេណីព្រះរាជាណាចក្រកម្ពុជា ០៨ ធ្នូ ២០០៧។

[57] មាត្រា ១២១៩ ក្រមរដ្ឋប្បវេណីព្រះរាជាណាចក្រកម្ពុជា ឆ្នាំ ២០០៧។

មត៌ករបស់មតកជននៅពេលចាប់ផ្តើមសន្តតិកម្ម ដែលជាកម្មវត្ថុនៃសិទ្ធិក្នុងការគ្រប់គ្រងចាត់ចែងមត៌ករបស់អ្នកប្រតិបត្តិមតកសាសន៍ ព្រមទាំងដើម្បីបញ្ជាក់អំពីមូលដ្ឋាននៃករណីយកិច្ចប្រគល់ ករណីកិច្ចរាយការណ៍ និងករណីយកិច្ចសងសំណង របស់សារការីក្នុងការប្រតិបត្តិមតកសាសន៍ជាដើម។ ទោះជាយ៉ាងនេះក្តីការរៀបចំបញ្ជីសារពើភ័ណ្ឌ អាចអនុវត្តទៅបានតែចំពោះទ្រព្យសម្បត្តិជាក់លាក់ដែលបានកំណត់នៅក្នុងលិខិតមតកសាសន៍តែប៉ុណ្ណោះ។[58] ដូច្នេះក្នុងករណីដែលខ្លឹមសារនៃលិខិតបណ្តាំរបស់មតកជនមានចែងអំពីសិទ្ធិនិង ករណីកិច្ចរបស់សារការីក្នុងការប្រតិបត្តិមតកសាសន៍ សារការីត្រូវអនុវត្តតែចំពោះទ្រព្យសម្បត្តិ មួយភាគក្នុងខ្លឹមសារនៃលិខិតបណ្តាំនោះប៉ុណ្ណោះ មិនអាចអនុវត្តលើសពីទ្រព្យដែលមតកជនមិនបានចែងនោះទេ។ នៅពេលដែលសារការីជាអ្នកប្រតិបត្តិមតកសាសន៍បានចាប់ផ្តើមកាន់កាប់មុខងាររបស់ខ្លួន សន្តតិជនពុំអាចចាត់ចែងមត៌ក ឬធ្វើសកម្មភាពផ្សេងទៀត ដែលនាំឱ្យរារាំងដល់ការប្រតិបត្តិមតកសាសន៍បានឡើយ។[59]

**១.២.២. ការដាក់ពាក្យស្នើសុំទៅតុលាការ**

មុននឹងសហសន្តតិជនអាចធ្វើការយល់ព្រមដោយកម្រិតបាន សហសន្តតិជនត្រូវយកបញ្ជីសារពើភណ្ឌដែលធ្វើឡើងដោយសារការីនោះ ដើម្បីដាក់ពាក្យសុំអំពីការយល់ព្រមដោយកម្រិត ទៅតុលាការក្នុងអំឡុងពេលដែលបានកំណត់នៅក្នុងកថាខណ្ឌទី១ នៃមាត្រា ១២៤៨ (អំឡុងពេលនៃការយល់ព្រម) នៃក្រមនេះ។[60] មាត្រា ១២៥៨ នៃសេចក្តីកំណត់ក្រមរដ្ឋប្បវេណីបានចែងអំពីអានុភាពនៃការយល់ព្រមដោយកម្រិត ដែលមានខ្លឹមសារថាម្ចាស់បំណុលរបស់មតកជន មិនអាចទាមទារឱ្យសន្តតិជនទទួលខុសត្រូវចំពោះទ្រព្យសម្បត្តិផ្ទាល់ខ្លួនរបស់សន្តតិជននោះបានឡើយជាអាទិ៍។ ទោះបីជាបានយល់ព្រមដោយកម្រិតក៏ដោយ តាមផ្លូវច្បាប់មត៌កនោះត្រូវធ្លាក់ទៅសន្តតិជន ក៏ប៉ុន្តែជាសារធាតុទ្រព្យសម្បត្តិនោះត្រូវធ្វើការជម្រះបញ្ជីផ្សេងពីទ្រព្យសម្បត្តិផ្ទាល់របស់សន្តតិ-ជន ហេតុនេះហើយសិទ្ធិលើបំណុល និងកាតព្វកិច្ចរបស់សន្តតិជន និងមតកជន មិនអាចរលត់ដោយព្យាកុល-ភាពទេ ពោលគឺចាំបាច់ត្រូវធ្វើការជម្រះបញ្ជី ដោយនីតិវិធីដូចគ្នានឹងការជម្រះបញ្ជីសិទ្ធិលើបំណុល និងកាតព្វកិច្ចផ្សេងដែរ។ យ៉ាងណាមិញក្នុងករណីដែលសន្តតិជនបានយល់ព្រមដោយកម្រិត ម្ចាស់បំណុលរបស់មតកជនពុំអាចតាមទាមទារឱ្យសន្តតិជនទទួលខុសត្រូវ ចំពោះទ្រព្យសម្បត្តិផ្ទាល់ខ្លួនរបស់សន្តតិជននោះបានឡើយ។[61]

---

[58] មាត្រា ១២២២ ក្រមរដ្ឋប្បវេណីព្រះរាជាណាចក្រកម្ពុជា ឆ្នាំ ២០០៧។

[59] មាត្រា ១២២១ ក្រមរដ្ឋប្បវេណីព្រះរាជាណាចក្រកម្ពុជា ឆ្នាំ ២០០៧។

[60] មាត្រា ១២៥៧ ក្រមរដ្ឋប្បវេណីព្រះរាជាណាចក្រកម្ពុជា ០៨ ធ្នូ ២០០៧។

[61] មាត្រា ១២៥៨ នៃសេចក្តីកំណត់ក្រមរដ្ឋប្បវេណីព្រះរាជាណាចក្រកម្ពុជា ០៨ ធ្នូ ២០១០។

## ផ្នែកទី២៖ ការផ្ទេរបេតិកភណ្ឌពាណិជ្ជកម្មតាមនីតិក្រុមហ៊ុន

រាល់ការផ្ទេរ ផ្លាស់ប្តូរ និងកែប្រែបេតិកភណ្ឌពាណិជ្ជកម្មនៃក្រុមហ៊ុនមួយបាន ច្បាប់តម្រូវឱ្យម្ចាស់ក្រុមហ៊ុនចាស់ដែលជា (អនុប្បទាយី) ធ្វើការផ្ទេរសិទ្ធិ កាតព្វកិច្ច និងបេតិកភណ្ឌពាណិជ្ជកម្មរបស់ខ្លួនទៅឱ្យម្ចាស់ក្រុមហ៊ុនថ្មី (អនុប្បទានិក) ដោយត្រូវធ្វើតាមបែបបទលក្ខខណ្ឌ និងនីតិវិធីដែលមានចែងស្តីពីការផ្ទេរបេតិកភណ្ឌពាណិជ្ជកម្ម ដើម្បីដាក់ទៅកាន់ក្រសួងសាមី ឬក្រសួងពាណិជ្ជកម្ម។

### ២.១. ក្រសួងសាមី ឬក្រសួងពាណិជ្ជកម្ម

ដើម្បីធ្វើការផ្ទេរបេតិកភណ្ឌពាណិជ្ជកម្មនីតិក្រុមហ៊ុនមួយបាន រាល់សំណុំឯកសារទាំងអស់របស់ក្រុមហ៊ុនត្រូវមានការចុះបញ្ជី និងត្រូវតម្កល់ទុកនៅក្រសួងពាណិជ្ជកម្ម។ ពាណិជ្ជករ, សហកម្មសិទ្ធិករទូទៅ, ស្ថាបនិក ឬអភិបាលម្នាក់ៗ ត្រូវជាអ្នកចុះហត្ថលេខាលើពាក្យស្នើសុំចុះក្នុងបញ្ជីពាណិជ្ជកម្មនូវការកែប្រែក្រោយចុះបញ្ជី និងផ្តល់ឯកសារតម្រូវសម្រាប់តម្កល់ទៅឱ្យនាយកដ្ឋានចុះបញ្ជីពាណិជ្ជកម្ម។[62] នីតិវិធីនៃការផ្ទេរបេតិកភណ្ឌពាណិជ្ជកម្មក្រុមហ៊ុនត្រូវធ្វើការចុះបញ្ជីពាណិជ្ជកម្ម (**ចំណុចទី១**) ការផ្ទេរក្រុមហ៊ុន ឬលក់ភាគហ៊ុន (**ចំណុចទី២**) និងឯកសារដែលត្រូវតម្កល់ (**ចំណុចទី៣**)។

#### ២.១.១ ការចុះបញ្ជីពាណិជ្ជកម្ម

រាល់ការកែប្រែក្នុងដំណើរការអាជីវកម្មរបស់ក្រុមហ៊ុនសហគ្រាសទាំងអស់តម្រូវឱ្យមានការចុះបញ្ជីពាណិជ្ជកម្មដូចខាងក្រោម៖

- ការផ្លាស់ប្តូរនាមករណ៍ សហគ្រាស ឬក្រុមហ៊ុន
- ការបន្ថែម ការបន្ថយ ឬការផ្លាស់ប្តូរគោលបំណងកម្មវត្ថុអាជីវកម្ម ឬសកម្មភាពប្រកបពាណិជ្ជកិច្ចរបស់ក្រុមហ៊ុន
- ការបែងចែកសារជាថ្មី នូវចំនួនភាគហ៊ុនជាប្រភេទឡើងវិញ ដោយមានការកែប្រែលក្ខណៈដាច់ខាត និងលក្ខណៈធៀបរបស់ប្រភេទភាគហ៊ុនណាមួយ
- ការកែប្រែភាគលាភ នៃប្រភេទភាគហ៊ុនណាមួយ
- ការបង្កើនដើមទុនដោយបង្កើតភាគហ៊ុនប្រភេទថ្មី ដែលមានលក្ខណៈដាច់ខាត និងលក្ខណៈធៀបប្រសើរជាង ឬទាបជាងប្រភេទភាគហ៊ុនដែលមានរួចហើយ។
- ការបន្ថយដើមទុនចុះបញ្ជី ដោយបញ្ចុះតំលៃចារឹកលើប័ណ្ណនៃប្រភេទភាគហ៊ុនណាមួយ ឬដោយបន្ថយចំនួនភាគហ៊ុនដែលអនុញ្ញាត

[62] ប្រការ ២ ប្រកាសស្តីពីបែបបទ និងនីតិវិធីចុះក្នុងបញ្ជីពាណិជ្ជកម្មនូវរាល់ការផ្លាស់ប្តូរ និងកែប្រែរបស់សហគ្រាសក្រុមហ៊ុន ឆ្នាំ២០១៥។

- ការកែប្រែចិរវេលា នៃអត្ថិភាពរបស់ក្រុមហ៊ុន ការផ្លាស់ប្តូរទីស្នាក់ការចុះបញ្ជី
- ការកែប្រែចំនួនក្លូម
- បន្ថែមបទបញ្ញត្តិណាមួយ ដែលច្បាប់អនុញ្ញាតឱ្យដាក់បញ្ចូលទៅក្នុងលក្ខន្តិកៈក្រុមហ៊ុន
- ការផ្ទេរ ឬលក់ភាគហ៊ុនទាំងឡាយដែលអនុញ្ញាតដោយច្បាប់។[63]

### ២.១.២. ការផ្ទេរក្រុមហ៊ុន ឬលក់ភាគហ៊ុន

ចំពោះការផ្ទេរក្រុមហ៊ុន ឬលក់ភាគហ៊ុនដូចមានចែងក្នុងចំណុចទី១ ខាងលើ ដើម្បីជានាអះអាង និង ទទួលខុសត្រូវលើការផ្ទេរ ឬលក់ភាគហ៊ុនថាពិតជាត្រឹមត្រូវ រាល់សំណុំលិខិតផ្ទេរ ឬលក់ភាគហ៊ុនត្រូវមានការ បញ្ជាក់ដូចខាងក្រោម៖

- ការផ្ទេរ ឬលក់ភាគហ៊ុន ដែលម្ចាស់ភាគហ៊ុនជាអ្នកផ្ទេរ ឬលក់ភាគហ៊ុន នៅក្នុងព្រះរាជាណាចក្រ-កម្ពុជា រាល់សំណុំលិខិតផ្ទេរ ឬលក់ភាគហ៊ុន ត្រូវមានការបញ្ជាក់ពីមេធាវី ឬសារការីនៃព្រះរាជា-ណាចក្រកម្ពុជា
- ការផ្ទេរ ឬលក់ភាគហ៊ុន ដែលម្ចាស់ភាគហ៊ុនជាអ្នកផ្ទេរ ឬលក់ភាគហ៊ុន នៅក្រៅព្រះរាជាណាចក្រ-កម្ពុជា រាល់សំណុំលិខិតផ្ទេរ ឬលក់ភាគហ៊ុន ត្រូវមានការបញ្ជាក់ពីសារការី ឬអាជ្ញាធរ ដែលមាន សមត្ថកិច្ច នៃប្រទេសដែលម្ចាស់ភាគហ៊ុនជាអ្នកផ្ទេរ ឬលក់ភាគហ៊ុនកំពុងរស់នៅ
- ក្នុងករណី ម្ចាស់ហ៊ុនដែលជាអ្នកផ្ទេរ ឬលក់ភាគហ៊ុនរបស់ខ្លួនមិនត្រូវការបញ្ជាក់ពីមេធាវី ឬសារ-ការី នោះសាមីខ្លួនអាចមកចុះហត្ថលេខា និងផ្តិតមេដៃដោយផ្ទាល់នៅចំពោះមុខមន្ត្រីនាយកដ្ឋាន ចុះបញ្ជីពាណិជ្ជកម្ម។[64]

### ២.១.៣. ឯកសារដែលត្រូវតម្កល់

រាល់សំណុំឯកសារដែលមានការចុះបញ្ជី ចំពោះការផ្ទេរបេតិកភណ្ឌក្រុមហ៊ុន ឬលក់ភាគហ៊ុនតម្រូវឱ្យមាន ការផ្តល់ជូនមកនាយកដ្ឋានចុះបញ្ជីពាណិជ្ជកម្មសម្រាប់តម្កល់ទុក ហើយឯកសារដែលត្រូវតម្កល់ទុកនោះមាន ដូចជា៖

- កំណត់ហេតុ និងសេចក្តីសម្រេចសមូហភាពសន្និបាតរបស់ក្រុមហ៊ុន (ច្បាប់ដើម) ចំនួន ០៣ ច្បាប់
- ពាក្យស្នើសុំធ្វើការកែប្រែនិងផ្លាស់ប្តូរ ចំនួន ០៣ ច្បាប់

---

[63] ប្រការ ៣ ប្រកាសស្តីពីបែបបទ និងនីតិវិធីចុះក្នុងបញ្ជីពាណិជ្ជកម្មនូវរាល់ការផ្លាស់ប្តូរ និងកែប្រែរបស់សហគ្រាសក្រុមហ៊ុន ឆ្នាំ២០១៥។

[64] ប្រការ ៤ ប្រកាសស្តីពីបែបបទ និងនីតិវិធីចុះក្នុងបញ្ជីពាណិជ្ជកម្មនូវរាល់ការផ្លាស់ប្តូរ និងកែប្រែរបស់សហគ្រាសក្រុមហ៊ុន ឆ្នាំ២០១៥។

- ច្បាប់ចម្លងវិញ្ញាបនបត្រចុះបញ្ជីពាណិជ្ជកម្ម (វិញ្ញានបនបត្រចុះបញ្ជីពាណិជ្ជកម្មច្បាប់ដើម ក្នុងករណី ក្រុមហ៊ុនធ្វើការកែប្រែនាមករណ៍ ប្តូរសញ្ជាតិ ឬប្តូរទ្រង់ទ្រាយក្រុមហ៊ុន) ចំនួន ០៣ ច្បាប់
- ច្បាប់ចម្លងលិខិតគោលការណ៍ទទួលចុះឈ្មោះក្រុមហ៊ុនក្នុងបញ្ជីពាណិជ្ជកម្ម ចំនួន ០៣ ច្បាប់
- ច្បាប់ចម្លងប្រតិវេទន៍អំពីស្ថានភាពសហគ្រាសពាណិជ្ជកម្ម ប្រចាំឆ្នាំ ចំនួន ០១ ច្បាប់
- ច្បាប់ចម្លងប័ណ្ណប៉ាតង់ ចំនួន ០៣ ច្បាប់
- ច្បាប់ចម្លងអត្តសញ្ញាណប័ណ្ណ ឬលិខិតឆ្លងដែន និងរូបថតទំហំ ៤ x ៦ របស់ម្ចាស់ហ៊ុនថ្មីម្នាក់ៗ (ក្នុងករណីមានបន្ថែមសមាជិកភាគហ៊ុនថ្មី)
- ច្បាប់ចម្លងអាជ្ញាប័ណ្ណរបស់ក្រសួង - ស្ថាប័នពាក់ព័ន្ធ "បើសិនជាមាន" ចំនួន ០៣ ច្បាប់។[65]

[65] ប្រការ ៥ ប្រកាសស្តីពីបែបបទ និងនីតិវិធីចុះក្នុងបញ្ជីពាណិជ្ជកម្មនូវរាល់ការផ្លាស់ប្តូរ និងកែប្រែរបស់សហគ្រាសក្រុមហ៊ុន ឆ្នាំ២០១៥។

# ជំពូកទី៣

# អានុភាពនៃការផ្ទេរ

# បេតិកភណ្ឌពាណិជ្ជកម្ម

# ជំពូកទី៣

# អានុភាពនៃការផ្ទេរបេតិកភណ្ឌពាណិជ្ជកម្ម

ក្នុងការផ្ទេរបេតិកភណ្ឌពាណិជ្ជកម្ម បើយោងតាមក្រមរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជា ដើម្បីធ្វើឱ្យការផ្ទេរកម្មសិទ្ធិមួយមានអានុភាពបាន លុះត្រាតែមានការព្រមព្រៀងគ្នារវាងអនុប្បទាយី និងអនុប្បទានិក។[66] ហើយការព្រមព្រៀងគ្នានេះផងដែល មានន័យថាអនុប្បទាយីបានយល់ព្រមប្រគល់សិទ្ធិ កាតព្វកិច្ចគ្រប់គ្រងក្រុម-ហ៊ុន និងទ្រព្យទាំងមូល ឱ្យទៅអនុប្បទានិក ពោលគឺផ្ទេរបេតិកភណ្ឌទៅលើទ្រព្យអកម្ម និងទ្រព្យសកម្មមកឱ្យអនុ-ប្បទានិកជាអ្នកគ្រប់គ្រងបន្ត។ ដូចនេះការផ្ទេរអនុប្បទានពាណិជ្ជកម្ម ត្រូវបានធ្វើការបែកចែកជាពីរបៀប ការផ្ទេរបេតិកភណ្ឌពាណិជ្ជកម្មទៅលើទ្រព្យសកម្ម **(ផ្នែកទី១)** និងការផ្ទេរបេតិកភណ្ឌពាណិជ្ជកម្មទៅលើទ្រព្យអកម្ម **(ផ្នែកទី២)**។

## ផ្នែកទី១៖ ការផ្ទេរបេតិកភណ្ឌពាណិជ្ជកម្មទៅលើទ្រព្យសកម្ម

ការផ្ទេរបេតិកភណ្ឌពាណិជ្ជកម្មទៅលើទ្រព្យសកម្ម គឺជាការផ្ទេរនូវសិទ្ធិកាន់កាប់ទៅលើប្រភពនៃប្រាក់ចំណូលទាំងអស់របស់ក្រុមហ៊ុនពីសំណាក់អនុប្បទាយីទៅឱ្យអនុប្បទានិក។ ប្រាកដណាស់ការផ្ទេរកម្មសិទ្ធិនៃកម្មវត្ថុទាំងអស់នេះ មានន័យថាផ្ទេរកម្មសិទ្ធិនៃអរូបទ្រព្យដែលជាបេតិកភណ្ឌពាណិជ្ជកម្ម ដោយហេតុថាផ្តើមចេញពីការលក់មូលនិធិពាណិជ្ជកម្ម ដែលជាកិច្ចសន្យាព្រមព្រៀងពុំមែនជាកិច្ចសន្យាឱឡារិកទេ ការផ្ទេរកម្មសិទ្ធិត្រូវបានប្រព្រឹត្តទៅរវាងគូភាគីទាំងសងខាង ចាប់ពីពេលដែលសហភាគីបានព្រមព្រៀងគ្នានូវវត្ថុ និងថ្លៃនៃវត្ថុនោះផងដែរ។ ហើយប្រភពនៃការទទួលបានប្រាក់ចំណូលនៃទ្រព្យរបស់ក្រុមហ៊ុននេះផងដែលអាចមានលក្ខណៈជាទម្រង់ **១.១.** អនុប្បទានសិទ្ធិលើបំណុល **១.២.** សិទ្ធិតតាំងជាមួយតតិយជន និង **១.៣.** កម្មសិទ្ធិឧស្សាហកម្ម ។

### ១.១ អនុប្បទានសិទ្ធិលើបំណុល

យោងតាមក្រមរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជា អនុប្បទានសិទ្ធិលើបំណុល គឺជាការផ្ទេរសិទ្ធិលើបំណុលពីអ្នកមានសិទ្ធិលើបំណុល ទៅបុគ្គលផ្សេងទៀតដែលមិនមែនជាកូនបំណុល ដោយច្បាប់បានបញ្ញត្តិថាអ្នកមានសិទ្ធិលើបំណុលគឺ អនុប្បទាយី រីឯអ្នកទទួលសិទ្ធិលើបំណុលវិញគឺ អនុប្បទានិក។ ជាមួយគ្នានេះ ច្បាប់មិនបានកំណត់ពីលក្ខខណ្ឌ ឬទម្រង់នៃការបង្កើតអនុប្បទានសិទ្ធិលើបំណុលច្បាស់លាស់នូវឡើយ ហេតុនេះភាគីមិនចាំបាច់ធ្វើឡើងជាលាយល័ក្ខណ៍អក្សរ ឬជាទម្រង់លិខិតយថាភូត ក៏បានដែរ ដោយភាគីអាចបង្កើតឡើងបានតាមការព្រមព្រៀង ឬតាមបញ្ញត្តិច្បាប់ និងគោរពតាម លក្ខខណ្ឌនៃការអនុវត្តសិទ្ធិលើបំណុល និងលក្ខខណ្ឌនៃការជូនដំណឹងអំពីការ ធ្វើអនុប្បទានសិទ្ធិលើបំណុល។

[66] មាត្រា ៣៣៧ ក្រមរដ្ឋប្បវេណីព្រះរាជាណាចក្រកម្ពុជា ០៨ ធ្នូ ២០០៧។

### ១.១.១. លក្ខខណ្ឌនៃការអនុវត្តសិទ្ធិលើបំណុល

ក្រោយពីមានការព្រមព្រៀងគ្នារវាងអនុប្បទាយី (ម្ចាស់បំណុល) ដែលមានគោលបំណងធ្វើអនុប្បទានសិទ្ធិលើបំណុល ជាមួយអនុប្បទានិកដែលមានគោលបំណងទទួលសិទ្ធិលើបំណុលនោះរួចរាល់ នាំឱ្យកើតមានអានុភាពនៃអនុប្បទានសិទ្ធិលើបំណុលផងដែរ។[67] បន្ទាប់ពីអនុប្បទាយី បានប្រគល់សិទ្ធិលើបំណុលទៅឱ្យអនុប្បទានិក នោះអនុប្បទានិកនឹងក្លាយជាម្ចាស់បំណុលថ្មី ហើយមានសិទ្ធិអនុវត្តនូវសិទ្ធិលើបំណុលដើមជំនួសអនុប្បទាយីបាន។ យ៉ាងណាមិញ សិទ្ធិលើបំណុលមួយចំនួន មិនអាចធ្វើអនុប្បទានបានឡើយ ដោយហេតុថា សិទ្ធិលើបំណុលនោះ មានការចងកាតព្វកិច្ចរវាងតែម្ចាស់បំណុលជាមួយកូនបំណុលតែប៉ុណ្ណោះ។[68] មួយវិញទៀត ភាគីអាចធ្វើកិច្ចសន្យាពិសេសដែលបង្ហាញឆន្ទៈដើម្បីហាមឃាត់មិនឱ្យធ្វើអនុប្បទានសិទ្ធិលើបំណុលបាន។[69]

ជាពិសេស ប្រសិនបើអនុប្បទានិកបានបំពេញលក្ខខណ្ឌដូចបានរៀបរាប់ខាងលើនេះ ដូច្នេះអនុប្បទានិកមានសិទ្ធិតាំងខ្លួនជាម្ចាស់បំណុលថ្មី ក្នុងការទាមទារឱ្យកូនបំណុលអនុវត្តកាតព្វកិច្ចចំពោះខ្លួនបាន។

### ១.១.២. លក្ខខណ្ឌនៃការជូនដំណឹងអំពីការធ្វើអនុប្បទានសិទ្ធិលើបំណុល

ក្នុងករណីដែលធ្វើអនុប្បទានសិទ្ធិលើបំណុលតែមួយ តែធ្វើឡើងច្រើនដង នោះអាទិភាពនៃអនុប្បទាននេះ ត្រូវកំណត់យកការជូនដំណឹង ដែលមានកាលបរិច្ឆេទស្តាពរបានដល់កូនបំណុល ឬពេលដែលកូនបំណុលយល់ព្រមទទួលលិខិតនោះ។ ដូច្នេះ អនុប្បទានិកនីមួយៗអាចទាមទារឱ្យកូនបំណុលអនុវត្តកាតព្វកិច្ចចំពោះខ្លួនបាន ប៉ុន្តែក្នុងករណីនេះ កូនបំណុលអាចសងចំពោះម្ចាស់បំណុលណាម្នាក់ដែលមានអាទិភាព រួមទាំងត្រូវតម្កល់នូវវត្ថុដែលជាកម្មវត្ថុនៃកាតព្វកិច្ច នោះទើបកាតព្វកិច្ចរបស់កូនបំណុលត្រូវបានរំលត់។ ជាមួយគ្នានេះ កូនបំណុលមិនអាចលើកយកមូលហេតុដែលខ្លួនអាចធ្វើការតតាំងជាមួយអនុប្បទានិកបានឡើយ។[70]

## ១.២. សិទ្ធិតតាំងជាមួយតតិយជន

ដើម្បីឱ្យអនុប្បទានសិទ្ធិលើបំណុលនេះរឹតតែមានអានុភាពអាចតតាំងជាមួយកូនបំណុល ឬតតិយជនផ្សេងបាន អនុប្បទាយី ឬអនុប្បទានិក ត្រូវធ្វើការជូនដំណឹងដល់កូនបំណុលជាលាយល័ក្ខណ៍អក្សរ និងទទួលការយល់ព្រមពីកូនបំណុល ឬតតិយជន តែការតតាំងជាមួយតតិយជនត្រូវធ្វើជាលាយល័ក្ខណ៍អក្សរ បើមិនដូច

[67] មាត្រា ៥០២ វាក្យខណ្ឌ ១ ក្រមរដ្ឋប្បវេណីព្រះរាជាណាចក្រកម្ពុជា ០៨ ធ្នូ ២០០៧។

[68] មាត្រា ៥០១ ចំណុច១ ក្រមរដ្ឋប្បវេណីព្រះរាជាណាចក្រកម្ពុជា ០៨ ធ្នូ ២០០៧។

[69] មាត្រា ៥០១ ចំណុច២ ក្រមរដ្ឋប្បវេណីព្រះរាជាណាចក្រកម្ពុជា ០៨ ធ្នូ ២០០៧។

[70] មាត្រា ៥០៥ ចំណុច១ ក្រមរដ្ឋប្បវេណីព្រះរាជាណាចក្រកម្ពុជា ០៨ ធ្នូ ២០០៧។

ច្នេះនោះទេមិនអាចធ្វើការតតាំងជាមួយកូនបំណុល ឬតតិយជនបានឡើយ។ ទទ្ទឹមនឹងនេះផងដែលក្នុងលក្ខខណ្ឌអនុវត្តសិទ្ធិតតាំង បានត្រូវគោរពតាមនីតិវិធីនៃការតតាំងជាមួយតតិយជន។

ចំពោះការជូនដំណឹង ឬការយល់ព្រមនេះ ពុំមានកំណត់ទម្រង់អ្វីនោះទេ ហេតុនេះការជូនដំណឹងអាចធ្វើឡើងដោយផ្ទាល់មាត់ ឬជាលាយល័ក្ខណ៍អក្សរ[71] ប៉ុន្តែការជូនដំណឹង ឬការយល់ព្រមខាងលើនេះ បើមិនធ្វើឡើងដោយលិខិតដែលមានកាលបរិច្ឆេទស្អាពរទេ (សំដៅលើលិខិតដែលធ្វើឡើងជាលាយល័ក្ខណ៍អក្សរ ដែលតាក់តែងឡើងដោយស្ថាប័នរដ្ឋ ឬលិខិតយថាភូត[72] ដែលតាក់តែងដោយសារការី ឬមេធាវី ដោយមានសរសេរអំពីៈ

- ព័ត៌មានអត្តសញ្ញាណរបស់អ្នកជូនដំណឹង និងឈ្មោះ
- ទីតាំងរបស់អ្នកទទួល
- កម្មវត្ថុ ឬគោលបំណង
- កាលបរិច្ឆេទ នៃការជូនដំណឹង
- ស្នាមមេដៃ ឬហត្ថលេខារបស់អ្នកជូនដំណឹង រួមជាមួយហត្ថលេខា និងត្រារបស់ស្ថាប័នរដ្ឋ ឬសារ-ការី ឬមេធាវី អមជាមួយដើម្បីបញ្ជាក់អំពីភាពត្រឹមត្រូវនៃលិខិតនោះ) នោះពុំមានអានុភាពតតាំងជាមួយតតិយជនបានឡើយក្រៅពីកូនបំណុល។

ប៉ុន្តែអនុប្បទាយី ឬអនុប្បទានិក មិនអាចតតាំងជាមួយកូនបំណុល ឬតតិយជនផ្សេងបានឡើយប្រសិនបើមិនបានជូនដំណឹងអំពីអនុប្បទានសិទ្ធិលើបំណុលនេះដល់កូនបំណុល ឬមិនមានការយល់ព្រមពីកូនបំណុល។[73] ករណីនេះ មិនអាចតតាំងចំពោះតតិយជនដែលមិនបានដឹងអំពីហេតុការណ៍នេះបានឡើយ លើកលែងតែមិនបានដឹងដោយកំហុសធ្ងន់ធ្ងរ។[74] ជាគោលការណ៍ច្បាប់ បានអនុញ្ញាតឱ្យអនុប្បទានិក ដែលម្ចាស់បំណុលបានកំណត់ឈ្មោះជាក់លាក់ (សិទ្ធិលើការកំណត់ឈ្មោះជាសិទ្ធិរបស់ម្ចាស់បំណុល) ជាអ្នកមានសិទ្ធិលើបំណុល អាចអះអាងអំពីសិទ្ធិនេះ យកទៅតតាំងជាមួយតតិយជនបាន ។

---

[71] មាត្រា ៣៣៦ ក្រមរដ្ឋប្បវេណីព្រះរាជាណាចក្រកម្ពុជា ០៨ ធ្នូ ២០០៧។

[72] មាត្រា ១១៧៣ ក្រមរដ្ឋប្បវេណីព្រះរាជាណាចក្រកម្ពុជា ០៨ ធ្នូ ២០០៧។

[73] មាត្រា ៥០៣ ចំណុច៣ ក្រមរដ្ឋប្បវេណីព្រះរាជាណាចក្រកម្ពុជា ០៨ ធ្នូ ២០០៧។

[74] មាត្រា ៥០១ ចំណុច៣ ក្រមរដ្ឋប្បវេណីព្រះរាជាណាចក្រកម្ពុជា ០៨ ធ្នូ ២០០៧។

## ១.៣. កម្មសិទ្ធិឧស្សាហកម្ម

ក្រុមហ៊ុនមួយ គឺភ្ជាប់មកជាមួយកម្មសិទ្ធិឧស្សាហកម្មរបស់ក្រុមហ៊ុន ហើយការផ្ទេរបេតិកភណ្ឌរបស់ក្រុម-ហ៊ុនមួយ គឺស្មើនឹងការផ្ទេរកម្មសិទ្ធិឧស្សាហកម្មក្រុមហ៊ុន។ ដែលកម្មសិទ្ធិលើឧស្សាហកម្មនោះរួមមានដូចជា **១.** ប្រកាសនីយបត្រតក្កកម្ម និងវិញ្ញាបនបត្រម៉ូដែលមានប្រយោជន៍ **២.** គំនូរឧស្សាហកម្មក្រុមហ៊ុន **៣.** ម៉ាក និង **៤.** ការសម្ងាត់ពាណិជ្ជកម្ម។

### ១.៣.១. ប្រកាសនីយបត្រតក្កកម្ម និងវិញ្ញាបនបត្រម៉ូដែលមានប្រយោជន៍

រាល់ការប្រកាសនីយបត្រតក្កកម្ម និងវិញ្ញាបនបត្រដែលត្រូវបានផ្តល់ដោយរដ្ឋឱ្យទៅតក្កករ ដើម្បីការពារតក្កកម្ម។តក្កកម្មគឺជា គំនិតរបស់តក្កករ ដែលអាចយកមកអនុវត្ត បានក្នុងដំណោះស្រាយបញ្ហាជាក់លាក់មួយក្នុងវិស័យបច្ចេកវិជ្ជា។[75] ត្រូវបានការពារដោយ ក្រសួងសាមីទាក់ទង និងផលិតផល ឬ ដំណើរការផលិតកម្មនៃផលិតផលនោះ ការរកឃើញអ្វីមួយដែលទាក់ទងនឹងផលិតផល ឬដំណើរការផលិតកម្ម។[76] តក្កកម្មអាចទទួលបានកិច្ចការពារចំពោះ គំនិតដែលតក្កករបានបង្កើតឡើង។ ចំពោះវិញ្ញាបនបត្រម៉ូដែលមានអត្ថប្រយោជន៍ គឺជាវិញ្ញាបនបត្រដែលបានផ្តល់ដើម្បីការពារម៉ូដែលមានអត្ថប្រយោជន៍។ ម៉ូដែលមានអត្ថប្រយោជន៍ គឺជាតក្កកម្មណាមួយដែលថ្មី និង អាចយកទៅអនុវត្តបានក្នុងវិស័យឧស្សាហកម្ម និងដែលអាចជាផលិតផល ឬដំណើរការផលិតកម្ម ឬដែលអាចទាក់ទងទៅនឹងផលិតផល ឬដំណើរការផលិតកម្ម។[77]

### ១.៣.២. គំនូរឧស្សាហកម្មក្រុមហ៊ុន

នៅពេលដែលមានការផ្ទេរក្រុមហ៊ុនពាណិជ្ជកម្ម អនុប្បទាយីបានផ្ទេរសិទ្ធិ និងការគ្រប់គ្រងទៅឱ្យអានុប្បទានិកព្រមទាំងសិទ្ធិលើគំនូរឧស្សហកម្ម ដែលបានធ្វើអាជីវកម្មតាំងពីដំបូងហើយអាចធ្វើការកំណត់សម្គាល់បាន ជារូបរាង សោភ័ណ្ឌភាពនៃផលិផលយ៉ាងច្បាស់លាស់។[78]គំនូរឧស្សហកម្ម ជាកេរ្តិ៍ឈ្មោះដ៏សំខាន់ដែលអាចទាក់ទាញអតិថិជនបានព្រមទាំង មានសិទ្ធិអំណាចក្នុងការចរចានៅលើទីផ្សារដើម្បីទាញយកផលប្រយោ-ជន៍។

---

[75] មាត្រា ៣ កថាខណ្ឌ១ នៃច្បាប់ស្តីពីប្រកាសនីយបត្រតក្កកម្ម វិញ្ញាបនបត្រម៉ូដែលមានអត្ថប្រយោជន៍ និងគំនូរឧស្សាហកម្ម ឆ្នាំ២០០២

[76] មាត្រា ៣ កថាខណ្ឌ២ នៃច្បាប់ស្តីពីប្រកាសនីយបត្រតក្កកម្ម វិញ្ញាបនបត្រម៉ូដែលមានអត្ថប្រយោជន៍ និងគំនូរឧស្សាហកម្ម ឆ្នាំ២០០២

[77] មាត្រា ៦៩ នៃច្បាប់ស្តីពីប្រកាសនីយបត្រតក្កកម្ម វិញ្ញាបនបត្រម៉ូដែលមានអត្ថប្រយោជន៍ និងគំនូរឧស្សាហកម្ម ឆ្នាំ២០០២

[78] មាត្រា ៨៩ នៃច្បាប់ស្តីពីប្រកាសនីយបត្រតក្កកម្ម វិញ្ញាបនបត្រម៉ូដែលមានអត្ថប្រយោជន៍ និងគំនូរឧស្សាហកម្ម ឆ្នាំ២០០២

### ១.៣.៣. ម៉ាក

លក្ខខណ្ឌគ្រឹះដែលទទួលបានកិច្ចការពារម៉ាក គឺជាសញ្ញាដែលមើលឃើញ ហើយអាចសំគាល់លក្ខណៈខុសគ្នា នៃទំនិញ ឬសេវានៃសហគ្រាសនីមួយៗ។[79] ជាគោលការណ៍សិទ្ធិផ្តាច់មុខក្នុងការប្រើប្រាស់ម៉ាក ត្រូវបានទទួលស្គាល់តាមរយៈការចុះបញ្ជី។[80] ការការពារម៉ាក ពាណិជ្ជនាម ដែលបានចុះបញ្ជីក្នុងបញ្ជីម៉ាក នៅក្នុងព្រះរាជាណាចក្រកម្ពុជា និងប្រឆាំងការប្រកួតប្រជែងមិនស្មោះត្រង់ លើការបង្កើត ការប្រើប្រាស់ម៉ាក និងពាណិជ្ជនាម។[81] ជាគោលការណ៍ ម៉ាកដែលមានការចុះបញ្ជីត្រឹមត្រូវ មានសិទ្ធិតតាំងជាមួយតតិយជនបាន នៅពេលមានការរំលោភបំពាន។

### ១.៣.៤. ការសម្ងាត់ពាណិជ្ជកម្ម

លក្ខខណ្ឌដែលអាចទទួលបានកិច្ចការពារ ការសម្ងាត់របស់ក្រុមហ៊ុនរបស់អនុប្បទានិកបន្ទាប់ពីទទួលបានសិទ្ធិគ្រប់គ្រង ក្រុមហ៊ុន ត្រូវកំណត់បានដោយគូភាគីនៅក្នុងកិច្ចសន្យារួមមាន កិច្ចព្រមព្រៀង ឬ ខ រក្សាការសម្ងាត់ កិច្ចសន្យាបឋម តម្លៃពាណិជ្ជកម្មនៃព័ត៌មាន គោលការណ៍ចំណាយដើម្បីចំណេញ តម្លៃសេដ្ឋកិច្ចឯករាជ្យជាក់ស្តែង និងប្រកបដោយសក្តានុពល។ និយោជកអាចការពារ ការសម្ងាត់ពាណិជ្ជកម្មរបស់ពួកគេបានតាមរយៈ ការធ្វើកិច្ចសន្យារក្សាការសម្ងាត់រវាងនិយោជិតសំខាន់នីមួយៗ ឬដោយពឹងផ្អែកលើវិធានបញ្ញត្តិរួមមួយរបស់ទីភ្នាក់ងារក្រុមហ៊ុនឬ គោលការណ៍ណាមួយដែលក្រុមហ៊ុនបានបង្កើតឡើង។ និយោជិតមានកាតព្វកិច្ចមិនបើកបង្ហាញនូវព័ត៌មានសម្ងាត់ណាមួយដែលគាត់បានទទួលតាមរយៈ ការងាររបស់គាត់ឱ្យតតិយជននោះឡើយ។ ព័ត៌មានសម្ងាត់ត្រូវតែរក្សាទុកដោយភាពទុកចិត្តសម្រាប់និយោជក។[82] ជាងនេះទៅទៀតនិយោជិតមានកាតព្វកិច្ចយ៉ាងជាក់លាក់មួយក្នុងការរក្សានូវព័ត៌មានទាំងឡាយណាដែលជាកម្មសិទ្ធិរបស់និយោជក ឱ្យទៅជាការសម្ងាត់។ ក្នុងការកំណត់លក្ខខណ្ឌក្នុងកិច្ចសន្យា ដែលមានកំណត់ពីការសម្ងាត់ពាណិជ្ជកម្ម ត្រូវតម្រូវឱ្យនិយោជិតធ្វើការរក្សាជាសម្ងាត់នូវព័ត៌មាននៃទិន្នន័យ ឬរូបមន្ត គំរូ ឬការបង្កើត ឬបញ្ជីផ្សេងៗ ដែលនិយោជកបានធ្វើការកំណត់នៅក្នុងកិច្ចសន្យានោះ។ ក្នុងករណីដែលនិយោជិតបានធ្វើការបង្ហើបបង្ហាញនូវព័ត៌មានទាំងនោះទៅដល់តតិយជន ឬជាសាធារណៈ ឬយកទៅប្រើប្រាស់ ក្នុងសណ្ឋានដែលធ្វើឱ្យប៉ះពាល់ដល់ផល ប្រយោជន៍

---

[79] មាត្រា ២ ក នៃច្បាប់ស្តីពី ម៉ាក ពាណិជ្ជនាម និងអំពើនៃការប្រកួតប្រជែងមិនស្មោះត្រង់ ឆ្នាំ២០០១

[80] មាត្រា ៣ នៃច្បាប់ស្តីពី ម៉ាក ពាណិជ្ជនាម និងអំពើនៃការប្រកួតប្រជែងមិនស្មោះត្រង់ ឆ្នាំ២០០១

[81] មាត្រា ១ នៃច្បាប់ស្តីពី ម៉ាក ពាណិជ្ជនាម និងអំពើនៃការប្រកួតប្រជែងមិនស្មោះត្រង់ ឆ្នាំ២០០១

[82] ការសម្ងាត់ពាណិជ្ជកម្ម និងនិយោជិតជំនាញនៅក្នុងវិស័យបច្ចេកវិទ្យា (Trade Secrets and Skilled Employee in Computer Industry)

របស់និយោជក នោះនិយោជកអាចធ្វើការរំលាយនូវកិច្ចសន្យាការងារដែលបានធ្វើឡើងរវាងកម្មករនិយោជិត ដោយក្រោមសណ្ឋានដែលនិយោជិតបានប្រព្រឹត្តិនូវកំហុសដែលធ្ងន់ធ្ងរ ដែលធ្វើឱ្យប៉ះពាល់ដល់ផលមួយរបស់និយោជក។ ដូច្នេះបន្ទាប់ពីអនុប្បទាយី ធ្វើការផ្ទេរបេតិកភណ្ឌពាណិជ្ជកម្មរបស់ខ្លួនឱ្យទៅអនុប្បទានិករួចហើយ អនុប្បទានិកត្រូវបន្តក្នុងការការពារការសម្ងាត់ពាណិជ្ជកម្មនោះបន្តដោយមិនឱ្យមានការបែកធ្លាយនោះទេ ពីព្រោះវាអាចធ្វើឱ្យមានការប៉ះពាល់ដល់ប្រយោជន៍អនុប្បទានិក។[83]

## ផ្នែកទី២៖ ការផ្ទេរបេតិកភណ្ឌពាណិជ្ជកម្មទៅលើទ្រព្យអកម្ម

ការផ្ទេរបេតិកភណ្ឌពាណិជ្ជកម្មទៅលើទ្រព្យអកម្ម គឺជាការផ្ទេរនូវសិទ្ធិទទួលបន្តទៅលើប្រភពនៃប្រាក់បំណុលទាំងអស់របស់ក្រុមហ៊ុនពីសំណាក់អនុប្បទាយីទៅឱ្យអនុប្បទានិក។ ព្រមទាំងឱ្យអនុប្បទានិក អនុវត្តបន្តជាមួយ ម្ចាស់បំណុលមានអភ័យឯកសិទ្ធិ **២.១.** និងកម្មករនិយោជិត **២.២.** តាមរយៈឧបាទេសកម្ម។

### ២.១. ម្ចាស់បំណុលមានអភ័យឯកសិទ្ធិ

នៅពេលមានការផ្ទេរទ្រព្យសម្បត្តិពីអនុប្បទាយីទៅអនុប្បទានិក រាល់ទ្រព្យសម្បត្តិទាំងអស់របស់ម្ចាស់ក្រុមហ៊ុនចាស់ត្រូវក្លាយជាបន្ទុករបស់ ម្ចាស់ក្រុមហ៊ុនថ្មី ហេតុនេះជាគោលការណ៍ច្បាប់ ម្ចាស់ក្រុមហ៊ុនថ្មីត្រូវទទួលបន្តនូវបំណុលជំនួសម្ចាស់ក្រុមហ៊ុនចាស់។[84] ម្ចាស់បំណុលដែលមានអភ័យឯកសិទ្ធិ អាចធ្វើការទាមទារអោយម្ចាស់ក្រុមហ៊ុនថ្មីអនុវត្តហ៊ីប៉ូតែកបាន។ ម្ចាស់បំណុលដែលមានអភ័យឯកសិទ្ធិ សំដៅលើម្ចាស់បំណុលដែលមានសិទ្ធិលើបំណុលដែលកើតឡើងដោយសារ សោហ៊ុយចំណាយសម្រាប់ប្រយោជន៍រួម និងសិទ្ធិលើបំណុលរបស់កម្មករនិយោជិត។[85] ឯកសិទ្ធិចំពោះសោហ៊ុយចំណាយសម្រាប់ប្រយោជន៍រួមមានអត្ថិភាពចំពោះសោហ៊ុយចំណាយដើម្បីថែរក្សាទ្រព្យ ឬជម្រះបញ្ជី ឬចែកចំណែកទ្រព្យដែលបានចេញសម្រាប់ប្រយោជន៍រួមរបស់ម្ចាស់បំណុលនីមួយៗ។[86]

#### ២.១.១. លក្ខខណ្ឌហ៊ីប៉ូតែក

ហ៊ីប៉ូតែក ជារបបគតិយុត្តមួយនៃការធានាបំណុលដោយវត្ថុ ដែលត្រូវបានដាក់ជាប្រាតិភោគ។ សារប្រយោជន៍ដ៏ធំបំផុតមួយរបស់ហ៊ីប៉ូតែក គឺថាកូនបំណុលមិនចាំបាច់ផ្ទេរនូវការកាន់កាប់ទ្រព្យដែលជាកម្មវត្ថុនៃហ៊ីប៉ូតែកទៅឱ្យម្ចាស់បំណុលឡើយ ពីព្រោះករណីនេះធ្វើឱ្យកូនបំណុលអាចបន្តការរស់នៅ ឬការធ្វើអាជីវកម្ម នៅ

[83] មាត្រា ៧៧ នៃច្បាប់ស្តីពីការងារ ឆ្នាំ១៩៩៧។

[84] សន្ធានុក្រមផ្នែករដ្ឋប្បវេណី ឆ្នាំ២០០៧។

[85] មាត្រា ៧៨៣ ក ខ ក្រមរដ្ឋប្បវេណីព្រះរាជាណាចក្រកម្ពុជា ឆ្នាំ ២០០៧។

[86] មាត្រា ៧៨៤ ១ ក្រមរដ្ឋប្បវេណីព្រះរាជាណាចក្រកម្ពុជា ឆ្នាំ ២០០៧។

លើទ្រព្យរបស់ខ្លួននោះជាធម្មតា ទោះបីជាទ្រព្យនោះកំពុងតែជាប់ហ៊ីប៉ូតែកក៏ដោយ។ សារប្រយោជន៍មួយទៀតនៃហ៊ីប៉ូតែក គឺថាកូនបំណុលអាចបង្កើតហ៊ីប៉ូតែកច្រើននៅលើទ្រព្យនោះបានចំពោះម្ចាស់បំណុលច្រើនគ្នាទៀតផង ហើយដែលលំដាប់នៃការទទួលបានសំណង គឺអាស្រ័យទៅលើពេលវេលានៃការចុះបញ្ជីសុរិយោដីនៃបន្ទុកហ៊ីប៉ូតែកនោះ។ ការយល់អំពីការបង្កើតកិច្ចសន្យាហ៊ីប៉ូតែក និងអានុភាពនៃកិច្ចសន្យាហ៊ីប៉ូតែកនោះ គឺមានសារៈសំខាន់ណាស់ ព្រោះបើកិច្ចសន្យាហ៊ីប៉ូតែកមួយត្រូវបានបង្កើតឡើង ប៉ុន្តែមិនស្របទៅនឹងលក្ខខណ្ឌដែល ច្បាប់បានកំណត់ទេនោះ នាំឱ្យកិច្ចសន្យាហ៊ីប៉ូតែកនោះមិនមានអានុភាពតាមផ្លូវច្បាប់ទាល់តែសោះ ហើយម្ចាស់បំណុលក៏មិនមានសិទ្ធិប្រាតិភោគប្រត្យក្សនៅលើវត្ថុដែលដាក់ហ៊ីប៉ូតែក ដោយកូនបំណុលនោះដែរ ពោលគឺម្ចាស់ បំណុលមិនអាចអនុវត្តនូវសិទ្ធិហ៊ីប៉ូតែករបស់ខ្លួន ឬទទួលបាននូវអាទិភាពនៃការសងបំណុលរបស់ខ្លួនមុនម្ចាស់បំណុល ដទៃទៀតបានទេ។ អ្វីដែលគួរឱ្យកត់សម្គាល់នោះគឺថា ហ៊ីប៉ូតែកដែលមានចែងនៅក្នុងក្រមរដ្ឋ-ប្បវេណីនេះ គឺអាចអនុវត្តបានតែលើអចលនវត្ថុ សិទ្ធិជួលអចិន្ត្រៃយ៍ ឬផលុបភោគតែប៉ុណ្ណោះ។ ក្នុងន័យនេះ យើងឃើញថាហ៊ីប៉ូតែកជារបបគតិយុត្តមួយ ដែលបង្កើតឡើងដើម្បីការពារនូវផលប្រយោជន៍របស់ម្ចាស់-បំណុល។[87]

### ២.១.២. កម្មករនិយោជិត

នៅពេលដែលមានការផ្ទេរការកាន់កាប់ សិទ្ធិរបស់អនុប្បទាយីទាំងអស់ត្រូវបានទទួលបន្តដោយអនុប្បទា-និកតាមរយៈការព្រមព្រៀងគ្នាចំពោះទម្រង់កិច្ចសន្យា លក់ ទិញ។ កិច្ចសន្យា លក់ ទិញនៅក្នុងន័យអាជីវកម្មរាល់ការលក់ ទិញទាំងអស់ត្រូវមកជាមួយកិច្ចសន្យាការងារ។[88] ហេតុនេះសិទ្ធិលើបំណុលរបស់កម្មករនិយោជិត មានអត្ថិភាពចំពោះសិទ្ធិលើបំណុលទាំងអស់ ដែលកម្មករនិយោជិតត្រូវទទួលពីនិយោជក ដោយផ្អែកលើកិច្ចសន្យាការងារ។ [89]

ម្ចាស់បំណុលដែលជាកម្មករនយោជិតអាចទាមទារ ឱ្យកូនបំណុលអនុវត្តកាតព្វកិច្ចរបស់ខ្លួន ឱ្យស្របទៅតាមខ្លឹមសារនៃកិច្ចសន្យា និង គោលការណ៍នៃភាពសុចរិត និងភាពស្មោះត្រង់។[90]

សិទ្ធិរបស់ម្ចាស់បំណុលក្នុងការទាមទារឱ្យអនុវត្តកាតព្វកិច្ចៈ

១. ម្ចាស់បំណុលអាចទាមទារឱ្យកូនបំណុលអនុវត្តកាតព្វកិច្ចតាមផ្លូវតុលាការ ។

[87] មាត្រា នៃសេចក្តីកំណត់ក្រមរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជា ០៨ ធ្នូ ២០០៧។

[88] មាត្រា ៣៣៧ ក្រមរដ្ឋប្បវេណីព្រះរាជាណាចក្រកម្ពុជា ០៨ ធ្នូ ២០០៧។

[89] មាត្រា ៧៨៥ ក្រមរដ្ឋប្បវេណីព្រះរាជាណាចក្រកម្ពុជា ០៨ ធ្នូ ២០០៧។

[90] មាត្រា ៣៨៤ ក្រមរដ្ឋប្បវេណីព្រះរាជាណាចក្រកម្ពុជា ០៨ ធ្នូ ២០០៧។

២. ទោះបីជាមានបញ្ញត្តិនៃកថាខណ្ឌទី ១ ខាងលើនេះក៏ដោយ ម្ចាស់បំណុលមិន អាចទាមទារឱ្យអនុ-វត្ត កាតព្វកិច្ច តាមផ្លូវតុលាការបានឡើយ ក្នុងករណីដែលមានការព្រមព្រៀងគ្នារវាងភាគីនៃកិច្ចសន្យាថា មិនទាមទារឱ្យអនុវត្ត តាមផ្លូវតុលាការ ។

៣. ទោះបីជាមានការកម្រិតនូវសិទ្ធិទាមទារឱ្យអនុវត្តកាតព្វកិច្ចតាមផ្លូវតុលាការ ដោយសារមានករណីត្រូវនឹងកថាខណ្ឌទី ២ ខាងលើនេះក៏ដោយ ប្រសិនបើកូនបំណុល បានអនុវត្តកាតព្វកិច្ចដោយស្ម័គ្រចិត្ត ហើយ ម្ចាស់បំណុលអាចទទួល និង រក្សាទុកនូវ តាវកាលិកនេះ ដោយចាត់ទុកថាជាការសងបាន។[91]

## ២.២. អានុភាពផ្ទេរបេតិកភណ្ឌ

ចំពោះការផ្ទេរកម្មសិទ្ធិលើកម្មវត្ថុក្នុងកិច្ចសន្យាលក់ទិញ ត្រូវអនុវត្តតាមគោលការណ៍សំណើ និងស្ទីកាត្រូវគ្នា។ បើយោងតាមបញ្ញត្តិនៃច្បាប់អនុប្បទាយី (អ្នកលក់) ត្រូវមានករណីយកិច្ចផ្ទេរសិទ្ធិលើទ្រព្យសម្បត្តិដែលខ្លួនបានលក់ ឬប្រគល់ទៅឱ្យអនុប្បទានិកក្នុងលក្ខខណ្ឌត្រូវថែរក្សាទុកនូវវត្ថុដែលបានលក់រហូតដល់ពេលប្រគល់ រួមទាំងប្រគល់នូវលិខិតផ្សេងៗ ដែលចាំបាច់ដើម្បីបញ្ជាក់ពីសិទ្ធិទៅលើអនុប្បទានិក (អ្នកទិញ) តាមកិច្ចសន្យាដែលបានចែង។ ជាធម្មតាកម្មវត្ថុត្រូវរាប់បញ្ចូលទាំងអតិថិតាដោយសារកម្មវត្ថុចម្បងរបស់អនុប្បទានិកត្រូវធ្វើអាជីវកម្មបន្ត ដើម្បីពង្រីកមុខរបររបស់ខ្លួននាថ្ងៃអនាគត។ ម្ល៉េះហើយប្រសិនបើអ្នកលក់មិនអាចផ្ទេរសិទ្ធិដែលជាកម្មវត្ថុនៃការលក់ទិញទៅឱ្យអ្នកទិញបានទេ អ្នកទិញអាចរំលាយកិច្ចសន្យាបាន។ ជាក់ស្តែងនៅពេលធ្វើកិច្ច-សន្យាបើសិនជាអ្នកទិញពុំបានដឹងថា សិទ្ធិនោះមិនមែនជាសិទ្ធិរបស់អ្នកលក់ទេ អ្នកទិញអាចទាមទារសំណងនៃការខូចខាតបាន។ ក្នុងករណីក្រុមហ៊ុនមួយមានរឿងអាស្រូវ ជាហេតុបណ្តាលឱ្យបាត់បង់អតិថិតា ហើយធ្វើឱ្យអាជីវកម្មមានការរាំងស្ទះ នោះអនុប្បទានិកអាចទាមទារឱ្យអនុប្បទាយីចេញសំណងនៃការខូចខាតបាន ។

ម្យ៉ាងទៀត នៅពេលធ្វើកិច្ចសន្យាប្រសិនបើអ្នកលក់ពុំបានដឹងថា សិទ្ធិដែលជាកម្មវត្ថុនៃការលក់ទិញមិនមែនជារបស់ខ្លួនទេ គឺមិនអាចយកសិទ្ធិនោះដើម្បីផ្ទេរទៅឱ្យអ្នកទិញបានទេ ហើយអ្នកលក់ក៏អាចរំលាយកិច្ច-សន្យានោះបាន ប៉ុន្តែត្រូវសងការខូចខាត។[92] បន្ថែមពីនេះទៀត ប្រសិនបើអ្នកលក់បានយល់ច្រឡំថា វត្ថុដែលជាកម្មវត្ថុនៃការលក់ជាកម្មសិទ្ធិរបស់ខ្លួន ប៉ុន្តែតាមការពិត វត្ថុនោះជារបស់អ្នកដទៃ។ ក្នុងករណីនេះ ដូចដែលបានកំណត់នៅក្នុងមាត្រាមុនផងដែរ អ្នកលក់មានករណីយកិច្ចធ្វើលទ្ធកម្មនូវ កម្មសិទ្ធិលើវត្ថុដែលជាកម្មវត្ថុនោះ ហើយផ្ទេរកម្មសិទ្ធិនោះទៅឱ្យអ្នកទិញ។ ប៉ុន្តែប្រសិនមិនអាចធ្វើបានទេអ្នកលក់ អាចរំលាយកិច្ចសន្យាដើម្បីឱ្យរួចផុតពីករណីយកិច្ចផ្ទេរសិទ្ធិនោះបាន ដោយមានលក្ខខណ្ឌសងនូវសំណងនៃការខូចខាត ដែលខ្លួនត្រូវសង តាម

[91] មាត្រា ៣៨៥ ក្រមរដ្ឋប្បវេណីព្រះរាជាណាចក្រកម្ពុជា ០៨ ធ្នូ ២០០៧។

[92] មាត្រា ៥៣១ កថាខណ្ឌទី១ ក្រមរដ្ឋប្បវេណីព្រះរាជាណាចក្រកម្ពុជា ០៨ ធ្នូ ២០០៧។

បញ្ញត្តិនៃមាត្រា ៥៣១ មុននេះ។ ប្រសិនបើអ្នកទិញដឹងនៅពេលធ្វើកិច្ចសន្យាថាវត្ថុនោះ ជាកម្មសិទ្ធិរបស់តតិយជន (ទុច្ចរិត) អ្នកទិញមិនទទួលការខូចខាតដែលមកពីហេតុដែលវត្ថុនោះជាកម្មសិទ្ធិរបស់តតិយជនទេ ដូច្នេះ អ្នកលក់អាចរំលាយនូវកិច្ចសន្យាបាន ដោយមិនចាំបាច់សងនូវសំណងនៃការខូចខាត ។[93]

លក្ខខណ្ឌនៃការទទួលខុសត្រូវក្នុងការសងសំណងនៃការខូចខាត ដែលអនុប្បទាយីបានរំលោភបំពានកិច្ចសន្យា អនុប្បទានិកអាចទាមទារដោយផ្អែកលើគោលការណ៍ដូចជា៖

១. ក្នុងករណីដែលកូនបំណុលមិនបានអនុវត្តកាតព្វកិច្ចទេ ម្ចាស់បំណុលអាចទាមទារសំណងនៃការខូចខាតដែលកើតឡើង ដោយសារការមិនអនុវត្តកាតព្វកិច្ចនោះបាន។ ប៉ុន្តែ ក្នុងករណីដែលកូនបំណុលមានសំអាងបញ្ជាក់ថា ខ្លួនគ្មានកំហុស ចំពោះការមិនអនុវត្តកាតព្វកិច្ចនោះទេ កូនបំណុលនោះត្រូវរួចផុតពីការទទួលខុសត្រូវក្នុងការសងសំណងខូចខាត ។

២. ក្នុងករណីដែលកូនបំណុលឱ្យអ្នកដទៃទៀតធ្វើជាអ្នកជំនួយដើម្បីឱ្យជួយអនុវត្ត កាតព្វកិច្ចកូនបំណុលនោះមិនអាចរួចផុតពីការទទួលខុសត្រូវក្នុងការសងសំណងខូចខាតបានទេ លើកលែងតែកូនបំណុលនោះមានសំអាងបញ្ជាក់ថា ខ្លួនគ្មានកំហុសក្នុងការជ្រើសតាំង និងការត្រួតពិនិត្យអ្នកជំនួយទេ ហើយអ្នកជំនួយនោះក៏គ្មានកំហុសដែរ។[94] គោលការណ៍នៃការសងការខូចខាតជាប្រាក់ ចំពោះសំណងនៃការខូចខាតដែលកើតឡើងដោយការមិនអនុវត្តកាតព្វកិច្ច កូនបំណុលត្រូវសងជាប្រាក់។[95]

[93] មាត្រា ៥៣២ សេចក្តីកំណត់ ក្រមរដ្ឋប្បវេណីព្រះរាជាណាចក្រកម្ពុជា ២០១០។

[94] មាត្រា ៣៩៨ ក្រមរដ្ឋប្បវេណីព្រះរាជាណាចក្រកម្ពុជា ០៨ ធ្នូ ២០០៧។

[95] មាត្រា ៤០៤ ក្រមរដ្ឋប្បវេណីព្រះរាជាណាចក្រកម្ពុជា ០៨ ធ្នូ ២០០៧។

# សេចក្តីសន្និដ្ឋាន

# សេចក្តីសន្និដ្ឋាន

តាមការសិក្សាវែកញែកខាងលើយ៉ាងលម្អិតមកឃើញថា «ការផ្ទេរបេតិកភណ្ឌពាណិជ្ជកម្ម» គឺជាវិធានក្នុងការបែងចែកទ្រព្យសម្បត្តិ ឬសកម្មភាពពាណិជ្ជកម្មរបស់អនុប្បទាយី ទៅអនុប្បទានិក ជាគោលការណ៍ដើម្បីឱ្យការផ្ទេរបេតិកភណ្ឌពាណិជ្ជកម្មនោះមានអានុភាពត្រូវធ្វើឡើងតាមរយៈ អនុប្បទានតាមរបបសន្តិកម្ម និងអនុប្បទានតាមរយៈកិច្ចសន្យា។ បន្ថែមពីនេះ ចំពោះនីតិវិធីក្នុងការផ្ទេរបេតិកភណ្ឌពាណិជ្ជកម្ម អនុប្បទាយីក៏អាចមានសិទ្ធិជ្រើសរើសនីតិវិធីក្នុងការផ្ទេរនោះតាមលក្ខខណ្ឌសន្តតិកម្ម និងតាមនីតិក្រុមហ៊ុន។ ប៉ុន្តែបើទោះបីជាយ៉ាងណាក៏ដោយជាក់ស្តែងទាំងអនុប្បទាយី និងអនុប្បទានិកច្រើនធ្វើឡើងតាមនីតិក្រុមហ៊ុន ព្រោះវាមានអានុភាពជាង ដែលអាចយកទៅអះអាងចំពោះតតិយជន និងអះអាងតាមផ្លូវច្បាប់បាន។ ហេតុនេះ ការផ្ទេរបេតិកភណ្ឌពាណិជ្ជកម្មគួរតែបន្តធ្វើឡើងតាមលក្ខខណ្ឌនីតិក្រុមហ៊ុន ដើម្បីការពារប្រយោជន៍ឱ្យជនរងគ្រោះ។

ការបង្កើតឱ្យមានការផ្ទេរបេតិកភណ្ឌពាណិជ្ជកម្ម ពិតជាមានសារៈសំខាន់ណាស់សម្រាប់អនុប្បទានិកក្នុងការទទួលបានទ្រព្យសម្បត្តិ ជាពិសេសផ្នែកពាណិជ្ជកម្ម ដូចជាអនុប្បទានិកទទួលសិទ្ធិក្នុងការគ្រប់គ្រងបន្តអភិវឌ្ឍន៍ និងសិទ្ធិក្នុងការទាមទារប្រយោជន៍ដល់ក្រុមហ៊ុន។ ក៏ប៉ុន្តែប្រសិនជាមើលនីតិវិធីនៃការផ្ទេរបេតិកភណ្ឌវិញ រាល់ការផ្លាស់ប្តូរ និងកែប្រែរបស់សហគ្រាសពាណិជ្ជកម្មវិញ គឺនៅតម្រូវឱ្យពាណិជ្ជករ ឬអ្នកតំណាងរកឯកសារដែលមានការបញ្ជាក់អំពីការផ្ទេរ ឬលក់ក្រុមហ៊ុនដែលមានការអះអាងពីសារការី ឬអាជ្ញាធរដែលមានសមត្ថកិច្ចទៅដាក់នៅក្រសួងពាណិជ្ជកម្មនៅឡើយទេ។ មិនដូចទៅនឹងក្នុងវិស័យឧស្សាហកម្មទេការចុះបញ្ជីពាណិជ្ជកម្មពាណិជ្ជករ និងក្រុមហ៊ុនពាណិជ្ជកម្មទាំងឡាយអាចធ្វើការចុះឈ្មោះក្រុមហ៊ុនរបស់ខ្លួនក្នុងបញ្ជីពាណិជ្ជកម្មតាមប្រព័ន្ធស្វ័យប្រវត្តកម្មបាន។ ដូចនេះនីតិវិធីនៃការផ្ទេរបេតិកភណ្ឌពាណិជ្ជកម្មវាធ្វើឱ្យប្រើពេលយូរ មានភាពសាំញ៉ាំ និងខាតបង់ថវិការ។ ក្នុងនោះផងដែលការផ្ទេរបេតិកភណ្ឌពាណិជ្ជកម្ម ដែលអនុប្បទានិកត្រូវទទួលបន្តពីអនុប្បទាយី ត្រូវទទួលទាំងអស់ មិនថាទ្រព្យសកម្ម និងទ្រព្យអកម្មឡើយ។

សរុបសេចក្តីមក ការផ្ទេរបេតិកភណ្ឌពាណិជ្ជកម្ម ពិតជាជួយសម្រួលការស្មុកស្មាញជាច្រើនដល់គូភាគីក្នុងការផ្ទេរទ្រព្យ ក៏ដូចជានីតិវិធីក្នុងការផ្ទេរ។ ទោះបីជាមានភាពសាំញ៉ាំ ខាតបង់ថវិការនិងប្រើពេលយូរក៏ដោយក៏នៅតែមិនទាន់គ្រប់គ្រាន់នៅឡើយ ប្រសិនបើឱ្យការផ្ទេរបេតិកភណ្ឌពាណិជ្ជកម្មមួយដំណើរការទៅល្អ យើងទាំងអស់គ្នាត្រូវរួមគ្នាគោរពច្បាប់ដោយប្រកាន់ភ្ជាប់នូវ សមភាព ភាពស្មើគ្នា សុចរិត និងស្មោះត្រង់ចំពោះគ្នា ទើបធ្វើឱ្យប្រតិបត្តិការនៃការផ្ទេរបេតិកភណ្ឌពាណិជ្ជកម្មមានភាពត្រឹមត្រូវ។

# អនុសាសន៍

# អនុសាសន៍

ក្រោយពីបានសិក្សាស្រាវជ្រាវ និងបកស្រាយទៅលើប្រធានបទ «ការផ្ទេរបេតិកភណ្ឌពាណិជ្ជកម្ម» រួចមក ការផ្ទេរបេតិកភណ្ឌ គឺជាការផ្ទេរទ្រព្យសម្បត្តិ សិទ្ធិ និងកាតព្វកិច្ចគ្រប់គ្រងក្រុមហ៊ុនរបស់អនុប្បទាយី ទៅឱ្យអ្នកទទួលបន្តដែលជាអនុប្បទានិក។ ជាក់ស្តែងការផ្ទេរបេតិកភណ្ឌដែលមានទម្រង់ធំបែបនេះវាមានលក្ខណៈពិបាក និងស្មុកស្មាញដែលតម្រូវឱ្យធ្វើតាមនីតិវិធីជាច្រើន។

ដូច្នេះហើយទើបខ្ញុំបាទទាំងពីរនាក់ មានការចាប់អារម្មណ៍ចង់សិក្សាស្រាវជ្រាវទៅលើប្រធានបទខាងលើឱ្យបានស៊ីជម្រៅ ហើយខ្ញុំទាំងពីរនាក់មានអនុសាសន៍មួយចំនួន ដើម្បីចូលរួមជាមតិយោបល់ទៅកាន់ស្ថាប័ន និងក្រសួងពាក់ព័ន្ធ ឬភាគីនៃការផ្ទេរបេតិកភណ្ឌ ក្នុងន័យជួយសម្រួលដល់ការផ្ទេរបេតិកភណ្ឌឱ្យមានភាពងាយស្រួល និងល្អប្រសើរជាងមុន និងចំណុចដែលខ្វះខាតនៃនីតិវិធី។

- ក្រសួងសាមីគប្បីមាននីតិវិធីនៃការផ្ទេរ និងកែប្រែបេតិកភណ្ឌពាណិជ្ជកម្មតាមប្រព័ន្ធស្វ័យប្រវត្តកម្ម ឱ្យស្របទៅតាមបដិវត្តន៍ឧស្សាហកម្ម ៤.០។
- គួរតែចែងឱ្យបានច្បាស់អំពីសិទ្ធិ និងកាតព្វកិច្ចរបស់អនុប្បទាយី និងអនុប្បទានិកថាមុន និងក្រោយការផ្ទេរបេតិកភណ្ឌពាណិជ្ជកម្មភាគីទាំងសងខាងមានតួនាទីអ្វីខ្លះ ជៀសវាងប៉ះពាល់សិទ្ធិរបស់ភាគីទាំងសងខាង។
- គួរតែមានកំណត់អំពីសំណងការខូចខាត និងទោសបញ្ញត្តិលើការរំលោភបំពានទៅលើសិទ្ធិរបស់អនុប្បទានិកឱ្យបានច្រើន។

# ឯកសារយោង

# ឯកសារយោង

❖ **បទដ្ឋានគតិយុត្ត**

- ច្បាប់ស្ដីពីវិសោធនកម្មច្បាប់ស្ដីពីសហគ្រាសពាណិជ្ជកម្ម ឆ្នាំ២០២២
- ច្បាប់ស្ដីពីការអនុវត្តក្រមរដ្ឋប្បវេណី ឆ្នាំ២០១១
- ក្រមរដ្ឋប្បវេណី នៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០០៧
- ច្បាប់ស្ដីពី សហគ្រាសពាណិជ្ជកម្ម ឆ្នាំ២០០៥
- ច្បាប់ស្ដីពី ប្រកាសនីយបត្រតក្កកម្ម វិញ្ញាបនបត្រម៉ូដែលមានប្រយោជន៍ និងគំនូរឧស្សាហកម្ម ឆ្នាំ ២០០២
- ច្បាប់ស្ដីពី ម៉ាក ពាណិជ្ជនាម និងអំពើនៃការប្រកួតប្រជែងមិនស្មោះត្រង់ ឆ្នាំ២០០១
- ច្បាប់ស្ដីពី វិធានពាណិជ្ជកម្ម និងបញ្ជីពាណិជ្ជកម្ម ឆ្នាំ១៩៩៩
- ច្បាប់ស្ដីពីការងារ ឆ្នាំ១៩៩៧
- ប្រកាសលេខ ១៤២ នៃក្រសួងពាណិជ្ជកម្មស្ដីពី បែបបទ និងនីតិវិធីចុះបញ្ជីពាណិជ្ជកម្មនូវរាល់ការផ្លាស់ប្ដូរ និងកែប្រែរបស់សហគ្រាស ក្រុមហ៊ុន ឆ្នាំ២០១៥

❖ **សៀវភៅ និងឯកសារផ្សេងៗ**

- សេចក្ដីកំណត់ចំពោះមាត្រានីមួយៗ នៃក្រមរដ្ឋប្បវេណីភាគ១ ដល់ភាគ៦ បោះពុម្ពនៅក្នុងខែមីនា ឆ្នាំ ២០១០
- សៀវភៅសិក្សាស្ដីពី ដំណោះស្រាយវិវាទក្រៅប្រព័ន្ធតុលាការ ឆ្នាំ២០១០
- សន្ទានុក្រមរដ្ឋប្បវេណី បោះពុម្ពដោយទីស្ដីការគណៈរដ្ឋមន្ត្រី ឆ្នាំ២០០៧
- កៅ មុយថង, ច្បាប់ពាណិជ្ជកម្ម, បោះពុម្ពលើកទី៣ ឆ្នាំ២០១៥

❖ **គេហទំព័រ**

- The New York Times <https://archive.nytimes.com/dealbook.nytimes.com/2012/04/09/facebook-buys-instagram-for-1-billion/ > ចូលមើលថ្ងៃទី០៦ ខែសីហា ឆ្នាំ២០២៣។
- កម្ពុជាថ្មី KAMPUCHEA THMEY DAILY <https://m.postkhmer.com/business/2022-02-21-1124-232046.html?fbclid=IwAR1WwVzaMRwnhY7J_pUOhkTsNIN3B78tC_vKV6Y_ykvfkUEb_OGBHwmbL54_aem_AUu9gLVFUID9uGqq-

GFSiDYIfydU7hZwgz75CVwB24v2xwd1NjiXY0IKvo5C4_rTtGw > ចូលមើលថ្ងៃទី០៦ ខែ
សីហា ឆ្នាំ២០២៣។

# ឧបសម្ព័ន្ធ

# បញ្ជីឧបសម្ព័ន្ធ

| ល.រ | ឈ្មោះ | លេខឧបសម្ព័ន្ធ |
|---|---|---|
| ១ | បទដ្ឋានគតិយុត្ត | ឧបសម្ព័ន្ធទី១ |
| ២ | ប្រកាសលេខ ១៤២ នៃក្រសួងពាណិជ្ជកម្មស្តីពី បែបបទ និងនីតិវិធីចុះបញ្ជីពាណិជ្ជកម្មនូវរាល់ការផ្លាស់ប្តូរ និងកែប្រែរបស់សហគ្រាស ក្រុមហ៊ុន ចុះថ្ងៃទី០៣ ខែមិថុនា ឆ្នាំ២០១៥ | ឧបសម្ព័ន្ធទី២ |
| ៣ | សេចក្តីប្រកាសព័ត៌មានលេខ ២២០៤២ ឃ.ថ អ/ប នៃអភិបាលបណ្តោះអាសន្នស្តីពីការផ្ទេរក្រុមហ៊ុន Opennet ទៅឱ្យក្រុមហ៊ុន Ezecom | ឧបសម្ព័ន្ធទី៣ |

**មាត្រា ១១៥៥.–** មូលហេតុនៃការចាប់ផ្ដើមធ្វើសន្តតិកម្ម

១-សន្តតិកម្ម ត្រូវចាប់ផ្ដើមដោយមរណភាពរបស់មតកជន ។

២-សន្តតិកម្ម ត្រូវធ្វើឡើងដោយផ្អែកតាមបញ្ញត្តិនៃច្បាប់ ឬ ដោយផ្អែកតាមឆន្ទៈរបស់មតកជន ។ សន្តតិកម្មដោយផ្អែកតាមបញ្ញត្តិនៃច្បាប់ ហៅថា សន្តតិកម្មតាមច្បាប់ សន្តតិកម្មដោយផ្អែកតាមឆន្ទៈរបស់មតកជន ហៅថា សន្តតិកម្មមានបណ្ដាំ ។

**មាត្រា ១១៥៩.–** សន្តតិជនដែលមានលំដាប់ទី ២

១-បើមតកជនពុំមានបច្ឆាញាតិផ្ទាល់ដែលត្រូវក្លាយជាសន្តតិជនទេ បុព្វញាតិផ្ទាល់របស់មតកជននោះ ត្រូវក្លាយជាសន្តតិជន ។ ប៉ុន្តែ រវាងបុគ្គលដែលមានថ្នាក់ញាតិខុសគ្នា ត្រូវយកបុព្វញាតិដែលនៅជិតជាង ជាមុន ។

២-ប្រសិនបើបុព្វញាតិផ្ទាល់ដែលត្រូវក្លាយជាសន្តតិជន មានចំនួនច្រើននាក់ បុព្វ-ញាតិផ្ទាល់នីមួយៗត្រូវទទួលចំណែកមត៌កស្មើៗគ្នា ។

**មាត្រា ១១៦០.–** សន្តតិជនដែលមានលំដាប់ទី ៣

១-បើមតកជនពុំមានទាំងបច្ឆាញាតិផ្ទាល់ ទាំងបុព្វញាតិផ្ទាល់ ដែលត្រូវក្លាយជាសន្តតិជនទេ បងប្អូនបង្កើតរបស់មតកជននោះ ត្រូវក្លាយជាសន្តតិជន ។

២-បើបងប្អូនបង្កើតមានចំនួនច្រើននាក់ បងប្អូនបង្កើតម្នាក់ៗត្រូវបានចំណែកមត៌កភាគស្មើៗគ្នា ។ ប៉ុន្តែ ចំណែកមត៌ករបស់បងប្អូនបង្កើតដែលមានឪពុក ឬ ម្ដាយតែម្ខាងដូចគ្នា ត្រូវមាន ១ ភាគ ២ (មួយភាគពីរ) នៃចំណែកមត៌ករបស់បងប្អូនដែលមានឪពុក និង ម្ដាយទាំងសងខាងដូចគ្នា ។

៣-បញ្ញត្តិនៃកថាខណ្ឌទី ១ នៃមាត្រា ១១៥៧ (សន្តតិកម្មជំនួស) និង បញ្ញត្តិនៃមាត្រា ១១៥៨ (ចំណែកមត៌ក ក្នុងករណីនៃសន្តតិកម្មជំនួស) ខាងលើនេះ ត្រូវយកមកអនុវត្តដូចគ្នាផងដែរ ចំពោះករណីដែលបងប្អូនបង្កើតរបស់មតកជនដែលត្រូវក្លាយជាសន្តតិជន យោងតាមបញ្ញត្តិនៃកថាខណ្ឌទី ១ និង ទី ២ ខាងលើនេះ បានទទួលមរណភាពនៅមុនពេលចាប់ផ្ដើមសន្តតិកម្ម ។

**មាត្រា ១១៦១.–** សន្តតិកម្មរបស់សហព័ទ្ធ

១-សហព័ទ្ធរបស់មតកជន ត្រូវក្លាយជាសន្តតិជនជានិច្ច ។

២-នៅក្នុងករណីដែលសហព័ទ្ធរបស់មតកជន ត្រូវក្លាយជាសន្តតិជន បើមានបុគ្គលផ្សេងទៀតក្រៅពីសហព័ទ្ធ ត្រូវជាសន្តតិជនដែរ ដោយយោងតាមបញ្ញត្តិនៃផ្នែកទី ១ (សន្តតិជន) ខាងលើនេះ សហព័ទ្ធនោះត្រូវមានលំដាប់ស្មើគ្នានឹងបុគ្គលនោះ ។

**មាត្រា ១១៥៦.–** សន្តតិជនដែលមានលំដាប់ទី ១

១-កូនរបស់មតកជន ត្រូវក្លាយជាសន្តតិជនដែលមានលំដាប់ទី ១ ។

២-កូនរបស់មតកជន ទោះបីជាកូនបង្កើតក្តី ឬ កូនសុំក្តី ត្រូវមានចំណែកមត៌កស្មើៗគ្នា ។

**មាត្រា ១១៥៧.–** សន្តតិកម្មជំនួស

១-បើកូនរបស់មតកជន បានទទួលមរណភាព នៅមុនពេលចាប់ផ្តើមសន្តតិកម្ម ឬ បានបាត់បង់សិទ្ធិសន្តតិកម្ម ដោយត្រូវនឹងល័ក្ខខ័ណ្ឌដែលបានកំណត់ក្នុងបញ្ញត្តិនៃមាត្រា ១១៥០ (អភ័ព្វបុគ្គលនៃសន្តតិកម្ម ជាអាទិ៍) ខាងលើនេះ ឬ ដោយការផ្តាច់មត៌ក កូនរបស់បុគ្គលនោះ ត្រូវក្លាយទៅជាសន្តតិជនជំនួស ។ ប៉ុន្តែ បញ្ញត្តិនេះមិនត្រូវយកមកអនុវត្តឡើយ ចំពោះបុគ្គលដែលមិនមែនជាបច្ឆាញាតិផ្ទាល់របស់មតកជន ។

២-បញ្ញត្តិនៃកថាខណ្ឌទី ១ ខាងលើនេះ ត្រូវយកមកអនុវត្តជាបន្តបន្ទាប់ ចំពោះករណីដែលមានមូលហេតុដូចបានកំណត់នៅក្នុងកថាខណ្ឌទី ១ ដដែលនេះ ចំពោះអ្នកទទួលសន្តតិកម្មជំនួស ។

**មាត្រា ១១៥០.–** អភ័ព្វបុគ្គលនៃសន្តតិកម្ម ជាអាទិ៍

បុគ្គលដែលបានកំណត់ដូចខាងក្រោមនេះ ពុំអាចក្លាយជាសន្តតិជន ឬ ពុំអាចទទួលទ្រព្យសម្បត្តិតាមមតកសាសន៍បានឡើយ :

ក-បុគ្គលដែលបានទទួលទោស ដោយមានចេតនាធ្វើឃាត ឬ ប៉ុនប៉ងធ្វើឃាតលើមតកជន ឬ លើជនដែលមានលំដាប់សន្តតិកម្មមុន ឬ លំដាប់ស្មើគ្នា ទោះដោយផ្ទាល់ក្តី ឬ ដោយប្រយោលក្តី ។

ខ-បុគ្គលដែលដឹងអំពីការសម្លាប់មតកជន តែមិនបានរាយការណ៍ ឬ មិនបានប្តឹង ។ ប៉ុន្តែ បញ្ញត្តិនេះមិនត្រូវយកមកអនុវត្តឡើយ ចំពោះករណីដែលបុគ្គលនោះ មិនអាចវិនិច្ឆ័យអំពើល្អ ឬ អាក្រក់បាន ឬ ករណីដែលអ្នកសម្លាប់ជាសហព័ទ្ធ ឬ ញាតិលោហិតខ្សែផ្ទាល់របស់បុគ្គលនោះ ។

គ-បុគ្គលដែលបានរារាំងមតកជនក្នុងការធ្វើ លុបចោល ឬ កែប្រែមតក-សាសន៍ស្តីពីសន្តតិកម្ម ដោយការឆបោក ឬ គម្រាមកំហែង ។

ឃ-បុគ្គលដែលបានឱ្យមតកជនធ្វើ លុបចោល ឬ កែប្រែមតកសាសន៍ស្តីពីសន្តតិកម្ម ដោយការឆបោក ឬ គម្រាមកំហែង ។

ង-បុគ្គលដែលបានក្លែង កែបន្ថំ បំផ្លាញចោល ឬ លាក់ទុកនូវលិខិតមតក-សាសន៍ស្តីពីសន្តតិកម្មរបស់មតកជន ។

**មាត្រា ៣៣៦.–** ការបង្កើតកិច្ចសន្យាដោយសំណើ និង ស្ទីការ

១-កិច្ចសន្យាមានអានុភាពដោយសារសំណើ និង ស្ទីការត្រូវគ្នា ។

២-ទោះបីមានបញ្ញត្តិនៃកថាខណ្ឌទី ១ ខាងលើនេះក៏ដោយ ក៏កិច្ចសន្យាដែលភាគីម្ខាងទទួលករណីយកិច្ចធ្វើអនុប្បទាននូវកម្មសិទ្ធិលើអចលនវត្ថុ ឬ ករណីយកិច្ចធ្វើលទ្ធកម្មនូវកម្មសិទ្ធិលើអចលនវត្ថុ នឹងមានអានុភាព លុះត្រាតែបានធ្វើលិខិតយថាភូត ។

**មាត្រា ៣៣៧.–** និយមន័យនៃសំណើ និង ស្ទីការ

១-សំណើគឺជាការសុំបង្កើតកិច្ចសន្យាដែលធ្វើឡើងដោយមានឆន្ទៈភ្ជាប់ខ្លួនជាមួយនឹងចំណងគតិយុត្តក្នុងករណីដែលមានស្ទីការរបស់ភាគីម្ខាងទៀតចំពោះសំណើនេះ ។

២-សំណើត្រូវមានអានុភាពនៅពេលដែលសំណើនោះបានដល់ភាគីម្ខាងទៀត ។ ប៉ុន្តែ ប្រសិនបើដំណឹងអំពីការដកសំណើវិញ ដល់ភាគីម្ខាងទៀត នៅពេលព្រមគ្នានឹងពេលសំណើដល់ ឬ មុនពេលសំណើដល់ នោះអានុភាពសំណើមិនត្រូវកើតឡើយ ។

៣-ស្ទីការគឺជាការបង្ហាញឆន្ទៈដែលអ្នកទទួលសំណើយល់ព្រមចំពោះសំណើនោះ ។

៤-ស្ទីការត្រូវមានអានុភាពនៅពេលដែលស្ទីការនោះបានដល់អ្នកស្នើ ។ ប៉ុន្តែ ប្រសិនបើដំណឹងអំពីការដកស្ទីការវិញ ដល់អ្នកស្នើ នៅពេលព្រមគ្នានឹងពេលស្ទីការដល់ ឬ មុនពេលស្ទីការដល់ នោះអានុភាពនៃស្ទីការ មិនត្រូវកើតឡើយ ។

**មាត្រា ៣១១.–** និយមន័យនៃកិច្ចសន្យា

កិច្ចសន្យាគឺជាកិរិយាដែលបុគ្គលពីរនាក់ ឬ ច្រើននាក់មានឆន្ទៈត្រូវគ្នាព្រមបង្កើត កែប្រែ ឬ រំលត់នូវកាតព្វកិច្ច ។

**មាត្រា ១៤.–** ការខ្វះសមត្ថភាពខាងឆន្ទៈ

សកម្មភាពដែលភាគីបានធ្វើនៅក្នុងស្ថានភាពដែលខ្លួនមិនអាចយល់ដឹង និងវិនិច្ឆ័យបាន អំពីលទ្ធផលតាមផ្លូវច្បាប់នៃសកម្មភាពរបស់ខ្លួន អាចលុបចោលបាន ។

**មាត្រា ១៥.–** និយមន័យនៃសកម្មភាព

ពាក្យ "សកម្មភាព" ដែលត្រូវបានប្រើនៅក្នុងផ្នែកទី ៣ (សមត្ថភាពខាងឆន្ទៈ) ផ្នែកទី ៤ (សមត្ថភាពក្នុងការធ្វើសកម្មភាព) និង ផ្នែកទី ៦ (ការគ្រប់គ្រងទ្រព្យសម្បត្តិរបស់បុគ្គលដែលអវត្តមាន និង ការប្រកាសអំពីការបាត់ខ្លួន) នៃជំពូកទី ១ នេះ សំដៅទៅលើកិច្ចសន្យា និង សកម្មភាពឯកតោភាគី ។

**មាត្រា ៦.–** គោលការណ៍សមភាពនៃសមត្ថភាពទទួលសិទ្ធិ

រូបវន្តបុគ្គលគ្រប់រូប មានលក្ខណសម្បត្តិអាចក្លាយជាប្រធាននៃសិទ្ធិ និង កាតព្វកិច្ច បាន ។

**មាត្រា ១១៧៣.–** មតកសាសន៍ដោយលិខិតយថាភូត

១-មតកសាសន៍ដោយលិខិតយថាភូត ត្រូវធ្វើឡើងដោយម្ចាស់បណ្តាំ នៅចំពោះមុខសារការី តាមទម្រង់ដែលបានកំណត់នៅក្នុងកថាខណ្ឌទី ២ ខាងក្រោមនេះ ។

២-មតកសាសន៍ដោយលិខិតយថាភូត ត្រូវធ្វើឡើង ដោយយោងតាមទម្រង់ដូចខាងក្រោមនេះ :

ក-ត្រូវមានវត្តមានរបស់សាក្សីយ៉ាងតិច ២ (ពីរ) នាក់ ។

ខ-ម្ចាស់បណ្តាំត្រូវប្រាប់ផ្ទាល់មាត់ នូវខ្លឹមសារនៃមតកសាសន៍ ចំពោះសារការី ។

គ-សារការីត្រូវសរសេរនូវអត្ថន័យនៃមតកសាសន៍របស់ម្ចាស់បណ្តាំនោះ ជាលាយល័ក្ខណ៍អក្សរ ហើយត្រូវសូត្រឱ្យម្ចាស់បណ្តាំ និង សាក្សីនោះស្តាប់ ។

ឃ-បន្ទាប់ពីម្ចាស់បណ្តាំ និង សាក្សី បានទទួលស្គាល់ថាកំណត់ជាលាយល័ក្ខណ៍អក្សរនោះត្រឹមត្រូវហើយ ជននីមួយៗនោះត្រូវធ្វើឱ្យមានភាពច្បាស់លាស់នៅលើឯកសារអំពីឈ្មោះ អាយុ និង លំនៅឋាន ហើយ ត្រូវចុះហត្ថលេខា រៀងៗខ្លួន ។ ប៉ុន្តែបើម្ចាស់បណ្តាំ មិនអាចសរសេរអក្សរ ឬ មិនអាចចុះហត្ថលេខាបានទេ សារការីអាចជំនួសការសរសេរ និង ហត្ថលេខាដូចកំណត់ខាងលើនេះ ដោយសរសេរឈ្មោះ អាយុ និង លំនៅឋានរបស់ជននោះ ហើយត្រូវសរសេរបន្ថែមនូវហេតុនោះផង ។



ង-សារការីត្រូវសរសេរថ្ងៃខែឆ្នាំ ហើយត្រូវចុះហត្ថលេខា ។

**មាត្រា ១១៧៤.-** មតកសាសន៍ដោយលិខិតឯកជន

១-មតកសាសន៍ដោយលិខិតឯកជន ត្រូវធ្វើឡើង ដោយម្ចាស់បណ្ដាំសរសេរពាក្យទាំងអស់ និង ចុះថ្ងៃខែឆ្នាំ ដោយខ្លួនឯង ហើយត្រូវចុះហត្ថលេខាលើលិខិតនោះ ។ មតក-សាសន៍ដោយលិខិតឯកជនដែលត្រូវបានសរសេរជំនួសដោយអ្នកដទៃ ឬ ដែលត្រូវបានសរសេរដោយប្រើម៉ាស៊ីនដូចជាអង្គុលីលេខ ជាអាទិ៍ នឹងត្រូវចាត់ទុកជាមោឃៈ ។

២-ការបន្ថែម ការលុប ឬ ការកែប្រែផ្សេងទៀត នៅក្នុងមតកសាសន៍ដោយលិខិតឯកជន ពុំមានអានុភាពឡើយ បើម្ចាស់បណ្ដាំមិនបានបង្ហាញនូវកន្លែង ហើយសរសេរបន្ថែមនូវហេតុនៃការកែប្រែនោះ ជាពិសេសបើមិនបានចុះហត្ថលេខាទេ ។

**មាត្រា ១១៧៥.-** មតកសាសន៍ដោយលិខិតសម្ងាត់

មតកសាសន៍ដោយលិខិតសម្ងាត់ ត្រូវធ្វើឡើង ដោយយោងតាមទម្រង់ដូចខាងក្រោមនេះ :

ក-ម្ចាស់បណ្ដាំត្រូវចុះហត្ថលេខាលើលិខិតនោះ ។

ខ-ម្ចាស់បណ្ដាំត្រូវដាក់លិខិតនោះក្នុងស្រោមបិទជិត ហើយត្រូវចុះហត្ថលេខា ឬ សរសេរសញ្ញាសំគាល់ ឬ មធ្យោបាយផ្សេងទៀតដែលអាចវិនិច្ឆ័យបានអំពីការបានបើក ឬ មិនបានបើកស្រោមលិខិតនោះ នៅមាត់ស្រោមលិខិតនោះ ។

គ-ម្ចាស់បណ្ដាំត្រូវដាក់លិខិតដែលបានបិទជិតនោះ នៅចំពោះមុខសារការីម្នាក់ និង សាក្សី ២ (ពីរ) នាក់ និង ធ្វើសេចក្ដីថ្លែងការណ៍ថា លិខិតនេះជាលិខិតមតកសាសន៍របស់ខ្លួន ហើយបើមានជនក្រៅពីសាមីខ្លួនបានសរសេរ ត្រូវធ្វើសេចក្ដីថ្លែងការណ៍អំពីឈ្មោះ និង លំនៅឋានរបស់ជនដែលបានសរសេរនោះ ។

ឃ-សារការីត្រូវចុះថ្ងៃខែឆ្នាំដែលសាមីខ្លួនបានដាក់លិខិតនោះ និង សរសេរសេចក្ដីថ្លែងការណ៍របស់ម្ចាស់បណ្ដាំ នៅលើលិខិតដែលបិទជិតនោះ ហើយត្រូវចុះហត្ថ-លេខាលើលិខិតនោះ ជាមួយគ្នានឹងសាក្សី និង ម្ចាស់បណ្ដាំ ។

**មាត្រា ១២៥៤.-** ការយល់ព្រមទាំងស្រុង

បើសន្តតិជនបានយល់ព្រមទាំងស្រុង ត្រូវទទួលបន្តដោយគ្មានកម្រិត នូវសិទ្ធិ និង កាតព្វកិច្ចរបស់មតកជននោះ ។

**មាត្រា ១១៧០.–** ភាពចាំបាច់នៃទម្រង់មតកសាសន៍

១-មតកសាសន៍ ពុំអាចធ្វើបានឡើយ បើពុំផ្អែកតាមទម្រង់ដែលបានកំណត់ក្នុងក្រមនេះទេ ។

២-មតកសាសន៍ដែលធ្វើមិនត្រូវនឹងទម្រង់ណាមួយក្នុងបញ្ញត្តិនៃក្រមនេះ ត្រូវចាត់ទុកជាមោឃៈ ។ ប៉ុន្តែ មតកសាសន៍ដែលគ្មានការចុះថ្ងៃខែឆ្នាំ ត្រូវចាត់ទុកថាមានសុពលភាព លុះត្រាតែមតកសាសន៍នោះ មិនផ្ទុយនឹងមតកសាសន៍ផ្សេងទៀតដែលបានធ្វើដោយម្ចាស់បណ្ដាំដូចគ្នានេះ ។ នៅក្នុងករណីដែលមតកសាសន៍ដែលគ្មានការចុះថ្ងៃខែឆ្នាំ មានចំនួនច្រើន ហើយបើមតកសាសន៍ទាំងនេះ ផ្ទុយនឹងគ្នា អានុភាពនៃមតកសាសន៍ទាំងនោះត្រូវកាត់បន្ថយគ្នាទៅវិញទៅមក ។

**មាត្រា ១២៥៦.–** ការយល់ព្រមដោយមានកម្រិត

១-សន្តតិជនអាចយល់ព្រម ដោយបម្រុងទុកនូវសំណងកាតព្វកិច្ច និង អច្ច័យទានរបស់មតកជនបាន ត្រឹមកម្រិតនៃទ្រព្យសម្បត្តិដែលខ្លួនបានទទួលតាមរយៈសន្តតិកម្ម តែប៉ុណ្ណោះ ។

២-បើសន្តតិជនមានច្រើននាក់ ការយល់ព្រមដោយកម្រិតនេះ អាចធ្វើបាន លុះត្រាតែសហសន្តតិជននោះបានធ្វើដោយរួមគ្នាទាំងអស់ ។

**មាត្រា ១២៥៧.–** វិធីនៃការយល់ព្រមដោយកម្រិត

សន្តតិជនដែលមានបំណងចង់យល់ព្រមដោយកម្រិត ត្រូវធ្វើបញ្ជីសារពើភ័ណ្ឌ ហើយត្រូវដាក់ពាក្យសុំអំពីការយល់ព្រមដោយកម្រិតនោះ ទៅតុលាការ នៅក្នុងអំឡុងពេលដែលបានកំណត់នៅក្នុងកថាខណ្ឌទី ១ នៃមាត្រា ១២៤៨ (អំឡុងពេលនៃការយល់ព្រម ឬ ការបោះបង់) នៃក្រមនេះ ។

**មាត្រា ១២១៩.–** ការធ្វើបញ្ជីសារពើភ័ណ្ឌនៃទ្រព្យសម្បត្តិ

១-អ្នកប្រតិបត្តិមតកសាសន៍ត្រូវធ្វើបញ្ជីសារពើភ័ណ្ឌនៃទ្រព្យសម្បត្តិ ហើយប្រគល់បញ្ជីសារពើភ័ណ្ឌនោះទៅឱ្យសន្តតិជន ដោយគ្មានការយឺតយ៉ាវ ។

២-សន្តតិជន អាចមានវត្តមាន នៅពេលដែលអ្នកប្រតិបត្តិមតកសាសន៍ ធ្វើបញ្ជីសារពើភ័ណ្ឌនៃទ្រព្យសម្បត្តិបាន ។

**មាត្រា ១២២០.–** សិទ្ធិអំណាច មុខនាទី នៃអ្នកប្រតិបត្តិមតកសាសន៍

អ្នកប្រតិបត្តិមតកសាសន៍ មានសិទ្ធិ និង ករណីយកិច្ចក្នុងការគ្រប់គ្រងមត៌ក និង ធ្វើនូវរាល់សកម្មភាពផ្សេងទៀតដែលចាំបាច់ ដើម្បីប្រតិបត្តិមតកសាសន៍ ។

**មាត្រា ១២២១.–** ការបាត់បង់នូវសិទ្ធិចាត់ចែងរបស់សន្តតិជន

១-បើមានអ្នកប្រតិបត្តិមតកសាសន៍ សន្តតិជនពុំអាចចាត់ចែងមតិក ឬ ធ្វើសកម្មភាពផ្សេងទៀតដែលនាំឱ្យរារាំងដល់ការប្រតិបត្តិមតកសាសន៍បានឡើយ ។

២-ការចាត់ចែងដែលបានធ្វើផ្ទុយនឹងបញ្ញត្តិនៃកថាខណ្ឌទី ១ ខាងលើនេះ ពុំមានអានុភាពឡើយ ។

**មាត្រា ១២២២.–** ការប្រតិបត្តិមតកសាសន៍ ចំពោះទ្រព្យសម្បត្តិដែលបានកំណត់ជាក់លាក់

ក្នុងករណីមតកសាសន៍ ទាក់ទងនឹងទ្រព្យសម្បត្តិដែលបានកំណត់ជាក់លាក់ បញ្ញត្តិចាប់ពីមាត្រា ១២១៩ (ការធ្វើបញ្ជីសារពើភ័ណ្ឌនៃទ្រព្យសម្បត្តិ) រហូតដល់មាត្រា ១២២១

**មាត្រា ៣៣៧.–** និយមន័យនៃសំណើ និង ស្វីការ

១-សំណើគឺជាការសុំបង្កើតកិច្ចសន្យាដែលធ្វើឡើង ដោយមានឆន្ទៈភ្ជាប់ខ្លួនជាមួយនឹងចំណងគតិយុត្តក្នុងករណីដែលមានស្វីការរបស់ភាគីម្ខាងទៀតចំពោះសំណើនេះ ។

២-សំណើត្រូវមានអានុភាពនៅពេលដែលសំណើនោះបានដល់ភាគីម្ខាងទៀត ។ ប៉ុន្តែ ប្រសិនបើដំណឹងអំពីការដកសំណើវិញ ដល់ភាគីម្ខាងទៀត នៅពេលព្រមគ្នានឹងពេលសំណើដល់ ឬ មុនពេលសំណើដល់ នោះអានុភាពសំណើមិនត្រូវកើតឡើយ ។

៣-ស្វីការគឺជាការបង្ហាញឆន្ទៈដែលអ្នកទទួលសំណើយល់ព្រមចំពោះសំណើនោះ ។

៤-ស្វីការត្រូវមានអានុភាពនៅពេលដែលស្វីការនោះបានដល់អ្នកស្នើ ។ ប៉ុន្តែ ប្រសិនបើដំណឹងអំពីការដកស្វីការវិញ ដល់អ្នកស្នើ នៅពេលព្រមគ្នានឹងពេលស្វីការដល់ ឬ មុនពេលស្វីការដល់ នោះអានុភាពនៃស្វីការ មិនត្រូវកើតឡើយ ។

**មាត្រា ៥០១.–** ភាពដែលអាចធ្វើអនុប្បទានសិទ្ធិលើបំណុល និង ការសន្យាពិសេសហាមមិនឱ្យធ្វើអនុប្បទាន

១-សិទ្ធិលើបំណុល អាចធ្វើអនុប្បទានទៅឱ្យអ្នកផ្សេងបាន លើកលែងតែក្នុងករណីដែលសិទ្ធិនោះមានលក្ខណៈមិនអាចធ្វើអនុប្បទានបាន ។ ក្នុងករណីនេះ អនុប្បទានិកនឹងក្លាយជាម្ចាស់បំណុលថ្មី ។



២-ទោះបីជាសិទ្ធិលើបំណុលមានលក្ខណៈអាចធ្វើអនុប្បទានបានក៏ដោយ ក៏គូភាគីអាចហាមមិនឱ្យធ្វើអនុប្បទាន ដោយការបង្ហាញឆន្ទៈបានដែរ ។

៣-ការបង្ហាញឆន្ទៈដែលបានកំណត់នៅក្នុងកថាខណ្ឌទី ២ ខាងលើនេះ មិនអាចតតាំងចំពោះតតិយជនដែលមិនបានដឹងអំពីការបង្ហាញឆន្ទៈនោះបានឡើយ ។ ប៉ុន្តែ បញ្ញត្តិនេះមិនត្រូវយកមកអនុវត្តឡើយ ចំពោះករណីដែលតតិយជននោះមានកំហុសដ៏ធ្ងន់ធ្ងរ ។

**មាត្រា ៥០២.–** ការបង្កើតអនុប្បទានសិទ្ធិលើបំណុល

អនុប្បទានសិទ្ធិលើបំណុល ត្រូវមានអានុភាព តែដោយការព្រមព្រៀងគ្នារវាងម្ចាស់បំណុលដែលមានបំណងធ្វើអនុប្បទានសិទ្ធិលើបំណុល និង អនុប្បទានិកប៉ុណ្ណោះ ។ ប៉ុន្តែ ដើម្បីយកអនុប្បទានសិទ្ធិលើបំណុលនេះទៅតតាំង ចំពោះកូនបំណុល និង តតិយជនត្រូវមានល័ក្ខខ័ណ្ឌតតាំងដែលបានកំណត់នៅក្នុងមាត្រា ៥០៣ (ល័ក្ខខ័ណ្ឌតតាំងនៃអនុប្បទានសិទ្ធិលើបំណុលដែលមានកំណត់ឈ្មោះ) ខាងក្រោមនេះ ។

**មាត្រា ៥០៣.–** ល័ក្ខខ័ណ្ឌតតាំងនៃអនុប្បទានសិទ្ធិលើបំណុលដែលមានកំណត់ឈ្មោះ

១-អនុប្បទានសិទ្ធិលើបំណុលដែលមានកំណត់ឈ្មោះ មិនអាចតតាំងចំពោះកូនបំណុល ឬ តតិយជនផ្សេងទៀតបានឡើយ បើអនុប្បទាយីមិនបានជូនដំណឹងទៅកូនបំណុល ឬ កូនបំណុលមិនបានយល់ព្រម ចំពោះអនុប្បទាយី ឬ អនុប្បទានិក ។

២-ការជូនដំណឹង ឬ ការយល់ព្រមដែលបានកំណត់នៅក្នុងកថាខណ្ឌទី ១ ខាងលើនេះ មិនអាចតតាំងនឹងតតិយជន ក្រៅពីកូនបំណុលបានឡើយ បើមិនបានធ្វើឡើងដោយលិខិតដែលមានកាលបរិច្ឆេទស្ពាល ។

**មាត្រា ៧៨៣.–** អត្ថន័យនៃឯកសិទ្ធិទូទៅ

បុគ្គលដែលមានសិទ្ធិលើបំណុលដែលកើតឡើងដោយសារមូលហេតុណាមួយដូចខាងក្រោមនេះ មានឯកសិទ្ធិលើទ្រព្យទាំងអស់ របស់កូនបំណុល :

ក-សោហ៊ុយចំណាយសម្រាប់ប្រយោជន៍រួម ។

ខ-សិទ្ធិលើបំណុលរបស់កម្មករនិយោជិត ។

គ-សោហ៊ុយសម្រាប់បុណ្យសព ។

ឃ-ការផ្គត់ផ្គង់នូវវត្ថុសម្រាប់ប្រើប្រាស់ប្រចាំថ្ងៃ ។

**មាត្រា ៧៨៤.–** ឯកសិទ្ធិចំពោះសោហ៊ុយចំណាយសម្រាប់ប្រយោជន៍រួម

១-ឯកសិទ្ធិចំពោះសោហ៊ុយចំណាយសម្រាប់ប្រយោជន៍រួម មានអត្ថិភាពចំពោះសោហ៊ុយចំណាយដើម្បីថែរក្សាទ្រព្យ ឬ ជម្រះបញ្ជី ឬ ចែកចំណែកទ្រព្យ ដែលបានចេញសម្រាប់ប្រយោជន៍រួមរបស់ម្ចាស់បំណុលនីមួយៗ ។

២-ក្នុងចំណោមសោហ៊ុយចំណាយដែលបានកំណត់នៅក្នុងកថាខណ្ឌទី ១ ខាងលើនេះ ចំពោះសោហ៊ុយចំណាយដែលមានប្រយោជន៍ដល់ម្ចាស់បំណុលតែមួយចំនួន ឯកសិទ្ធិចំពោះសោហ៊ុយចំណាយនោះ មានអត្ថិភាពចំពោះតែម្ចាស់បំណុលដែលបានទទួលប្រយោជន៍ពីសោហ៊ុយចំណាយនោះតែប៉ុណ្ណោះ ។

**មាត្រា ៧៨៥.–** ឯកសិទ្ធិចំពោះសិទ្ធិលើបំណុលរបស់កម្មករនិយោជិត

ឯកសិទ្ធិចំពោះសិទ្ធិលើបំណុលរបស់កម្មករនិយោជិត មានអត្ថិភាពចំពោះសិទ្ធិលើបំណុលទាំងអស់ ដែលកម្មករនិយោជិតត្រូវទទួលពីនិយោជក ដោយផ្អែកលើកិច្ចសន្យាការងារ ។

**មាត្រា ៣៨៤.–** ករណីយកិច្ចរបស់កូនបំណុលក្នុងការអនុវត្តកាតព្វកិច្ច

១-កូនបំណុលត្រូវអនុវត្តកាតព្វកិច្ចរបស់ខ្លួន ឱ្យស្របទៅតាមខ្លឹមសារនៃកិច្ចសន្យា និង គោលការណ៍នៃភាពសុចរិត និង ភាពស្មោះត្រង់ ។

២-ការអនុវត្តតាមបញ្ញត្តិនៃកថាខណ្ឌទី ១ ខាងលើនេះ ត្រូវចាត់ទុកជាការសង ដែលនាំឱ្យកាតព្វកិច្ចរលត់ ។

**មាត្រា ៣៨៥.–** សិទ្ធិរបស់ម្ចាស់បំណុលក្នុងការទាមទារឱ្យអនុវត្តកាតព្វកិច្ច

១-ម្ចាស់បំណុលអាចទាមទារឱ្យកូនបំណុលអនុវត្តកាតព្វកិច្ចតាមផ្លូវតុលាការ ។

២-ទោះបីជាមានបញ្ញត្តិនៃកថាខណ្ឌទី ១ ខាងលើនេះក៏ដោយ ម្ចាស់បំណុលមិនអាចទាមទារឱ្យអនុវត្តកាតព្វកិច្ច តាមផ្លូវតុលាការបានឡើយ ក្នុងករណីដែលមានការព្រមព្រៀងគ្នារវាងភាគីនៃកិច្ចសន្យាថា មិនទាមទារឱ្យអនុវត្ត តាមផ្លូវតុលាការ ។

៣-ទោះបីជាមានការកម្រិតនូវសិទ្ធិទាមទារឱ្យអនុវត្តកាតព្វកិច្ចតាមផ្លូវតុលាការ ដោយសារមានករណីត្រូវនឹងកថាខណ្ឌទី ២ ខាងលើនេះក៏ដោយ ប្រសិនបើកូនបំណុលបានអនុវត្តកាតព្វកិច្ចដោយស្ម័គ្រចិត្តហើយ ម្ចាស់បំណុលអាចទទួល និង រក្សាទុកនូវតាវកាលិកនេះ ដោយចាត់ទុកថាជាការសងបាន ។

**មាត្រា ១២៥៦.–** ការយល់ព្រមដោយមានកម្រិត

១-សន្តតិជនអាចយល់ព្រម ដោយបម្រុងទុកនូវសំណងកាតព្វកិច្ច និង អច្ច័យទានរបស់មតកជនបាន ត្រឹមកម្រិតនៃទ្រព្យសម្បត្តិដែលខ្លួនបានទទួលតាមរយៈសន្តតិកម្ម តែប៉ុណ្ណោះ ។

២-បើសន្តតិជនមានច្រើននាក់ ការយល់ព្រមដោយកម្រិតនេះ អាចធ្វើបាន លុះត្រាតែសហសន្តតិជននោះបានធ្វើដោយរួមគ្នាទាំងអស់ ។

(កំណត់)

មាត្រានេះចែងស្ដីពីការយល់ព្រមដោយមានកម្រិត ហើយកំណត់និយមន័យនេះ ជាអាទិ៍ ។

កថាខណ្ឌទី ១ ចែងអំពីនិយមន័យនៃការយល់ព្រមដោយមានកម្រិត ដែលមានខ្លឹមសារថា ធ្វើសន្តតិកម្មដែលបម្រុងសម្រាប់សងនូវកាតព្វកិច្ចដែលបានទទួលដោយសន្តតិកម្ម ដោយសងត្រឹមកម្រិតនៃទ្រព្យសម្បត្តិដែលបានទទួល ដោយសន្តតិកម្ម ។ មានន័យថា សន្តតិជនក្លាយទៅជាកូនបំណុល ដោយទទួលសន្តតិកម្មនូវកាតព្វកិច្ចទាំងអស់របស់មតកជន ក៏ប៉ុន្តែ សន្តតិជនអាចកម្រិតការទទួលខុសត្រូវសង ត្រឹមតែកម្រិតនៃមតិកដែលបានទទួលដោយសន្តតិកម្មបាន ។ ប្រសិនបើសន្តតិជនស្ម័គ្រចិត្តសងកាតព្វកិច្ចលើសពីមតិកសកម្មក៏ដោយ ក៏មិនមែនជាការសងដោយគ្មានកាតព្វកិច្ចដែរ ដូច្នេះការសងនេះ មានសុពលភាព ។ តាមទ្រឹស្ដីសិក្សាចំណែកនៃកាតព្វកិច្ចដែលលើសមតិកសកម្មនេះ គេហៅថា កាតព្វកិច្ចធម្មជាតិ ហើយមានលក្ខណៈដូចកាតព្វកិច្ចដែលផុតអំឡុងពេលអាជ្ញាយុកាលដែរ ។

កថាខណ្ឌទី ២ ចែងថា ចំពោះករណីនៃសហសន្តតិកម្ម ការយល់ព្រមដោយមានកម្រិតត្រូវធ្វើឡើងរួមទាំងអស់គ្នា ។ ពេលយល់ព្រមដោយមានកម្រិត ចាំបាច់ត្រូវមាននីតិវិធីជម្រះបញ្ជីដើម្បីឱ្យមានសមភាពក្នុងការសងចំពោះម្ចាស់បំណុលរបស់មតកជន ហើយសហសន្តតិកម្មទាំងអស់ត្រូវមានការឯកភាពក្នុងការសងនោះ ។ នេះក៏ព្រោះថា ប្រសិនបើមានតែសន្តតិជនមួយចំនួនបានយល់ព្រមទាំងស្រុង ហើយបានអះអាងនូវចំណែកមតិកនោះ ការជម្រះបញ្ជីនូវមតិកទាំងអស់នឹងគ្មានដំណើរការល្អទេ ។ ប្រសិនបើសន្តតិជនមួយចំនួនបានបោះបង់សន្តតិកម្ម នោះគ្មានបញ្ហាចោទទេ ។ ជនដែលបាន



បោះបង់សន្តតិកម្ម ត្រូវចាត់ទុកថា មិនមែនជាសន្តតិជននោះតាំងពីដំបូងមក ហេតុនេះហើយ សន្តតិជនដែលនៅសល់នោះយល់ព្រមដោយមានកម្រិតរួមគ្នាទៅបានហើយ ។ម្យ៉ាងទៀត មានករណីដែលសន្តតិជនមួយចំនួន ក្នុងសន្តតិជនដែលយល់ព្រមដោយមានកម្រិត មានហេតុដែលបានកំណត់នៅក្នុងបញ្ញត្តិនៃមាត្រា ១២៥៩ កថាខណ្ឌទី ១ ហើយត្រូវទទួលខុសត្រូវដូចគ្នានឹងការយល់ព្រមទាំងស្រុង ដោយយោងតាមកថាខណ្ឌទី ២ នៃមាត្រានោះ ។ ក៏ប៉ុន្តែ ក្នុងករណីនេះ មតិកទាំងអស់ត្រូវឆ្លងកាត់តាមនីតិវិធីជម្រះបញ្ជី ដូច្នេះ សន្តតិជនដែលនឹងទទួលខុសត្រូវ តាមបញ្ញត្តិនៃកថាខណ្ឌទី ២ នៃមាត្រា ១២៥៩ នោះ មិនអាចអះអាងថា ខ្លួនមានសិទ្ធិលើចំណែកមតិកសកម្មដែលមិនទាន់បញ្ចប់នីតិវិធីនៃការជម្រះបញ្ជីនេះឡើយ ។

(មាត្រាពាក់ព័ន្ធ)

មាត្រា ៩២២ មាត្រា ៩២៣ នៃក្រមរដ្ឋប្បវេណីជប៉ុន និង មាត្រា ៥៥០ មាត្រា ៦០៤ នៃក្រមរដ្ឋប្បវេណីចាស់របស់កម្ពុជា

**មាត្រា ១២៥៧.–** វិធីនៃការយល់ព្រមដោយកម្រិត

សន្តតិជនដែលមានបំណងចង់យល់ព្រមដោយកម្រិត ត្រូវធ្វើបញ្ជីសារពើភ័ណ្ឌ ហើយត្រូវដាក់ពាក្យសុំអំពីការយល់ព្រមដោយកម្រិតនោះ ទៅតុលាការ នៅក្នុងអំឡុងពេល ដែលបានកំណត់នៅក្នុងកថាខណ្ឌទី ១ នៃមាត្រា ១២៤៨ (អំឡុងពេលនៃការយល់ព្រម ឬ ការបោះបង់) នៃក្រមនេះ ។

(កំណត់)

មាត្រានេះ គឺជាបញ្ញត្តិចែងអំពីវិធី ជាអាទិ៍ សម្រាប់ធ្វើការយល់ព្រមដោយកម្រិត ។

ដើម្បីធ្វើការយល់ព្រមដោយកម្រិត សន្តតិជនត្រូវដាក់ពាក្យសុំទៅតុលាការក្នុងអំឡុងពេលគិតឱ្យបានជិតដល់ ។ ក្នុងករណីនៃសហសន្តតិកម្ម ទោះបីមានសន្តតិជនណាម្នាក់ដែលបានទុកឱ្យអំឡុងពេលនេះកន្លងផុតក៏ដោយ អាចគណនាអំឡុងពេលនេះ ដោយយកថ្ងៃដែលសន្តតិជនចុងក្រោយគេដឹងថា សន្តតិកម្មបានចាប់ផ្តើម មកធ្វើជាមូលដ្ឋាន ។ ក្នុងករណីនៃសហសន្តតិកម្ម សហសន្តតិជនទាំងអស់ ត្រូវដាក់ពាក្យសុំទៅតុលាការ ដើម្បីធ្វើការយល់ព្រមដោយកម្រិត (មាត្រា ១២៥៦ កថាខណ្ឌទី ២) ។ ដូច្នេះ ការគណនាអំឡុងពេលនេះគឺដើម្បីការពារសិទ្ធិរបស់សន្តតិជនដែលដឹងអំពីការចាប់ផ្តើមសន្តតិកម្មក្រោយគេ ។

នៅពេលដែលដាក់ពាក្យសុំទៅតុលាការ សន្តតិជនត្រូវដាក់បញ្ជីសារពើភ័ណ្ឌនៃមតិក ។ ទម្រង់នៃបញ្ជីសារពើភ័ណ្ឌគ្មានចែងក្នុងបញ្ញត្តិទេ ក៏ប៉ុន្តែ ត្រូវធ្វើសរសេរមតិកសកម្ម មតិកអកម្ម ដែលសន្តតិជនបានទទួលបន្តដោយចាប់ផ្តើមសន្តតិកម្មទាំងអស់ ក្នុងកម្រិតដែលមានលទ្ធភាពអាចដឹង ។ ប្រសិនបើមិនបានបញ្ជាក់ក្នុងបញ្ជីសារពើភ័ណ្ឌនេះឱ្យបាន



គ្រប់គ្រាន់ដោយចេតនា ត្រូវចាត់ទុកថាជាការយល់ព្រមទាំងស្រុង (មាត្រា ១២៥៩) ។ ក្នុងករណីដែលអាចស្មានបានថា ចាំបាច់ត្រូវការពេលវេលា ដើម្បីធ្វើបញ្ជីសារពើភ័ណ្ឌមតិកនោះ សន្តតិជនអាចសុំឱ្យពន្យារអំឡុងពេលគិតឱ្យបានជិតដល់នេះបាន ដោយយោងតាមមាត្រា ១២៤៨ កថាខណ្ឌទី ១ វាក្យខណ្ឌទី ១ ។

(មាត្រាពាក់ព័ន្ធ)

មាត្រា ៩២៤ នៃក្រមរដ្ឋប្បវេណីជប៉ុន និង មាត្រា ៩៩១ មាត្រា ៩៨៦ នៃក្រមរដ្ឋប្បវេណីចាស់របស់កម្ពុជា

**មាត្រា ១២៥៨.–** អានុភាពនៃការយល់ព្រមដោយកម្រិត

១-ក្នុងករណីដែលសន្តតិជនបានយល់ព្រមដោយកម្រិត ម្ចាស់បំណុលរបស់មតកជន ពុំអាចតាមទាមទារឱ្យសន្តតិជនទទួលខុសត្រូវ ចំពោះទ្រព្យសម្បត្តិផ្ទាល់ខ្លួនរបស់សន្តតិជននោះបានឡើយ ។

២-ក្នុងករណីដែលបានកំណត់នៅក្នុងកថាខណ្ឌទី ១ ខាងលើនេះ សិទ្ធិ និង កាតព្វកិច្ចរបស់សន្តតិជនដែលមានចំពោះមតកជននោះ ត្រូវចាត់ទុកថាមិនបានរលត់ដោយល្បាកុលភាពឡើយ ។

(កំណត់)

មាត្រានេះចែងអំពីអានុភាពនៃការយល់ព្រមដោយកម្រិត ដែលមានខ្លឹមសារថា ម្ចាស់បំណុលរបស់មតកជន មិនអាចទាមទារឱ្យសន្តតិជនទទួលខុសត្រូវ ចំពោះទ្រព្យសម្បត្តិផ្ទាល់ខ្លួនរបស់សន្តតិជននោះបានឡើយ ជាអាទិ៍ ។

កថាខណ្ឌទី ១ ជាបញ្ញត្តិស្តីពីអានុភាពជាសារធាតុនៃការយល់ព្រមដោយកម្រិត ។

ទោះបីជាបានយល់ព្រមដោយកម្រិតក៏ដោយ តាមផ្លូវច្បាប់ មតិកនោះត្រូវធ្លាក់ទៅសន្តតិជន ក៏ប៉ុន្តែ ជាសារធាតុទ្រព្យសម្បត្តិនោះត្រូវធ្វើការជម្រះបញ្ជីផ្សេងពីទ្រព្យសម្បត្តិផ្ទាល់របស់សន្តតិជន ហេតុនេះហើយ សិទ្ធិលើបំណុល និង កាតព្វកិច្ចរបស់សន្តតិជន និង មតកជន មិនអាចរលត់ដោយព្យាកុលភាពទេ ពោលគឺចាំបាច់ត្រូវធ្វើការជម្រះបញ្ជី ដោយនីតិវិធីដូចគ្នានឹងការជម្រះបញ្ជីសិទ្ធិលើបំណុល និង កាតព្វកិច្ចផ្សេងដែរ ។ ដូច្នេះ កថាខណ្ឌទី ២ បានចែងថា សិទ្ធិ និង កាតព្វកិច្ចរបស់សន្តតិជនដែលមានចំពោះមតកជននោះ ត្រូវចាត់ទុកថា មិនបានរលត់ដោយព្យាកុលភាពឡើយ ។

ម្យ៉ាងទៀត ការគ្រប់គ្រង ឬ ការជម្រះបញ្ជី ជាអាទិ៍ នៃទ្រព្យសម្បត្តិ ក្នុងករណីដែលមានការយល់ព្រមដោយកម្រិត មានចែងពីមាត្រា ១២៨០ ទៅ ។

(មាត្រាពាក់ព័ន្ធ)

មាត្រា ៩២៥ នៃក្រមរដ្ឋប្បវេណីជប៉ុន

**មាត្រា ១៤៣.-**

ភាគហ៊ុននីមួយៗត្រូវចុះក្នុងបញ្ជីទៅតាមបែបបទដែលបានកំណត់ ។ ភាគហ៊ុននីមួយៗ ត្រូវមានតម្លៃចារឹកលើប័ណ្ណ ហើយក្រុមហ៊ុនមិនត្រូវចេញប័ណ្ណភាគហ៊ុនណាមួយដែលមានតម្លៃតិចជាងតម្លៃចារឹកលើប័ណ្ណនោះទេ ។ សិទ្ធិ ឯកសិទ្ធិ ការរឹតត្បិត និងលក្ខខណ្ឌទាំងឡាយ ដែលភ្ជាប់ទៅនឹងប័ណ្ណភាគហ៊ុនប្រភេទនីមួយៗត្រូវបានកំណត់នៅក្នុងលក្ខន្តិកៈរបស់ក្រុមហ៊ុន ។

**មាត្រា ១៤៤.-**

ក្នុងករណីលក្ខន្តិកៈមិនបានចែងនូវចំនួន និងតម្លៃនៃប័ណ្ណភាគហ៊ុនទេ ក្រុមហ៊ុនត្រូវបោះលក់ចេញយ៉ាងតិចបំផុតមួយពាន់ភាគហ៊ុន ដែលមានតម្លៃចារឹកលើប័ណ្ណមិនតិចជាងបួនពាន់រៀលក្នុងមួយហ៊ុនៗ ។





ក្នុងករណីលក្ខន្តិកៈរបស់ក្រុមហ៊ុន មិនបានបញ្ជាក់នូវប្រភេទនៃភាគហ៊ុនទេនោះ ក្រុមហ៊ុនត្រូវមានប្រភេទភាគហ៊ុនតែមួយប៉ុណ្ណោះ ហើយសិទ្ធិរបស់សមាជិកហ៊ុននៃភាគហ៊ុនទាំងនេះគឺស្មើគ្នា និងរួមបញ្ចូលនូវសិទ្ធិ :

១-ក្នុងការបោះឆ្នោតនៅគ្រប់មហាសន្និបាតនៃម្ចាស់ហ៊ុនរបស់ក្រុមហ៊ុន ។

២-ក្នុងការទទួលនូវរាល់ភាគលាភ ដែលបានប្រកាសដោយក្រុមហ៊ុន ។

៣- ក្នុងការទទួលនូវទ្រព្យ ដែលនៅសេសសល់របស់ក្រុមហ៊ុន នៅពេលមានការរំលាយ ។

**មាត្រា ១២៤.–**

អភិបាលអាចត្រូវដកហូតចេញពីមុខតំណែងបានដោយសំឡេងភាគច្រើនដាច់ខាតនៃម្ចាស់ហ៊ុនដែលមានសិទ្ធិបោះឆ្នោត ទោះជាមាន ឬគ្មានមូលហេតុក៏ដោយ ។

**មាត្រា ២២៤.–**

អភិបាលត្រូវបង្ហាញរបាយការណ៍ហិរញ្ញវត្ថុប្រចាំឆ្នាំ នៅក្នុងមហាសន្និបាតម្ចាស់ហ៊ុនប្រចាំឆ្នាំ ។ របាយការណ៍នោះត្រូវមានទាំង :

ក- របាយការណ៍ហិរញ្ញវត្ថុ ដែលប្រៀបធៀបរវាងឆ្នាំសារពើពន្ធបច្ចុប្បន្ន និងឆ្នាំសារពើពន្ធឆ្នាំមុន ។ នៅក្នុងឆ្នាំដំបូងនៃអត្ថិភាពរបស់ក្រុមហ៊ុនរបាយការណ៍ហិរញ្ញវត្ថុត្រូវចាប់ផ្តើមពិនិត្យពីពេលក្រុមហ៊ុនមានអត្ថិភាព និងបញ្ចប់នៅកាលបរិច្ឆេទមិនលើសពី ៦ (ប្រាំមួយ)ខែ មុនមហាសន្និបាតប្រចាំឆ្នាំ ។

ខ- របាយការណ៍របស់សវនករ ។





គ- ព័ត៌មានផ្សេងទៀត ដែលធ្វើទៅតាមស្ថានភាពហិរញ្ញវត្ថុរបស់ក្រុមហ៊ុន និងលទ្ធផលដែលទទួលបានពីប្រតិបត្តិការរបស់ក្រុមហ៊ុន ដែលតម្រូវដោយលក្ខន្តិកៈ បទបញ្ញាផ្ទៃក្នុង ឬ កិច្ចព្រមព្រៀងជាឯកច្ឆន្ទនៃម្ចាស់ហ៊ុន ។

**មាត្រា ២៨៧.–**

ម្ចាស់ហ៊ុនអាចប្តឹង ឬ ធ្វើអន្តរាគមន៍ក្នុងនាម និងសិទ្ធិរបស់ក្រុមហ៊ុន ។ ម្ចាស់ហ៊ុនត្រូវបំពេញគ្រប់លក្ខខណ្ឌដូចខាងក្រោម :

ក- ជាម្ចាស់ហ៊ុននៅក្នុងក្រុមហ៊ុន ឬអ្នកស្នងមរតករបស់ម្ចាស់ហ៊ុន នៅក្នុងអំឡុងពេលដែលការប្តឹងតវ៉ានោះ កំពុងកើតមានឡើងដោយសារពាណិជ្ជកិច្ចរបស់ក្រុមហ៊ុន ។

ខ- មិនបានបោះឆ្នោតគាំទ្រ ឬមិនបានឱ្យសច្ចានុម័តតាមរបៀបណាផ្សេងទៀតឡើយ ។

គ- បានតវ៉ាជាលាយលក្ខណ៍អក្សរទៅក្រុមប្រឹក្សាភិបាល ដើម្បីធ្វើការដោះស្រាយជម្លោះហើយដែលក្រុមប្រឹក្សាភិបាលដោះស្រាយមិនបាន ។

ឃ- ផ្តល់លិខិតជូនដំណឹងទៅឱ្យក្រុមប្រឹក្សាភិបាល មុនពេលដាក់បណ្តឹងទៅតុលាការ ។

បណ្តឹងជំនួសមុខ បន្ទាប់ពីបាននៅតុលាការ មិនត្រូវបានដោះស្រាយដោយគ្មានការព្រមព្រៀងពីតុលាការឡើយ ។

**មាត្រា ២៨៨.–**

រាល់ប្រាក់សំណងដែលបានមកពីបណ្តឹងនេះ ត្រូវជាទ្រព្យសម្បត្តិរបស់ក្រុមហ៊ុន ។ ប្រសិនបើបណ្តឹងបានផ្តល់ផលដល់ក្រុមហ៊ុន ម្ចាស់ហ៊ុនដែលបានធ្វើបណ្តឹងជំនួសមុខអាចស្នើសុំទៅតុលាការ ដើម្បីឱ្យខ្លួនបានទទួលសំណងសមស្រប ។

**មាត្រា ២៥១.–**

ក្រុមហ៊ុនដែលគ្មានចេញប័ណ្ណភាគហ៊ុនណាមួយ អាចរំលាយនៅពេលណាក៏បាន តាមរយៈសេចក្តីសម្រេចរបស់អភិបាលទាំងអស់ ។

ក្រុមហ៊ុនគ្មានទ្រព្យសម្បត្តិនិងគ្មានបំណុល អាចធ្វើការរំលាយបាន តាមរយៈសេចក្តីសម្រេចចិត្តពិសេសរបស់ម្ចាស់ហ៊ុន ឬប្រសិនបើក្រុមហ៊ុនមានចេញប័ណ្ណភាគហ៊ុនច្រើនជាងមួយប្រភេទនោះ ការរំលាយត្រូវធ្វើតាមរយៈសេចក្តីសម្រេចពិសេសរបស់អ្នកកាន់កាប់ភាគហ៊ុននៃប្រភេទនីមួយៗ ទោះបីម្ចាស់ហ៊ុននោះមានសិទ្ធិ ឬគ្មានសិទ្ធិបោះឆ្នោតក៏ដោយ ។

**មាត្រា ២៤១.–**

ក្រុមហ៊ុនពីរ ឬ ច្រើន អាចរំលាយបញ្ចូលគ្នាជាក្រុមហ៊ុនតែមួយ ឬអាចបង្រួមចូលគ្នាជាក្រុមហ៊ុនថ្មីមួយផ្សេងទៀតបាន ។

ក្រុមហ៊ុនដែលរំលាយហៅថាក្រុមហ៊ុនដើម ។ ក្រុមហ៊ុនដែលទទួលបន្ទុកធ្វើអាជីវកម្មតទៅទៀតហៅថាក្រុមហ៊ុនថ្មី ។ ក្រុមហ៊ុនដើមនឹងត្រូវបាត់បង់នូវនីតិបុគ្គលិកលក្ខណៈ ចាប់ពីថ្ងៃដែលក្រសួងពាណិជ្ជកម្មចេញវិញ្ញាបនបត្របញ្ជាក់ការរំលាយក្រុមហ៊ុនបញ្ចូលគ្នា ។

**មាត្រា ២៤២.–**

ក្រុមប្រឹក្សាភិបាល របស់ក្រុមហ៊ុននីមួយៗ ដែលស្នើរំលាយក្រុមហ៊ុនបញ្ចូលគ្នា ត្រូវអនុម័តនូវសេចក្តីសម្រេចយល់ព្រមលើកិច្ចព្រមព្រៀងនៃការរំលាយបញ្ចូលគ្នា ។ លើកលែងតែមានចែងផ្សេងក្នុងលក្ខន្តិកៈ ការអនុម័តនេះត្រូវផ្អែកលើចំនួនភាគច្រើនដាច់ខាតនៃអភិបាលទាំងអស់ ។

**មាត្រា ២៤១.–**

ក្រុមហ៊ុនពីរ ឬ ច្រើន អាចរំលាយបញ្ចូលគ្នាជាក្រុមហ៊ុនតែមួយ ឬអាចបង្រួមចូលគ្នាជាក្រុមហ៊ុនថ្មីមួយផ្សេងទៀតបាន ។

ក្រុមហ៊ុនដែលរំលាយហៅថាក្រុមហ៊ុនដើម ។ ក្រុមហ៊ុនដែលទទួលបន្ទុកធ្វើអាជីវកម្មតទៅទៀតហៅថាក្រុមហ៊ុនថ្មី ។ ក្រុមហ៊ុនដើមនឹងត្រូវបាត់បង់នូវនីតិបុគ្គលិកលក្ខណៈ ចាប់ពីថ្ងៃដែលក្រសួងពាណិជ្ជកម្មចេញវិញ្ញាបនបត្របញ្ជាក់ការរំលាយក្រុមហ៊ុនបញ្ចូលគ្នា ។

**មាត្រា ២៤២.–**

ក្រុមប្រឹក្សាភិបាល របស់ក្រុមហ៊ុននីមួយៗ ដែលស្នើរំលាយក្រុមហ៊ុនបញ្ចូលគ្នា ត្រូវអនុម័តនូវសេចក្តីសម្រេចយល់ព្រមលើកិច្ចព្រមព្រៀងនៃការរំលាយបញ្ចូលគ្នា ។ លើកលែងតែមានចែងផ្សេងក្នុងលក្ខន្តិកៈ ការអនុម័តនេះត្រូវផ្អែកលើចំនួនភាគច្រើនដាច់ខាតនៃអភិបាលទាំងអស់ ។

**មាត្រា ២៤៣.–**

កិច្ចព្រមព្រៀងនៃការរំលាយក្រុមហ៊ុនបញ្ចូលគ្នាត្រូវចែងពី :

ក- ចំណុចសំខាន់ៗនិងលក្ខខណ្ឌនៃការរំលាយក្រុមហ៊ុនបញ្ចូលគ្នា ។

ខ- លក្ខន្តិកៈរបស់ក្រុមហ៊ុនថ្មីដែលទទួលបន្ទុកបន្តធ្វើអាជីវកម្ម ។

គ- បែបបទនៃការផ្លាស់ប្តូរភាគហ៊ុននៃប្រភេទនីមួយៗរបស់ក្រុមហ៊ុនដើមឱ្យទៅជាភាគហ៊ុន ឬ មូលបត្រផ្សេងៗរបស់ក្រុមហ៊ុនថ្មី ដែលទទួលបន្ទុកបន្តអាជីវកម្ម ។

ឃ- របាយការណ៍ស្តីពីសាច់ប្រាក់ សិទ្ធិ មូលបត្រ ឬ កម្មសិទ្ធិផ្សេងៗទៀតដែលអ្នកកាន់កាប់ភាគហ៊ុនត្រូវទទួល ក្នុងការរំលាយក្រុមហ៊ុនបញ្ចូលគ្នា ប្រសិនបើភាគហ៊ុនណាមួយរបស់ក្រុមហ៊ុនដើម មិនត្រូវប្តូរទៅជាភាគហ៊ុនរបស់ក្រុមហ៊ុនថ្មី ដែលទទួលបន្ទុកបន្តអាជីវកម្មនោះទេ ។

ង- ព័ត៌មានមានដទៃទៀតដែលម្ចាស់ហ៊ុនក្នុងប្រភេទនីមួយៗចង់ដឹងដើម្បីជាមូលដ្ឋានធ្វើការសម្រេចចិត្តក្នុងការបោះឆ្នោតលើការរំលាយក្រុមហ៊ុនបញ្ចូលគ្នា ។

ច- ព័ត៌មានលម្អិតនៃកិច្ចសម្របសម្រួលចាំបាច់ ដើម្បីធ្វើឱ្យប្រសើរឡើងនិងដើម្បីផ្តល់ដល់ការគ្រប់គ្រង ព្រមទាំងប្រតិបត្តិការនាពេលបន្ទាប់នៃក្រុមហ៊ុនថ្មីដែលទទួលបន្ទុកបន្តអាជីវកម្ម ។

**មាត្រា ២៤៤.–**

ក្រោយពីបានទទួលសេចក្តីសម្រេចពីក្រុមប្រឹក្សាភិបាលក្រុមហ៊ុនដើមនីមួយៗ ម្ចាស់ក្រុមហ៊ុនថ្មីត្រូវជូនដំណឹងទៅឱ្យម្ចាស់ហ៊ុនស្តីពីកិច្ចប្រជុំម្ចាស់ហ៊ុន ដែលមានសិទ្ធិបោះឆ្នោតនូវព័ត៌មានដូចតទៅ :

ក- នៅក្នុងរយៈពេល ៣០(សាមសិប)ថ្ងៃ ក្រោយកិច្ចព្រមព្រៀងនេះ ក្រុមប្រឹក្សាភិបាលនៃក្រុមហ៊ុនដើមនីមួយៗត្រូវធ្វើមហាសន្និបាតម្ចាស់ហ៊ុន ដើម្បីបោះឆ្នោតសម្រេចលើកិច្ចព្រមព្រៀងស្តីពីការរំលាយក្រុមហ៊ុនបញ្ចូលគ្នា ។

ខ- លិខិតជូនដំណឹងត្រូវភ្ជាប់ជាមួយនឹងច្បាប់ចម្លងនៃកិច្ចព្រមព្រៀងស្ដីពីការរំលាយក្រុមហ៊ុនបញ្ចូលគ្នា ។

គ- ក្រុមហ៊ុនដើមនីមួយៗត្រូវផ្ដល់លិខិតជូនដំណឹងស្ដីពីកិច្ចប្រជុំម្ចាស់ហ៊ុនយ៉ាងតិច ២០(ម្ភៃ)ថ្ងៃមុន ។

**មាត្រា ២៤៥.-**

ការរំលាយក្រុមហ៊ុនបញ្ចូលគ្នាត្រូវមានការយល់ព្រមដោយសេចក្ដីសម្រេចពិសេសរបស់ម្ចាស់ហ៊ុនពីរភាគបី (២/៣) នៃក្រុមហ៊ុនដើមនីមួយៗ ។

**មាត្រា ២៤៦.-**

ទោះបីលក្ខន្តិកៈរបស់ក្រុមហ៊ុនមិនអនុញ្ញាតឱ្យប្រភេទភាគហ៊ុនណាមួយមានសិទ្ធិជាទូទៅ ក្នុងការបោះឆ្នោតក៏ដោយ ក៏ប្រភេទភាគហ៊ុននោះនឹងនៅតែមានសិទ្ធិដោយឡែក ក្នុងការបោះឆ្នោតទៅតាមប្រភេទភាគហ៊ុនរបស់ខ្លួន ដើម្បីសម្រេចលើការរំលាយក្រុមហ៊ុនបញ្ចូលគ្នាដែលអាចនឹងកែប្រែដោយផ្ទាល់ និងដោយប្រយោលនូវសិទ្ធិ ឯកសិទ្ធិ ការរឹតត្បិតនិងលក្ខខណ្ឌនៃប្រភេទ ឬ សេរីនៃភាគហ៊ុនផ្សេងៗ ។

អំណាចបោះឆ្នោតដែលបង្កើតឡើងក្នុងមាត្រានេះមិនអាចបដិសេធឬកែប្រែដោយលក្ខន្តិកៈរបស់ក្រុមហ៊ុន ឬតាមរបៀបណាផ្សេងទៀតបានឡើយ ។

**មាត្រា ២៤៧.-**

អភិបាលរបស់ក្រុមហ៊ុនថ្មី ដែលទទួលធ្វើអាជីវកម្មបន្ត ត្រូវតម្កល់ឯកសារទុកនៅក្រសួងពាណិជ្ជកម្ម ដែលមានជាអាទិ៍ :

ក- កិច្ចព្រមព្រៀងស្ដីពីការរំលាយក្រុមហ៊ុនបញ្ចូលគ្នា ។

ខ- សេចក្ដីសម្រេចយល់ព្រមលើកិច្ចព្រមព្រៀងស្ដីពីការរំលាយក្រុមហ៊ុនបញ្ចូលគ្នានៃអង្គប្រជុំរបស់ក្រុមប្រឹក្សាភិបាល និងនៃមហាសន្និបាតម្ចាស់ហ៊ុនរបស់ក្រុមហ៊ុនដើមនីមួយៗ ។

គ- លក្ខន្តិកៈរបស់ក្រុមហ៊ុនថ្មីដែលទទួលធ្វើអាជីវកម្មបន្ត ។

ឃ- សេចក្ដីប្រកាសរបស់អភិបាលឬអ្នកគ្រប់គ្រងនៃក្រុមហ៊ុនដើមនីមួយៗ ដែលធ្វើឡើងតាមការទាមទារពីមន្ត្រីទទួលបន្ទុកគ្រប់គ្រងក្រុមហ៊ុននៃក្រសួងពាណិជ្ជកម្ម ។ សេចក្ដីប្រកាសនោះត្រូវមានមូលហេតុសមរម្យដូចតទៅ :

១- ក្រុមហ៊ុនដើមនិងក្រុមហ៊ុនថ្មីដែលទទួលធ្វើអាជីវកម្មបន្តនីមួយៗគឺមានលទ្ធភាពសងបំណុលរបស់ខ្លួន តាមពេលវេលាដែលត្រូវសង ។

២- ធនធានសរុបរបស់ក្រុមហ៊ុនថ្មី ដែលទទួលធ្វើអាជីវកម្មបន្ត មិនត្រូវតិចជាងចំនួនសរុបនៃបំណុលដែលខ្លួនជំពាក់ និងដើមទុនចុះបញ្ជីនៃក្រុមហ៊ុនដើម ។

៣- គ្មានម្ចាស់បំណុលណាមួយទទួលការខូចខាតដោយសារការរំលាយក្រុមហ៊ុនបញ្ចូលគ្នានេះទេ ។

៤- លិខិតជូនដំណឹងជាលាយលក្ខណ៍អក្សរ ត្រូវបានប្រគល់ឱ្យម្ចាស់បំណុលទាំងអស់របស់ក្រុមហ៊ុនដើម ហើយគ្មានម្ចាស់បំណុលណាមួយធ្វើការជំទាស់ដែលមានមូលហេតុស្របទៅលើការរំលាយបញ្ចូលគ្នានោះទេ ។

**មាត្រា ២៤៨.-**

នៅពេលទទួលលក្ខន្តិកៈស្ដីពីការរំលាយក្រុមហ៊ុនបញ្ចូលគ្នា ក្រសួងពាណិជ្ជកម្មត្រូវចេញវិញ្ញាបនបត្របញ្ជាក់ពីការរំលាយក្រុមហ៊ុនបញ្ចូលគ្នា ចាប់ពីកាលបរិច្ឆេទដែលមានចុះនៅលើវិញ្ញាបនបត្រនេះ :

ក- ការរំលាយបញ្ចូលគ្នារបស់ក្រុមហ៊ុនដើម និងការបន្តជាក្រុមហ៊ុនតែមួយរបស់គេ ត្រូវចូលជាធរមាន ។

ខ- កម្មសិទ្ធិរបស់ក្រុមហ៊ុនដើមនីមួយៗ ត្រូវបានជាកម្មសិទ្ធិក្រុមហ៊ុនថ្មីដែលបន្តធ្វើអាជីវកម្ម ។

គ- ក្រុមហ៊ុនថ្មីដែលបន្តធ្វើអាជីវកម្ម ត្រូវទទួលខុសត្រូវចំពោះកាតព្វកិច្ចរបស់ក្រុមហ៊ុនដើមនីមួយៗ ។

**មាត្រា ២៤៩.-**

ក្នុងការរំលាយក្រុមហ៊ុនបញ្ចូលគ្នា ម្ចាស់ហ៊ុនមួយចំនួននៃក្រុមហ៊ុនដើម មានសិទ្ធិទាមទារឱ្យមានការវាយតម្លៃ លើតម្លៃភាគហ៊ុនរបស់ខ្លួននៅក្នុងក្រុមហ៊ុនដើម ។ ប៉ុន្តែដើម្បីទទួលបានសិទ្ធិធ្វើការវាយតម្លៃ ម្ចាស់ហ៊ុនទាំងនោះត្រូវបំពេញលក្ខខណ្ឌដូចតទៅ :

ក- មុនពេលម្ចាស់ហ៊ុនបានបោះឆ្នោតធ្វើការរំលាយក្រុមហ៊ុនបញ្ចូលគ្នា ម្ចាស់ហ៊ុនត្រូវកាន់កាប់ភាគហ៊ុននៅក្នុងក្រុមហ៊ុនដើមណាមួយ ។

ខ- នៅក្នុងពេលបោះឆ្នោត ម្ចាស់ហ៊ុននោះមិនបានបោះឆ្នោតគាំទ្រការរំលាយក្រុមហ៊ុនបញ្ចូលគ្នាទេ ។

គ- ម្ចាស់ហ៊ុននោះត្រូវធ្វើការទាមទារជាលាយលក្ខណ៍អក្សរចំពោះក្រុមហ៊ុនថ្មីដែលទទួលធ្វើអាជីវកម្មបន្ត ក្រោយពីលក្ខន្តិកៈស្តីពីការរំលាយក្រុមហ៊ុនបញ្ចូលគ្នាត្រូវបានតម្កល់ទុកនៅក្រសួងពាណិជ្ជកម្ម ។

ឃ- នៅពេលដែលធ្វើការទាមទារវាយតម្លៃ ម្ចាស់ហ៊ុននោះត្រូវប្រគល់ប័ណ្ណភាគហ៊ុនរបស់ខ្លួន ទៅឱ្យក្រុមហ៊ុនថ្មីដែលទទួលធ្វើអាជីវកម្មបន្ត ។

**មាត្រា ២៥០.-**

នៅពេលមានការទាមទារវាយតម្លៃលើតម្លៃភាគហ៊ុន ក្រុមហ៊ុនថ្មីដែលទទួលធ្វើអាជីវកម្មបន្តនិងម្ចាស់ហ៊ុនដែលធ្វើការទាមទារនេះ ត្រូវចរចាគ្នាដើម្បីសម្រុះសម្រួល

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ
KINGDOM OF CAMBODIA
*Nation - Religion - King*

ក្រសួងពាណិជ្ជកម្ម
*Ministry of Commerce*
លេខ ១៤៧ ព.ណ.ជ.ប.ក-ប្រក

ភ្នំពេញ, ថ្ងៃទី ០៣ ខែ មិថុនា ឆ្នាំ ២០១៤

# ប្រកាស
## ស្តីពី
## បែបបទ និងនីតិវិធី ចុះក្នុងបញ្ជីពាណិជ្ជកម្ម នូវរាល់ការផ្លាស់ប្តូរ និងកែប្រែរបស់សហគ្រាស ក្រុមហ៊ុន

---

## ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យ លេខ នសរកត/០៩១៣/៩០៣/ចុះថ្ងៃទី ២៤ ខែ កញ្ញា ឆ្នាំ ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នសរកម/០១៩៦/១៦ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងពាណិជ្ជកម្ម
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦៩៥/០៤ ចុះថ្ងៃទី ២៦ ខែ មិថុនា ឆ្នាំ ១៩៩៥ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីវិធានពាណិជ្ជកម្ម និងបញ្ជីពាណិជ្ជកម្ម
- បានឃើញព្រះរាជក្រមលេខ នស/រកម/១១៩៩/១២ ចុះថ្ងៃទី ១៨ ខែ វិច្ឆិកា ឆ្នាំ ១៩៩៩ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីវិសោធនកម្មច្បាប់ស្តីពីវិធានពាណិជ្ជកម្ម និងបញ្ជីពាណិជ្ជកម្ម
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦០៥/១៩ ចុះថ្ងៃទី ១៩ ខែ មិថុនា ឆ្នាំ ២០០៥ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីសហគ្រាសពាណិជ្ជកម្ម
- បានឃើញអនុក្រឹត្យលេខ ១៣១ អនក្រ.បក ចុះថ្ងៃទី ១៩ ខែ មីនា ឆ្នាំ ២០១៤ ស្តីពីការរៀបចំ និងប្រព្រឹត្តទៅរបស់ក្រសួងពាណិជ្ជកម្ម
- យោងតាមការចាំបាច់របស់ក្រសួងពាណិជ្ជកម្ម

## សម្រេច

**ប្រការ ១.-**

ត្រូវបានកំណត់ឲ្យពាណិជ្ជករ សហកម្មសិទ្ធិករទូទៅ ស្ថាបនិក ឬអភិបាលម្នាក់ៗ ជាអ្នកទទួលខុសត្រូវចំពោះ - ការអនុវត្តន៍នូវការចុះបញ្ជីពាណិជ្ជកម្ម ការតម្កល់ទុក និងផ្សព្វផ្សាយដែលបានតម្រូវដោយច្បាប់។

ឡូត៍លេខ ១៩-៦១ វិថីក្រសួងពាណិជ្ជកម្ម (១១៣បេ). ភូមិទឹកថ្លា សង្កាត់ទឹកថ្លា ខណ្ឌសែនសុខ. ភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា
*Ministry of Commerce, Lot 19-61, MOC Road (113B Road), Phum Teuk Thla, Sangkat Teuk Thla, Khand Sen Sok, Phnom Penh, Kingdom of CAMBODIA*
ទូរស័ព្ទ / ទូរសារ:(៨៥៥)-២៣ ៨៦៦ ៤៦៩
*Phone/Facsimile: (855)-23 866 469*

**ប្រការ ២.-**

ពាណិជ្ជករ សហកម្មសិទ្ធិករទូទៅ ស្ថាបនិក ឬអភិបាលម្នាក់ៗ ត្រូវជាអ្នកចុះហត្ថលេខាលើពាក្យស្នើសុំចុះក្នុងបញ្ជីពាណិជ្ជកម្មនូវការកែប្រែក្រោយចុះបញ្ជី និងផ្តល់ឯកសារគតម្រូវសម្រាប់តម្កល់ទៅឲ្យនាយកដ្ឋានចុះបញ្ជីពាណិជ្ជកម្ម ។

**ប្រការ ៣.-**

ត្រូវចុះក្នុងបញ្ជីពាណិជ្ជកម្មផងដែរ ប្រសិនបើសហគ្រាស ក្រុមហ៊ុន មានការកែប្រែក្នុងដំណើរការអាជីវកម្មរបស់ខ្លួនដូចខាងក្រោម៖

- ការផ្លាស់ប្តូរនាមករណ៍ សហគ្រាស ឬក្រុមហ៊ុន
- ការបន្ថែម ការបន្ថយ ឬការផ្លាស់ប្តូរគោលបំណងកម្មវត្ថុអាជីវកម្ម ឬសកម្មភាពប្រកបពាណិជ្ជកិច្ចរបស់ក្រុមហ៊ុន
- ការបែងចែកសារជាថ្មី នូវចំនួនភាគហ៊ុនជាប្រភេទឡើងវិញ ដោយមានការកែប្រែលក្ខណៈដាច់ខាត និងលក្ខណៈធៀបរបស់ប្រភេទភាគហ៊ុនណាមួយ
- ការកែប្រែភាគលាភ នៃប្រភេទភាគហ៊ុនណាមួយ
- ការបង្កើនដើមទុនដោយបង្កើតភាគហ៊ុនប្រភេទថ្មី ដែលមានលក្ខណៈដាច់ខាត និងលក្ខណៈធៀបប្រសើរជាង ឬទាបជាងប្រភេទភាគហ៊ុនដែលមានរួចហើយ ។
- ការបន្ថយដើមទុនចុះបញ្ជី ដោយបញ្ចុះតំលៃចារឹកលើប័ណ្ណនៃប្រភេទភាគហ៊ុនណាមួយ ឬដោយបន្ថយចំនួនភាគហ៊ុនដែលអនុញ្ញាត
- ការកែប្រែថិរវេលា នៃអត្ថិភាពរបស់ក្រុមហ៊ុន
- ការផ្លាស់ប្តូរទីស្នាក់ការចុះបញ្ជី
- ការកែប្រែចំនួនកូរ៉ុម
- បន្ថែមបទបញ្ញត្តិណាមួយ ដែលច្បាប់អនុញ្ញាតឲ្យដាក់បញ្ចូលទៅក្នុងលក្ខន្តិកៈក្រុមហ៊ុន
- ការផ្ទេរ ឬលក់ភាគហ៊ុនទាំងឡាយដែលអនុញ្ញាតដោយច្បាប់ ។

**ប្រការ ៤.-**

ចំពោះការផ្ទេរ ឬលក់ភាគហ៊ុនដូចមានចែងក្នុងប្រការ ៣ ខាងលើ ដើម្បីធានាអះអាង និងទទួលខុសត្រូវលើការផ្ទេរ ឬលក់ភាគហ៊ុនថាពិតជាត្រឹមត្រូវ រាល់សំណុំលិខិតផ្ទេរ ឬលក់ភាគហ៊ុនត្រូវមានការបញ្ជាក់ដូចខាងក្រោម៖

- ការផ្ទេរ ឬលក់ភាគហ៊ុន ដែលម្ចាស់ភាគហ៊ុនជាអ្នកផ្ទេរ ឬលក់ភាគហ៊ុន នៅក្នុងព្រះរាជាណាចក្រកម្ពុជា រាល់សំណុំលិខិតផ្ទេរ ឬលក់ភាគហ៊ុន ត្រូវមានការបញ្ជាក់ពីមេធាវី ឬសារការី នៃព្រះរាជាណាចក្រកម្ពុជា
- ការផ្ទេរ ឬលក់ភាគហ៊ុន ដែលម្ចាស់ភាគហ៊ុនជាអ្នកផ្ទេរ ឬលក់ភាគហ៊ុន នៅក្រៅព្រះរាជាណាចក្រកម្ពុជា រាល់សំណុំលិខិតផ្ទេរ ឬលក់ភាគហ៊ុន ត្រូវមានការបញ្ជាក់ពីសារការី ឬអាជ្ញាធរ ដែលមានសមត្ថកិច្ច នៃប្រទេសដែលម្ចាស់ភាគហ៊ុនជាអ្នកផ្ទេរ ឬលក់ភាគហ៊ុនកំពុងរស់នៅ
- ក្នុងករណី ម្ចាស់ហ៊ុនដែលជាអ្នកផ្ទេរ ឬលក់ភាគហ៊ុនរបស់ខ្លួនមិនត្រូវការការបញ្ជាក់ពីមេធាវី ឬសារការី នោះសាម៉ីខ្លួនអាចមកចុះហត្ថលេខា និងផ្តិតមេដៃដោយផ្ទាល់នៅចំពោះមុខមន្ត្រីនាយកដ្ឋានចុះបញ្ជីពាណិជ្ជកម្ម។

**ប្រការ ៥.-**

ឯកសារតម្រូវ ដែលត្រូវផ្ដល់ជូននាយកដ្ឋានចុះបញ្ជីពាណិជ្ជកម្ម មានដូចខាងក្រោម៖

| | |
|---|---|
| - កំណត់ហេតុ និងសេចក្ដីសម្រេចសមូហភាពសន្និបាតរបស់ក្រុមហ៊ុន (ច្បាប់ដើម) | ចំនួន ០៣ ច្បាប់ |
| - ពាក្យស្នើសុំធ្វើការកែប្រែនិងផ្លាស់ប្ដូរ | ចំនួន ០៣ ច្បាប់ |
| - ច្បាប់ចម្លងវិញ្ញាបនបត្រចុះបញ្ជីពាណិជ្ជកម្ម (វិញ្ញាបនបត្រចុះបញ្ជីពាណិជ្ជកម្មច្បាប់ដើម ក្នុងករណី ក្រុមហ៊ុនធ្វើការកែប្រែ នាមករណ៍ ប្ដូរសញ្ជាតិ ឬប្ដូរទ្រង់ទ្រាយក្រុមហ៊ុន) | ចំនួន ០៣ ច្បាប់ |
| - ច្បាប់ចម្លងលិខិតគោលការណ៍ទទួលចុះឈ្មោះក្រុមហ៊ុនក្នុងបញ្ជីពាណិជ្ជកម្ម | ចំនួន ០៣ ច្បាប់ |
| - ច្បាប់ចម្លងប្រតិវេទន៍អំពីស្ថានភាពសហគ្រាសពាណិជ្ជកម្ម ប្រចាំឆ្នាំ | ចំនួន ០១ ច្បាប់ |
| - ច្បាប់ចម្លងប័ណ្ណប៉ាតង់ | ចំនួន ០៣ ច្បាប់ |
| - ច្បាប់ចម្លងអត្តសញ្ញាណប័ណ្ណ ឬ លិខិតឆ្លងដែន និងរូបថតទំហំ ៤ x ៦ របស់ម្ចាស់ហ៊ុនថ្មីម្នាក់ៗ ( ក្នុងករណីមានបន្ថែមសមាជិកភាគហ៊ុនថ្មី ) | |
| - ច្បាប់ចម្លងអាជ្ញាប័ណ្ណរបស់ក្រសួង - ស្ថាប័នពាក់ព័ន្ធ "បើសិនជាមាន" | ចំនួន ០៣ ច្បាប់ |

**ប្រការ ៦.-**

ប្រកាសលេខ ០៩៩MOC/SM2008 ចុះថ្ងៃទី ០៧ ខែ មេសា ឆ្នាំ ២០០៨ របស់ក្រសួងពាណិជ្ជកម្ម ស្ដីពី បែបបទ និងនីតិវិធីកែប្រែលក្ខន្តិកៈក្រុមហ៊ុន ត្រូវចាត់ទុកជានិរាករណ៍ ។

**ប្រការ ៧.-**

នាយកខុទ្ទកាល័យ អគ្គាធិការ អគ្គនាយក ប្រធាននាយកដ្ឋាន មន្ទីរពាណិជ្ជកម្មរាជធានី-ខេត្ត ប្រធានអង្គភាពចំណុះក្រសួងពាណិជ្ជកម្ម ត្រូវអនុវត្តប្រកាសនេះឱ្យមានប្រសិទ្ធភាពចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

**ឧបនាយករដ្ឋមន្ត្រី**
**រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម**

**ស៊ុន ចាន់ថុល**

***ចម្លងជូន***

- *អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា*
- *អគ្គលេខាធិការដ្ឋានរដ្ឋសភា*
- *ទីស្ដីការគណៈរដ្ឋមន្ត្រី*
- *ខុទ្ទកាល័យ សម្ដេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន*
- *ក្រសួង-ស្ថាប័ន*
- *ដូចប្រការ ៧ "ដើម្បីអនុវត្ត"*
- *សាលារាជធានី-ខេត្ត*
- *រាជកិច្ច*
- *ឯកសារ-កាលប្បវត្តិ*

**ព្រះរាជាណាចក្រកម្ពុជា**

លេខ: ២២០៤២ ພ.ថ អ/ប

**ជាតិ សាសនា ព្រះមហាក្សត្រ**

៚៚៚✽៛៛៛

# <u>សេចក្តីប្រកាសព័ត៌មាន</u>

**យោង** ÷ - សំណុំរឿងរដ្ឋប្បវេណីលេខ ២៧៦ ចុះថ្ងៃទី ២២ ខែកុម្ភៈ ឆ្នាំ២០២២ របស់សាលាដំបូងរាជធានីភ្នំពេញ។

- ដីកាសម្រេចបើកសំណុំរឿងក្ស័យធនលេខ ៥១ "ធ".វ.វ ចុះថ្ងៃទី ២៨ ខែមីនា ឆ្នាំ២០២២ របស់សាលាដំបូងរាជធានីភ្នំពេញ។
- ដីកាសម្រេចតែងតាំងអភិបាលបណ្តោះអាសន្នលេខ ៥២ "ធ".វ.វ ចុះថ្ងៃទី ២៨ ខែមីនា ឆ្នាំ២០២២ របស់សាលាដំបូងរាជធានីភ្នំពេញ។
- កំណត់ហេតុកិច្ចប្រជុំ ចុះថ្ងៃទី ០៣ ខែឧសភា ឆ្នាំ២០២២ រវាងអភិបាលបណ្តោះអាសន្ន និង ក្រុមហ៊ុន **Ezecom Co., Ltd** ។
- កិច្ចព្រមព្រៀង ចុះថ្ងៃទី ០៥ ខែឧសភា ឆ្នាំ២០២២ រវាងអភិបាលបណ្តោះអាសន្ន និង ក្រុមហ៊ុន **Ezecom Co., Ltd** ។

**អភិបាលបណ្តោះអាសន្ន** នៃកូនបំណុលក្រុមហ៊ុន King Technologies Co., Ltd. (Opennet) សូមប្រកាសព័ត៌មានជូនសាធារណជនឱ្យបានជ្រាបថា **អតិថិជនទាំងអស់** របស់កូនបំណុលក្រុមហ៊ុន King Technologies Co., Ltd. (Opennet) ត្រូវបានផ្ទេរទៅឱ្យក្រុមហ៊ុន **Ezecom Co., Ltd** ចាប់ពីថ្ងៃប្រកាសព័ត៌មាននេះតទៅ។

សូមទំនាក់ទំនងទូរស័ព្ទលេខ **023 888 181** និងលេខ **085 888 181** សម្រាប់សេវាអតិថិជន។

អាស្រ័យហេតុនេះ សូម **សាធារណជន** ជ្រាបជាព័ត៌មាន។

ថ្ងៃព្រហស្បតិ៍ ៥កើត ខែពិសាខ ឆ្នាំខាល ចត្វាស័ក ព.ស ២៥៦៥

រាជធានីភ្នំពេញ ថ្ងៃទី ០៥ ខែឧសភា ឆ្នាំ២០២២

**អភិបាលបណ្តោះអាសន្ន**

អភិបាលបណ្តោះអាសន្ន
Administrator
អ៊ុក_រី OUK RY

មជ្ឈមណ្ឌលភ្នំពេញ អាគារH ជាន់ទី៧ បន្ទប់ ៧៨១ មហាវិថីព្រះសីហនុ(៣)កែងវិថីព្រះសុធារស(២៧៤)សង្កាត់ទន្លេបាសាក់ ខណ្ឌចំការមន រាជធានីភ្នំពេញ ទូរស័ព្ទលេខ: ០១៥ ៧៥៥ ១៦៨
Phnom Penh Center Building H, 7th Floor, Room 781 Sothearous Blvd 3, Corner Sihanouk Blvd 274, Tonel Basac Chamkamon, Phnom Penh, Cambodia Tel: 015 755 168
Email: ryouk.bno@online.com.kh, neangsokchanchivorn@gmail.com